ធនាគារអភិវឌ្ឍន៍អាស៊ី

# យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស
# ២០០៥-២០០៩

## ព្រះរាជាណាចក្រកម្ពុជា

ខែ កុម្ភៈ ឆ្នាំ ២០០៥

# សមមូលរូបិយប័ណ្ណ

( ត្រឹមថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០០៤)

ឯកតារូបិយប័ណ្ណ - ប្រាក់រៀល

$១ = ៤.០៣១ រៀល

# អក្សរកាត់

| | | |
|---|---|---|
| ADB | – | ធនាគារអភិវឌ្ឍន៍អាស៊ី |
| ADF | – | មូលនិធិអភិវឌ្ឍន៍អាស៊ី |
| ASEAN | – | សមាគមប្រជាជាតិអាស៊ីអគ្នេយ៍ |
| CAPE | – | ការវាយតម្លៃកម្មវិធីនិងជំនួយប្រចាំប្រទេស |
| CPP | – | គណបក្សប្រជាជនកម្ពុជា |
| COS | – | យុទ្ធសាស្ត្រប្រតិបត្តិការប្រចាំប្រទេស |
| CSP | – | យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស |
| DFID | – | ក្រសួងអភិវឌ្ឍន៍អន្តរជាតិ (ចក្រភពអង់គ្លេស) |
| EA | – | ស្ថាប័នអនុវត្ត |
| FDI | – | វិនិយោគបរទេសផ្ទាល់ |
| GAP | – | ផែនការសកម្មភាពអភិបាលកិច្ច |
| GDP | – | ផលិតផលក្នុងស្រុកសរុប |
| GMS | – | មហាអនុតំបន់មេគង្គ |
| IFAPER | – | របាយការណ៍វាយតម្លៃនិងត្រួតពិនិត្យចំណាយសាធារណៈ |
| IPF | – | តួលេខផែនការចង្អុលបង្ហាញ |
| MDG | – | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| MEF | – | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| MFA | – | កិច្ចព្រមព្រៀងពហុវាយនភ័ណ្ឌ |
| NGO | – | អង្គការក្រៅរដ្ឋាភិបាល |
| NPRS | – | យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ |
| O&M | – | ប្រតិបត្តិការ និង ការថែទាំ |
| ODA | – | ជំនួយអភិវឌ្ឍន៍ផ្លូវការ |
| PBAs | – | ការវិភាគអាស្រ័យលើសមិទ្ធិផលសំរេចបាន |
| PFM | – | ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ |
| PRPA | – | កិច្ចព្រមព្រៀងស្តីពីភាពជាដៃគូកាត់បន្ថយភាពក្រីក្រ |
| RCSP | – | យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការប្រចាំតំបន់ |
| SARS | – | ជម្ងឺផ្លូវដង្ហើមធ្ងន់ធ្ងរ |
| SEDP II | – | ផែនការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចលើកទី២ ឆ្នាំ ២០០១-២០០៥ |
| SFMP | – | ផែនការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព |
| TWGs | – | ក្រុមបច្ចេកទេសការងារ |
| WTO | – | អង្គការពាណិជ្ជកម្មពិភពលោក |

# កំណត់សំគាល់

(១) ក្នុងរបាយការណ៍នេះ "ដុល្លារ" មានន័យថា ដុល្លារអាមេរិក

# យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេសកម្ពុជា ឆ្នាំ ២០០៥-២០០៩

## មាតិកា


ទំព័រ

**សេចក្តីសង្ខេប**

**១. និន្នាការនិងបញ្ហានៃកិច្ចអភិវឌ្ឍន៍បច្ចុប្បន្ន** **១**

ក. បរិបទអភិវឌ្ឍន៍ ១

ខ. កំណើនសេដ្ឋកិច្ច ២

គ. ភាពក្រីក្រ ៤

ឃ. បរិស្ថាននយោបាយ ៧

ង. អភិបាលកិច្ច និង សមត្ថភាពស្ថាប័ន ៩

ច. ការវាយតម្លៃយេនឌ័រ ១២

ឆ. វិស័យឯកជន ១២

ជ. បរិស្ថាន ១៥

ឈ. កិច្ចសហប្រតិបត្តិការក្នុងតំបន់ ១៧

**២. យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល** **១៧**

ក. គោលដៅនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍ ១៧

ខ. ការគៀងគរធនធាន និង វិនិយោគ ១៨

គ. តួនាទីនៃជំនួយពីក្រៅ ២០

ឃ. ការវាយតម្លៃរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលើយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ២១

**៣. បទពិសោធន៍អភិវឌ្ឍន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី** **២២**

ក. ឥទ្ធិពលនៃជំនួយកន្លងមក ២២

ខ. ស្នាដៃនិងស្ថានភាព ផលប័ត្រ ២៦

ខ. សេចក្តីសន្និដ្ឋាន និង មេរៀនសម្រាប់យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស ២៨

**៤. យុទ្ធសាស្ត្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី** **២៩**

ក. សេចក្តីសង្ខេបនៃចំណោទអភិវឌ្ឍន៍សំខាន់ៗ ២៩

ខ. គំរោងជាយុទ្ធសាស្ត្រនៃកម្មវិធីប្រចាំប្រទេស ៣០

**៥. កម្មវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី** **៣៧**

ក. កម្រិតជំនួយជារួម ៣៧

ខ. ជំនួយធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់កម្មវិធីអាទិភាពជាយុទ្ធសាស្ត្រ ៣៨

**៦. ការត្រួតពិនិត្យនិងការវាយតម្លៃស្នាដៃនិងហានិភ័យ ៥០**

ក. ហានិភ័យ ៥០

ខ. ការត្រួតពិនិត្យដំណើរការនិងផែនការ ៥៣

# សេចក្តីសង្ខេប


ប្រទេសកម្ពុជាគឺស្ថិតនៅលើផ្លូវបំបែកដែលត្រូវធ្វើការជ្រើសរើសនៅក្នុងមាគារនៃកិច្ចការអភិវឌ្ឍន៍របស់ខ្លួន នៅពេលដែលប្រទេសងាកចេញពីស្ថានភាពក្រោយវិវាទ ឆ្ពោះទៅកាន់គំរូអភិវឌ្ឍន៍កាន់តែប្រក្រតីវិញ។ ភាពឯកកោលើផ្ទៃអន្តរជាតិនិងវិវាទជាងពីរទសវត្សរ៍ដែល បានបញ្ចប់ក្នុងឆ្នាំ ១៩៩១ បានបំផ្លាញយ៉ាងច្រើននូវទុនរូបវ័ន្ត សង្គមនិងមនុស្សនៃប្រទេស ដែលបង្ខំឱ្យកម្ពុជា ចាប់ផ្តើមពីបាតដៃទទេក្នុងការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធនិងស្ថាប័នរបស់ខ្លួន។ ថ្វីបើសមិទ្ធផលខាងសង្គមកិច្ចនិងសេដ្ឋកិច្ចដ៏សំខាន់ៗត្រូវបានសំរេចក្នុងទសវត្សរ៍កន្លងមកនេះក្តី ក៏របៀបវារៈអភិវឌ្ឍន៍នៅតែមាន លក្ខណៈលំបាកខ្លាំង។ ភាពក្រីក្រនៅតែ មានពាសពេញនិងច្រើន ដោយមានប្រជាជន ៣៥%-៤០% នៅតែស្ថិតនៅ ក្រោមបន្ទាត់ភាពក្រីក្រ ហើយវិសមភាពហាក់បីដូចជាកំពុងកើនឡើង។ កំណើនសេដ្ឋកិច្ចថ្មីៗនេះ ពុំបាននាំឱ្យមានការកាត់បន្ថយភាពក្រីក្រជាដុំកំភួនឡើយ ហើយការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ជាច្រើន (MDGs) នឹងមានលក្ខណៈលំបាក។ ចំណោទនៃការកាត់បន្ថយភាពក្រីក្រ នឹងមានលក្ខណៈកាន់តែលំបាកថែមទៀត ចំពោះមុខនៃការធ្លាក់ចុះខ្លាំង ដែលគេរំពឹងថានឹងកើតឡើងចំពោះសេដ្ឋកិច្ច ដែលបណ្តាលមកពីការលុបចោលកិច្ចព្រមព្រៀងពហុវាយនភ័ណ្ឌ នៅចុងឆ្នាំ ២០០៤។

ដោយមានការបង្កើតដោយសន្តិភាពនូវរដ្ឋាភិបាលចំរុះមួយនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ រាជរដ្ឋាភិបាលបានចាត់វិធានការយ៉ាងលឿនដើម្បីច្បាមយករបៀបវារៈកំណែទម្រង់ ដោយដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធិភាព ដើម្បីកំណត់ទិសដៅការអនុវត្តន៍របៀបវារៈសេដ្ឋកិច្ចក្នុងរយៈពេលនៅសល់នៃអាណត្តិរបស់ខ្លួន។ រាជរដ្ឋាភិបាល បានបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការដោះស្រាយបញ្ហាអភិបាលកិច្ចដែលចាក់ឫសយ៉ាងជ្រៅហើយដែលបានរារាំងកិច្ចអភិវឌ្ឍន៍ និងវឌ្ឍនភាពសង្គមអស់រយៈពេលដ៏យូរមកហើយ និងបានផ្តួចផ្តើមផងដែរនូវវិធានការមួយចំនួនដើម្បីដោះស្រាយឧបសគ្គខាងរចនាសម្ព័ន្ធខ្លះៗចំពោះកំណើន។

យុទ្ធសាស្ត្រចតុកោណ ដែលដាក់ចេញនូវរបៀបវារៈកំណែទម្រង់របស់រាជរដ្ឋាភិបាលក្នុងរូបភាពជាចតុកោណកែងជាប់ទាក់ទងគ្នា កំណត់អភិបាលកិច្ចជាស្នូលនៃយុទ្ធសាស្ត្រ។ ចតុកោណកែងដទៃទៀតយកចិត្តទុកដាក់លើបរិស្ថានដែលគេចង់បានដើម្បីអនុវត្តយុទ្ធសាស្ត្រ និង លើការជម្រុញកំណើនសេដ្ឋកិច្ចតាមរយៈវិស័យកសិកម្ម ហេដ្ឋារចនា-សម្ព័ន្ធ កំណើនវិស័យឯកជននិងនិយោជន៍ និង កិច្ចអភិវឌ្ឍន៍ធនធានមនុស្ស។ បច្ចុប្បន្ន រាជរដ្ឋាភិបាលកំពុងរៀបចំផែនការសកម្មភាពដើម្បីអនុវត្តយុទ្ធសាស្ត្រនេះ ដែលនឹងក្លាយទៅជាមូលដ្ឋានសម្រាប់ថវិកា ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និង កម្មវិធីវិនិយោគសាធារណៈ។

ដោយសារមូលដ្ឋានចំណូលក្នុងស្រុកដ៏ទាបយ៉ាងខ្លាំង ជំនួយពីខាងក្រៅ បាននឹងបន្តជាប្រភពហិរញ្ញវត្ថុដ៏លើសលុបសម្រាប់កម្មវិធីវិនិយោគសាធារណៈ។ ក្នុងន័យនេះ រាជរដ្ឋាភិបាល បានកំណត់ជាអាទិភាពនូវសមត្ថភាពនិងប្រសិទ្ធិភាពរបស់ខ្លួនក្នុងការគ្រប់គ្រងជំនួយ និង លើការកែលំអការសម្របសម្រួលជំនួយពីក្រៅ។ ប្រទេសកម្ពុជាកំពុងត្រៀមខ្លួនដើម្បីអនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងរ៉ូមស្តីពីសុខដុមនីយកម្ម។ តាមសំណើរបស់រាជរដ្ឋាភិបាល ក្រុមការងារបច្ចេកទេសរាជរដ្ឋាភិបាល-អ្នកផ្តល់ជំនួយ (TWG) ត្រូវបានរៀបចំឡើងវិញ ដើម្បីលើកកំពស់ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និង ផ្តល់នូវមូលដ្ឋានសម្រាប់ការគ្រប់គ្រងកាន់តែមានប្រសិទ្ធិភាពលើជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) នៅក្នុងវិស័យជាអាទិភាពនិងផ្នែកជាប្រធានបទចំនួន ១៧។ គឺនៅក្នុងបរិបទនៃដំណើរការកំណែទម្រង់របស់រាជរដ្ឋាភិបាល និង បញ្ហាប្រឈមពិភពលោកដែលទើបតែលេចឡើងនេះឯងហើយ ដែលយុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេសនេះ (CSP) ត្រូវបានរៀបចំឡើង។

គោលដៅចំបងរបស់ ADB នៅក្នុងប្រទេសកម្ពុជា គឺការកាត់បន្ថយភាពក្រីក្រប្រកបដោយចីរភាព។ ស្របគ្នានឹងអាទិភាពនិងយុទ្ធសាស្ត្រទាំងឡាយដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល CSP នឹងផ្តោតការយកចិត្តទុកដាក់លើសសរទ្រូងជាយុទ្ធសាស្ត្រចំនួន ៣: (១) កំណើនសេដ្ឋកិច្ចប្រកបដោយមូលដ្ឋានទូលាយតាមរយៈវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត កិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការគាំទ្រចំពោះសមាហរណកម្មតំបន់កាន់តែទូលាយ កិច្ចអភិវឌ្ឍន៍ប្រកបដោយចេរភាពនូវសហគ្រាសធុនតូចនិងមធ្យម និង វិនិយោគលើវិស័យកសិកម្មនិងប្រព័ន្ធស្រោចស្រព (២) កិច្ចអភិវឌ្ឍន៍សង្គមទូលាយតាមរយៈការអប់រំជាមូលដ្ឋាន ការផ្តល់អំណាចដល់ក្រុមងាយរងគ្រោះ ដូចជាស្ត្រីនិងជនជាតិភាគតិច ការទប់ស្កាត់ជម្ងឺឆ្លង ការផ្តល់ទឹកនិងបរិក្ខារអនាម័យនៅជនបទ និង ការគ្រប់គ្រងប្រកបដោយចេរភាពផ្អែកលើសហគមន៍ និង ការការពារធនធានធម្មជាតិនៅក្នុងអាងទន្លេសាប និង (៣) អភិបាលកិច្ចល្អ តាមរយៈការកែលំអការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដើម្បីលើកកំពស់ប្រសិទ្ធិភាពអភិវឌ្ឍន៍នៃចំណាយសាធារណៈ និង គំនិតផ្តួចផ្តើមវិមជ្ឈការនិងវិសហមជ្ឈការដើម្បីពង្រឹងការចូលរួមរបស់មូលដ្ឋានក្នុងរដ្ឋាភិបាល និង កែលំអការផ្តល់សេវាកម្មសាធារណៈ ។ តំបន់ទន្លេសាបដែលមានភាពរសើបបំផុតក្នុងផ្នែកបរិស្ថាន និងជាតំបន់ដែលសំបូរអ្នកក្របំផុតរស់នៅត្រូវបានទទួលការយកចិត្តទុកដាក់ជាពិសេស។ កម្មវិធីយុទ្ធសាស្ត្រប្រចាំប្រទេស ក៏ត្រូវរៀបចំឡើងដើម្បីទទួល បាននូវអត្ថប្រយោជន៍ពីកាលានុវត្តភាពដ៏ទូលាយដែលត្រូវបានផ្តល់ដោយកម្មវិធីមហាអនុតំបន់មេគង្គ (GMS) របស់ ADB។ ប្រធានបទអន្តរវិស័យចំនួនបួន ពោលគឺ អភិបាលកិច្ច កិច្ចអភិវឌ្ឍន៍វិស័យឯកជន យេនឌ័រ និង បរិស្ថាន ក៏ត្រូវបានស្នើឡើងផងដែរដើម្បីគាំទ្រដល់គោលដៅកាត់បន្ថយភាពក្រីក្រនៃយុទ្ធសាស្ត្រចតុកោណ។

អន្តរាគមន៍តាមវិស័យនៅដែលជាសសរទ្រូងជាយុទ្ធសាស្ត្រដែលទាក់ទិនគ្នានិងដែលពង្រឹងគ្នាទៅវិញទៅមកទាំងបីនេះគឺផ្អែកលើ: ការកំណត់អាទិភាពទាំងឡាយ ដែលផ្អែកលើការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធទាំងអស់,

ឧត្តមភាពប្រៀបធៀបរបស់ ADB, ការវាយតម្លៃដ៏ប្រាកដប្រជាលើការប្ដេជ្ញារបស់រាជរដ្ឋាភិបាលចំពោះកំណែទម្រង់ និង លទ្ធភាពអន្តរាគមន៍ដោយដៃគូអភិវឌ្ឍន៍ដទៃទៀតនៅក្នុងវិស័យជាក់លាក់ទាំងឡាយ។ អន្តរាគមន៍តាមវិស័យទាំងនេះ ក៏នឹងគិតគូរផងដែរអំពីឧបសគ្គក្នុងការកាត់បន្ថយភាពក្រីក្រនៅក្នុងប្រទេសកម្ពុជា។ ADB គឺជាអ្នកត្រួសត្រាយផ្លូវនៃអភិក្រមទូទាំងវិស័យ (SWAps) នៅកម្ពុជា ហើយនឹងយកបទពិសោធន៍របស់ខ្លួនទៅប្រើប្រាស់ក្នុងការអនុវត្តន៍ជាជម្រើសនូវ SWAps ឬ អភិក្រមផ្អែកលើកម្មវិធីផ្តល់ជំនួយដោយផ្អែកលើលទ្ធផលប្រតិបត្តិការ (PBAs) នៅក្នុងកម្មវិធីជំនួយ អនាគតដើម្បីកែលំអរនៃជំនួយពីក្រៅ កាត់បន្ថយចំណាយប្រតិបត្តិការ និង ធានាឱ្យបាននូវ សង្គតភាពខាងគោលនយោបាយក្នុងចំណោមអន្តរាគមន៍ទាំងឡាយរបស់ដៃគូអភិវឌ្ឍន៍ផ្សេងៗគ្នា។ នៅទីណា ដែល SWAps ឬ PBAs មិនអាចធ្វើទៅបាន ADB នឹងបន្តស្វែងរកហិរញ្ញប្បទានឱ្យដល់អន្តរាគមន៍ដោយ-ឡែកទាំងឡាយដើម្បីបង្កើនការកៀងគរធនធានក្នុងល័ក្ខខ័ណ្ឌអនុគ្រោះបំផុត។

CSP ត្រូវបានរៀបចំឡើងដោយផ្អែកលើការពិគ្រោះយោបល់យ៉ាងទូលាយជាមួយរាជរដ្ឋាភិបាល អ្នកផ្តល់ជំនួយ សង្គមស៊ីវិល និង វិស័យឯកជន។ ជាពិសេស ADB ធនាគារពិភពលោក និង ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស (DFID) បានរៀបចំយុទ្ធសាស្ត្រប្រចាំប្រទេសកម្ពុជារបស់ខ្លួនក្នុងកិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលគ្នាដ៏ជិតស្និទ្ធដែលមិនដែលមានពីមុនមក។ ដោយធ្វើការងាររួមគ្នា ដៃគូអភិវឌ្ឍន៍ទាំងនេះសង្ឃឹមថានឹងមានការយល់គ្នាកាន់តែប្រសើរឡើង មានគោលទស្សនៈរួមចំពោះការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា និងសំដៅអោយមានការឆ្លើយតបក្នុងលក្ខណៈសម្របសម្រួលគ្នាមួយ។ ដំណើរការនេះបាននាំឱ្យមានការវាយតម្លៃរួមមួយលើនិន្នាការ និងបញ្ហានៃកិច្ចអភិវឌ្ឍន៍យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល និងហានិភ័យចំពោះការអនុវត្តន៍យុទ្ធសាស្ត្រ នោះ (ជំពូក ១-២ និង ផ្នែកខ្លះនៃជំពូក ៦ នៃ CSP)។ គេបានឯកភាពគ្នាថាអត្ថបទនៃឯកសារយុទ្ធសាស្ត្រ របស់ស្ថាប័នទាំងបីនេះ បញ្ចូលនូវការវាយតំលៃជារួមលើវិស័យទាំងនេះ។ ADB, DFID និង ធនាគារពិភពលោក ក៏បានឯកភាពគ្នាផងដែរលើក្របខ័ណ្ឌនៃការទទួលខុសត្រូវទូទៅខាងស្ថាប័នលើវិស័យជាមុខព្រួញនិងលទ្ធផល។ ភាពជាដៃគូរវាងភាគីទាំងបីនេះ គឺមិនមានលក្ខណៈជាក្រុមចង្អៀតចង្អល់ឡើយ ផ្ទុយទៅវិញ វាជាចំណែកនៃកិច្ចប្រឹងប្រែងដើម្បីបង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀត ទាំងនៅក្នុងកម្រិតយុទ្ធសាស្ត្រនិងទាំងក្នុងកម្រិតប្រតិបត្តិការ (ឧទាហរណ៍ ស្ថាប័នអង្គការ សហប្រជាជាតិ (UN) ទាំងឡាយបានចូលរួមក្នុងក្នុងដំណើរការយុទ្ធសាស្ត្រនៃស្ថាប័នទាំងបីនេះ និងបានប្រើការ វាយតម្លៃរួមនេះសម្រាប់ដំណើរការក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDAF) របស់ខ្លួន)។ ប្រការនេះ បាននាំឱ្យមានអន្តរាគមន៍ដែលមានការសម្របសម្រួលគ្នាកាន់តែប្រសើរឡើង ដែលជៀសវាងបាននូវភាពត្រួតគ្នានៃកម្មវិធីវិនិយោគ និងឱវាទគោលនយោបាយផ្ទុយគ្នា។ ADB ក៏នឹងពង្រឹងផងដែរនូវការចូលរួមរបស់ សង្គមស៊ីវិលក្នុងប្រតិបត្តិការរបស់ខ្លួននៅកម្ពុជា។

ចំពោះការត្រួតពិនិត្យលើឥទ្ធិពលដែលជាលទ្ធផលនៃកិច្ចអន្តរាគមន៍ដោយ ADB នឹងគាំទ្រយ៉ាងសកម្មដល់ក្រុមការងារប្រចាំផ្នែកនីមួយៗ (TWGs) ដែលបានរៀបចំផែនការសកម្មភាព និងសូចនាករត្រួតពិនិត្យសម្រាប់ការត្រួតពិនិត្យរួមក្នុងបណ្តាឆ្នាំខាងមុខនេះ។ ផែនការសកម្មភាព និង សូចនាករទាំងនេះ ត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំក្រុមពិគ្រោះយោបល់មួយនាពេលថ្មីៗនេះ។ ការត្រួតពិនិត្យ CSP នឹងត្រូវបានពង្រឹតដោយតារាងលទ្ធផលមួយដែលនឹងត្រូវបានធ្វើឱ្យមានបច្ចុប្បន្នភាព និង កែលំអនៅក្នុងយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសនៅពេលក្រោយ។

# ១. និន្នាការនិងបញ្ហានៃកិច្ចអភិវឌ្ឍន៍បច្ចុប្បន្ន

## ក. បរិបទអភិវឌ្ឍន៍

១. ប្រទេសកម្ពុជាគឺស្ថិតនៅលើផ្លូវបំបែកដែលត្រូវធ្វើការជ្រើសរើសនៅក្នុងកិច្ចអភិវឌ្ឍន៍របស់ខ្លួន នៅពេលដែលប្រទេសនេះកំពុងងាកចេញពី ស្ថានភាពក្រោយវិវាទ ឆ្ពោះទៅកាន់គំរូអភិវឌ្ឍន៍កាន់តែប្រក្រតីវិញ។ ភាពឯកកោរលើឆាកអន្តរជាតិ និងវិវាទជាងពីរទសវត្សរ៍ដែលបានបញ្ចប់ក្នុងឆ្នាំ ១៩៩១ ដោយមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស បានបំផ្លាញយ៉ាងច្រើននូវទុនរូបវ័ន្ត សង្គម និងធនធានមនុស្ស ដែលបង្ខំឱ្យកម្ពុជាចាប់ផ្ដើមពីបាតដៃទទេក្នុង ការកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធនិងស្ថាប័នរបស់ខ្លួន។

២. មានសមិទ្ធផលជាច្រើនដែលបានសំរេចក្នុងបណ្ដាឆ្នាំថ្មីៗកន្លងមកនេះ។ ប្រទេសកម្ពុជា សម្រេចបាននូវវឌ្ឍនភាពដ៏សំខាន់ក្នុងការធានាសន្តិភាពនិងសន្តិសុខ ការកសាងស្ថាប័នឡើងវិញ ការបង្កើតបរិស្ថានម៉ាក្រូសេដ្ឋកិច្ចមាំមួន និងដាក់ឱ្យអនុវត្តនូវរបបវិនិយោគសេរីមួយ។ ទន្ទឹមនឹងសមិទ្ធផលទាំងនេះរបៀបវារៈអភិវឌ្ឍន៍ នៅតែមានឧបសគ្គធំៗជាច្រើន។ ភាពក្រីក្រនៅតែមានពាសពេញនិងមានបរិមាណលើសលុប ដោយមានប្រជាជន ៣៥%-៤០% នៅក្រោមបន្ទាត់ភាពក្រីក្រ ហើយវិសមភាពហាក់បីដូចជាកំពុងកើនឡើង។ កំណើនសេដ្ឋកិច្ចថ្មីៗកន្លងមកនេះ មានមូលដ្ឋានចង្អៀត និង ពុំបាននាំឱ្យមានការកាត់បន្ថយភាពក្រីក្រជាដុំកំភួនឡើយ។ គេសង្ឃឹមថាការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាជាច្រើន (MDGs) នឹងជួបការលំបាកជាមិនខានឡើយ។

៣. ដោយមានសន្តិភាពនិងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចកាន់តែចាក់ឫសយ៉ាងមាំនាបច្ចុប្បន្ននេះ កម្ពុជាមានឱកាសធ្វើកំណែទម្រង់សេដ្ឋកិច្ចដ៏ទូលំទូលាយ ដើម្បីសម្រេចបាននូវកិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ប្រកបដោយចេរភាព។ ក្នុងបរិបទនេះ រាជរដ្ឋាភិបាលបានរៀបចំរបៀបវារៈកំណែទម្រង់ដ៏ទូលំទូលាយមួយដើម្បីសម្រេចបាននូវ MDGs របស់កម្ពុជា។ ប្រការនេះត្រូវបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចទីពីរ (SEDP II) ឆ្នាំ ២០០១-២០០៥ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (NPRS) ឆ្នាំ ២០០៣-២០០៥ និង យុទ្ធសាស្ត្រចតុកោណដើម្បីកំណើន និយោជន៍ សមធម៌ និង ប្រសិទ្ធិភាព។

## ខ. កំណើនសេដ្ឋកិច្ច

៤. ដោយឆ្លុះបញ្ចាំងគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដ៏ប្រុងប្រយ័ត្ន លំហូរចូលជំនួយដ៏ច្រើន និង ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មឧភតោភាគីជាមួយសហរដ្ឋអាមេរិកក្នុងឆ្នាំ ១៩៩៦ ផលិតផលក្នុងស្រុកសរុប (GDP) របស់កម្ពុជាបានកើនឡើងជាមធ្យម ៦,៨% ក្នុងមួយឆ្នាំ ពីឆ្នាំ ១៩៩៩ ដល់ ឆ្នាំ ២០០២ ប្រៀប-ធៀបនឹង ៥,៦% ក្នុងមួយឆ្នាំ ពីឆ្នាំ ១៩៩៥ ដល់ ឆ្នាំ ១៩៩៨។ ប៉ុន្តែ កំណើន GDP បានធ្លាក់ចុះចាប់តាំងពីឡើងដល់កម្រិតកំពូល ១០,៨% របស់វាក្នុងឆ្នាំ ១៩៩៩ ហើយតួលេខ GDP សម្រាប់ឆ្នាំ ២០០៣ គឺ ៥,២%។ កំណើនក្នុងឆ្នាំ ២០០៣ ត្រូវបានបន្ថយបង្អាក់ដោយការកើតមានឡើងនៃជម្ងឺផ្លូវដង្ហើមធ្ងន់ធ្ងរ (SARS) និង ការបះបោរប្រឆាំងប្រទេសថៃដែលមានផលប៉ះពាល់ជាអវិជ្ជមានលើវិស័យទេសចរណ៍។ ប្រការដែលត្រូវចំណាយពេល ១ ឆ្នាំដើម្បីបង្កើតរដ្ឋាភិបាលថ្មី មួយក្រោយការបោះឆ្នោតក្នុងខែ កក្កដា ឆ្នាំ ២០០៣ ក៏បានធ្វើឱ្យខូចខាតដល់ទំនុកចិត្តអាជីវកម្មផងដែរ។ រីឯចំណុចជាវិជ្ជមានវិញ ផលិតកម្មកសិកម្មបានងើបឡើងវិញយ៉ាងរឹងមាំបន្ទាប់ពីការធ្លាក់ចុះដោយសារគ្រោះរាំងស្ងួតក្នុងឆ្នាំ២០០២ ហើយឧស្សាហកម្មសំលៀកបំពាក់សំដៅការនាំចេញបានពង្រីកយ៉ាងខ្លាំង។ ក្នុងទសវត្សរ៍កន្លងមកនេះ វិស័យឧស្សាហកម្មគឺជាក្បាលម៉ាស៊ីនចំបងនៃកំណើន ដោយមានចំណែកនៃឧស្សាហកម្មក្នុង GDP កើនឡើងពី ១៣% ក្នុងឆ្នាំ ១៩៩២ ដល់ ២៦% ក្នុងឆ្នាំ ២០០៣ ហើយចំណែកនៃវិស័យកសិកម្មធ្លាក់ចុះ ពី ៤៨% ដល់ ៣៤% ក្នុងអំឡុងពេលនេះ។ អនុវិស័យកម្មន្តសាលគឺជាកត្តារួមចំណែកដ៏ធំបំផុតចំពោះកំណើន GDP ដោយមានវិស័យសំលៀកបំពាក់គឺជាកត្តានាំមុខជាគន្លឹះនៃកំណើននេះ។ វិស័យទេសចរណ៍ក៏បានរួមចំណែកយ៉ាងច្រើនផងដែរដល់កំណើន ខណៈដែលវិស័យកសិកម្មបានកើនឡើងបន្តិចបន្តួច ប៉ុន្តែតាមមិនទាន់កំណើនប្រជាជន។ ការប្រមើលមើលកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ ២០០៤ គឺមានលក្ខណៈមិនសូវល្អ ដោយសារលទ្ធភាពទន់ខ្សោយនៃវិស័យកសិកម្ម និង គេឃើញមានការបារម្ភអំពីការបង្អង់ល្បឿនដ៏ខ្លាំងក្នុងឆ្នាំ ២០០៥ ក្រោយពេលចប់កិច្ចព្រមព្រៀងពហុវាយនភ័ណ្ឌ (MFA) នៅចុងឆ្នាំ ២០០៤។

៥. ដោយសារសេដ្ឋកិច្ចកម្ពុជានៅតែមានលក្ខណៈដុល្លារូបនីយកម្មយ៉ាងខ្ពស់ អាជ្ញាធរពុំសូវមានលទ្ធភាពប្រើឧបករណ៍ដែលជាទម្លាប់ពីដើមរៀងមកក្នុងការគ្រប់គ្រងរូបិយវត្ថុទេ។ អាស្រ័យហេតុនេះ គោលនយោបាយសារពើពន្ធដ៏ប្រុងប្រយ័ត្ន បានដើរតួនាទីជាគន្លឹះដើម្បីធានាស្ថេរភាពតម្លៃ ហើយប្រទេសកម្ពុជាសម្រេចបានអត្រាអតិផរណាក្រោម ៤% តាំងពីឆ្នាំ ១៩៩៩ មក។ ប៉ុន្តែ ដោយតម្រូវការប្រាក់រៀលបន្តកើនឡើងជាមួយនឹងកំណើនសេដ្ឋកិច្ច ថ្មីៗនេះអាជ្ញាធរបានធ្វើអន្តរាគមន៍នៅក្នុងទីផ្សារប្តូររូបិយប័ណ្ណដើម្បីធ្វើឱ្យមានស្ថេរភាពដល់អត្រាប្តូរប្រាក់។ ជាលទ្ធផល អត្រាប្តូរប្រាក់នៅតែមានស្ថេរភាពយ៉ាងជាទូទៅក្នុងអត្រាប្រហែល ៤.០០០ រៀល ក្នុងមួយដុល្លារអាមេរិក ក្នុងឆ្នាំ ២០០៣ ជាមួយនឹងអតិផរណាជាមធ្យមត្រឹមតែ ១,២% ប៉ុណ្ណោះ។ ប៉ុន្តែ ការងាររកប្រាក់

ចំណូលរដ្ឋាភិបាលក្នុងឆ្នាំ ២០០៣ បានចុះខ្សោយដោយសារមានការធ្លាក់ចុះនៅក្នុងពាណិជ្ជកម្មនិងអាករពិសេស ទោះបីជាមានកិច្ចប្រឹងប្រែងថ្មីៗក្នុងការ កែលំអការគ្រប់គ្រងរដ្ឋបាលពន្ធនិងការប្រមូលពន្ធដារក្តី។ ការធ្លាក់ចុះនៃចំណូលបានបង្កើនឱនភាពសារពើពន្ធទូទៅដល់ ៧% នៃ GDP ក្នុងឆ្នាំ ២០០៣ ពី ៦,៧% ក្នុងឆ្នាំ ២០០២ និង បានកាត់បន្ថយចំណាយលើវិស័យជាអាទិភាពដូចជាសុខាភិបាល អប់រំ អភិវឌ្ឍន៍ជនបទ និង កសិកម្ម។ ដូចក្នុងបណ្តាឆ្នាំថ្មីៗនេះដែរ លំហូរចូលជំនួយជាច្រើនបានជួយផ្តល់ហិរញ្ញប្បទានដល់ឱនភាព។ ត្បិតឱនភាពពាណិជ្ជកម្មបានថយចុះល្មមក្តី ក៏ឱនភាពគណនីចរន្ត (មិនរាប់បញ្ចូលការបង្វែរផ្លូវការទេ) បានកើនឡើងដល់ ១០,២% នៃ GDP ក្នុងឆ្នាំ២០០៣ ពី ៩,០% ក្នុងឆ្នាំ២០០២ដែរ ដោយសារអតិរេកតិចខាងសេវាកម្មមានតិចជាងព្រោះចំណូលពីវិស័យទេសចរណ៍បានថយចុះ។ ឱនភាពនេះត្រូវបានផ្តល់ហិរញ្ញប្បទានតាមរយៈការបង្វែរឯកជននិងផ្លូវការ និង ទុនរូបិយវត្ថុបរទេសបំរុង ដែលរួមមានវិនិយោគបរទេសផ្ទាល់ (FDI) ប្រហែល ៧៧ លានដុល្លារ។ រូបិយវត្ថុបរទេសបំរុងគឺមានចំនួន ៧៣៧ លានដុល្លារនៅដំណាច់ឆ្នាំ ២០០៣ និង មានចំនួនគ្រប់គ្រាន់ដើម្បីចំណាយលើការនាំចូលបានជិត ៣ ខែ។ បំណុលសរុបនៅដំណាច់ឆ្នាំ ២០០៣ ត្រូវបានប៉ាន់ស្មានថាមានចំនួន ៧០,៨% នៃ GDP។ បំណុលរបស់កម្ពុជាដែលជំពាក់សហរដ្ឋអាមេរិកនិងសហព័ន្ធរុស្ស៊ី កំពុងត្រូវបានចរចារ ហើយបច្ចុប្បន្ននេះមិនត្រូវបានបង់សងដើមនិងការប្រាក់ឡើយ។ ហេតុនេះ អនុបាតទូទាត់បំណុលធៀបទៅនឹងការនាំចេញទំនិញនិងសេវានៅដំណាច់ ឆ្នាំ២០០៣ គឺ មានចំនួនតែ ២,៩% ប៉ុណ្ណោះ។ ប៉ុន្តែ អនុបាតទូទាត់បំណុលធៀបទៅនឹងចំណូលរដ្ឋាភិបាល គឺមានចំនួន ១៤,៨% ជាហេតុនាំឱ្យគេដាក់ប្រទេសកម្ពុជានៅក្នុងប្រភេទប្រទេសជំពាក់បំណុលគួរឱ្យបារម្ភ។

៦. ប្រទេសកម្ពុជាត្រូវតែដោះស្រាយឧបសគ្គខាងរចនាសម្ព័ន្ធមួយចំនួនចំពោះកំណើនសេដ្ឋកិច្ច។ ប្រភពកំណើនមានស្រាប់ គឺពឹងផ្អែកយ៉ាងខ្លាំងលើវិស័យសំលៀកបំពាក់និងទេសចរណ៍។ ប៉ុន្តែ អនាគតនៃវិស័យសំលៀកបំពាក់គឺមានលក្ខណៈមិនប្រាកដប្រជាឡើយ ក្រោយពីការបញ្ចប់ MFA។ គេត្រូវតែពឹងផ្អែកលើប្រភពកំណើនថ្មីដើម្បីសម្រេចឱ្យបាននូវគោលដៅកំណើន ៦-៧% នៅក្នុងយុទ្ធសាស្ត្រចតុកោណ និង រកការងារឱ្យមនុស្សប្រហែលជា ២៥០.០០០ នាក់ដែលចូលក្នុងទីផ្សារពលកម្មរៀងរាល់ឆ្នាំ។ ដោយសារប្រជាជនក្រីក្រចំនួន ៩០% រស់នៅនៅតំបន់ជនបទ ការជម្រុញវិស័យកសិកម្មគឺជាមធ្យោបាយដ៏ប្រសើរបំផុតសម្រាប់បង្កើនល្បឿនកំណើន ក្នុងការស្រូបយកកម្លាំងពលកម្មអោយកាន់តែកើនឡើងបានមួយចំណែកធំ និង ដោះស្រាយភាពក្រីក្រ ដោយផ្ទាល់។ ប៉ុន្តែ កសិផលិតកម្ម នៅតែស្ថិតនៅទាបជាងសក្តានុពលច្រើន ដោយសារផលិតភាពដ៏ទាប និង លទ្ធភាពដ៏មានកម្រិតចំពោះការមានដីអាចដាំដំណាំបាន និង ចំពោះការចូលទៅកាន់ទីផ្សារ។ ប្រភពកំណើនថ្មីឬប្រភពកំណើនប្រកបដោយពិពិធកម្ម នឹងតម្រូវឱ្យមានអត្រាដ៏ខ្ពស់ច្រើននៃផលិតភាព និងវិនិយោគ។ ប៉ុន្តែ ក្តីសង្ឃឹមលើកំណើនច្រើននៅក្នុងវិនិយោគសាធារណៈ គឺមានកម្រិត ដោយសារតែមូលដ្ឋានចំណូលរដ្ឋាភិបាលទាប។ ម្យ៉ាងទៀត

វិនិយោគឯកជនត្រូវបានរារាំងដោយការលំបាក ខាងហេដ្ឋារចនាសម្ព័ន្ធ (ជាពិសេស នៅក្នុងវិស័យថាមពលនិងដឹកជញ្ជូន) ប្រព័ន្ធហិរញ្ញវត្ថុទន់ខ្សោយនិងមិនទាន់ស៊ីជម្រៅ កង្វះពលកម្មជំនាញ និង ភាពទន់ខ្សោយនៅក្នុងអភិបាលកិច្ចតិតចាប់ ពីបរិយាកាសគោលនយោបាយ ក៏ដូចជាបទប្បញ្ញត្តិទន់ខ្សោយ និង ការផ្តល់សេវាកម្មអន់រហូតដល់អប្រសិទ្ធិភាពនៃការិយាធិបតេយ្យ និងអំពើពុករលួយដែលមានពាសពេញ។ ប្រការទាំងអស់នេះនាំឱ្យបង្កើនចំណាយប្រតិបត្តិការយ៉ាងច្រើន និង បន្ថយទំនុកចិត្តអាជីវកម្ម ផលិតភាព និង ភាពប្រកួតប្រជែងនៃសេដ្ឋកិច្ច។ ថ្វីបើគេបានទទួលជោគជ័យនៅ ក្នុងកំណែទម្រង់រចនាសម្ព័ន្ធក្នុងទស្សវត្សរ៍កន្លងមកនេះ ជាពិសេសកំណែទម្រង់ដែលទាក់ទិននឹងពាណិជ្ជកម្ម តម្លៃ និង សេរីភាវូបនីយកម្មអត្រាប្តូរប្រាក់ កំណែទម្រង់ពន្ធដារនិងវិស័យហិរញ្ញវត្ថុ និង ឯកជនភាវូបនីយកម្មនិងការជួលសហគ្រាសរដ្ឋក្តី ក៏ស្ថានភាពគោលនយោបាយ និងស្ថាប័នខាងក្នុងស្ទើរតែគ្រប់វិស័យទាំងអស់នៃសេដ្ឋកិច្ច ចាំបាច់ត្រូវមានកំណែទម្រង់ក្នុងទ្រង់ទ្រាយធំ។ វឌ្ឍនភាពលើកំណែទម្រង់មានលក្ខណៈយឺតជាពិសេសនៅខាងកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានបង្ខំឱ្យវិស័យឯកជនត្រូវដំណើរការនៅក្រោមវិធានទីផ្សារមិនប្រាកដប្រជា។ ការពង្រឹងកិច្ចប្រឹងប្រែងគៀងគរចំណូល ក៏នឹងមានសារៈសំខាន់ផងដែរចំពោះរាជរដ្ឋាភិបាល ប្រសិនបើចង់បង្កើនចំណាយសង្គមកិច្ច និង កែលំអគុណភាពនៃសេវាសាធារណៈ។ រាជរដ្ឋាភិបាលថ្មី បានចាត់វិធានការយ៉ាងលឿនរហ័សដើម្បីដោះស្រាយបញ្ហាទាំងនេះខ្លះ ជាពិសេសដោយកាត់បន្ថយការចំណាយនិងពេលវេលា ដែលទាក់ទិននឹងនីតិវិធីនាំចូលនិងនាំចេញ និង ការចុះបញ្ជីក្រុមហ៊ុននិងក្នុងការផ្តល់សច្ចាប័នលើការចូលក្នុងអង្គការពាណិជ្ជកម្មពិភពលោក(WTO)របស់កម្ពុជា។ ថ្វីបើ អត្ថប្រយោជន៍អំពីសមាជិកភាពនៃ WTO បានដោយសារការកាន់តែតំរង់ទិសដៅទៅរករបបទីផ្សារ និងលទ្ធភាពចូលទៅទីផ្សារត្រូវគេរំពឹងថាមានលក្ខណៈទូលាយ ហើយដែលតម្រូវឱ្យមានការអនុម័តច្បាប់ជាង ៤០ ដែលទាក់ទិននឹងប្រតិបត្តិការពាណិជ្ជកម្មក្នុងបណ្តាឆ្នាំខាងមុខនេះក្តី ក៏គេចាំបាច់ត្រូវយកចិត្តទុកដាក់លើការអនុវត្តន៍ច្បាប់ទាំងនេះឱ្យបានត្រឹមត្រូវ ប្រសិនបើគេចង់ឱ្យវាក្លាយជាអត្ថប្រយោជន៍ជាក់ស្តែង។

## គ. ភាពក្រីក្រ[១]

៧. ទោះបីជាមានកង្វះខាតទិន្នន័យក្តី ក៏គេមានការឯកភាពគ្នាលើចរិតលក្ខណៈគោលនៃភាពក្រីក្រនៅកម្ពុជាដែរ។ ប្រជាជនប្រមាណជា ៣៥-៤០% មានកម្រិតចំណាយនៅក្រោមបន្ទាត់ភាពក្រីក្រប្រាក់ចំណូល ដោយមាន

[១] ការវាយតម្លៃភាពក្រីក្រថ្មីបំផុតដោយពហុដៃគូរ ត្រូវបានសង្ខេបនៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) ដែលគឺជាយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។ មុនពេលរៀបចំយុទ្ធសាស្ត្រនិងកម្មវិធី (CSP) ADB បានរៀបចំការពិនិត្យមើលស្ថានភាពនៃចំណេះដឹងអំពីភាពក្រីក្រនៅកម្ពុជា (Knowles, James. ឆ្នាំ 2003។ *ការពិនិត្យមើលភាពក្រីក្រកម្ពុជា*។ ក្រុងម៉ានីលៈ ADB.) ដើម្បីសង្ខេបរបកគំហើញនៅក្នុង NPRS និង របកគំហើញពីប្រភពដទៃទៀត។

ប្រជាជន ១៥-២០% រស់នៅក្នុងភាពក្រីក្រហួសប្រមាណ។ ភាពក្រីក្រនៅកម្ពុជាភាគច្រើនលើសលុបគឺមាននៅទីជនបទ ចាប់ពីកម្រិតទាប ១០-១៥% នៅក្រុងភ្នំពេញ ទៅដល់ ៤០-៤៥% នៅតំបន់ជនបទ និង ឈានទៅដល់ ៧០-៨០% នៅក្នុងតំបន់ខ្លះនៅជុំវិញអាងទន្លេសាប។ ទោះបីជាមានកំណើនខ្លាំងគួរសមក្នុងទស្សវត្សរ៍កន្លងមកនេះក្តី ក៏តួលេខផ្លូវការបង្ហាញថា អត្រាកើតមាននៃភាពក្រីក្របានថយចុះតែបន្តិចប៉ុណ្ណោះ ពី ៣៩% ក្នុងឆ្នាំ ១៩៩៤ មកត្រឹម ៣៦% ក្នុងឆ្នាំ ១៩៩៩។ ប្រការនេះ គឺបណ្តាលមកពីកត្តាមួយចំនួន ដែលរួមមានភាពចង្អៀតនៃប្រភពកំណើនបច្ចុប្បន្នជាមួយនឹងការផ្សារភ្ជាប់ដ៏តិចតួចទៅនឹងសេដ្ឋកិច្ចក្នុងស្រុក ការមិនដាក់បញ្ចូលជនក្រីក្រនៅក្នុងចរន្តសេដ្ឋកិច្ច គុណភាពដ៏អន់នៃសេវាកម្មសង្គមនិងកង្វះលទ្ធភាពទទួលសេវាកម្មសង្គម ការគ្មានឥណទាន កង្វះលទ្ធភាពក្នុងការប្រើប្រាស់ដីធ្លី ការប្រើប្រាស់ ធនធានព្រៃឈើ និង ធនធានជលផល និងការមិនដាក់បញ្ចូលជនក្រីក្រ (និងជាពិសេស ជនជាតិភាគតិចនិងស្ត្រី) នៅក្នុងការ ធ្វើសេចក្តីសម្រេចចិត្តដែលមានអត្ថប្រយោជន៍ចំពោះការរស់នៅរបស់ពួកគេ។

៨. ភាពប្រសើរឡើងក្នុងការកាត់បន្ថយភាពក្រីក្ររបស់ ប្រជាជនមានលក្ខណៈចម្រុះ។ គេឃើញមានភាពប្រសើរឡើងច្រើន ចំពោះការអប់រំកម្រិតបឋមសិក្សាជាសកល ដោយមានអត្រាពិតនៃការចូលរៀនកម្រិតបឋមសិក្សា កើនឡើងពី ៧៦% ក្នុងឆ្នាំ ១៩៩៧ ដល់ ៨៧% ក្នុងឆ្នាំ ២០០១។ គុណភាពនិងលទ្ធភាពក្នុងការអប់រំក៏បានរីកចំរើនផងដែរ ប៉ុន្តែគេចាំបាច់ត្រូវជំរុញអោយមានវឌ្ឍនភាពបន្ថែមទៀត។ គេនៅឃើញមានវិសមភាពជាច្រើនខាងយេនឌ័រនៅក្នុងវិស័យអប់រំ ដោយបច្ចុប្បន្ននេះមានក្មេងស្រីត្រឹមតែ ៣៩% ប៉ុណ្ណោះបានចុះឈ្មោះចូលរៀនក្នុងមធ្យមសិក្សាបឋមភូមិ និង មានអត្រាបោះបង់ការសិក្សាខ្ពស់។ ស្ថានភាពសុខភាពរបស់ប្រជាជនគឺមានលក្ខណៈទាប ដោយមានការប៉ាន់ស្មានថាមរណភាពរបស់កុមារគឺមានចំនួន ១១៥ ក្នុងកំណើតរស់ចំនួន ១.០០០ នាក់ ។ ទិន្នន័យពីឆ្នាំ ២០០០ បង្ហាញនូវអនុបាត (ratio) ដ៏ខ្ពស់នៃមរណភាពមាតាចំនួន ៤៣៧ ក្នុងកំណើតរស់ចំនួន ១០០.០០០ នាក់ ។ ការឆ្លងទន្លេប្រហែល ៨០% គឺធ្វើនៅផ្ទះ និងមានគ្រូពេទ្យ ឬអ្នកជំនាញតិចជាងពាក់កណ្តាលសំរាប់ ជួយក្នុងការឆ្លងទន្លេទាំងអស់។ ចំពោះសេវាកម្មធ្វើផែនការគ្រួសារ ពុំទាន់ មានគ្រប់គ្រាន់ នៅឡើយដែលជាហេតុនាំឱ្យអត្រាកំណើនប្រជាជនមានចំនួនប្រហែល ២.៥% ក្នុងមួយឆ្នាំដែលធ្វើអោយភាពក្រីក្រមានលក្ខណៈកាន់តែធ្ងន់ធ្ងរ និងបង្កើនសំពាធថែមទៀតលើធនធានធម្មជាតិ។ ថ្វីបើប្រទេសកម្ពុជាមានអត្រាប្រេវ៉ាឡង់មេរោគអេដស៍/ជម្ងឺអេដស៍ខ្ពស់ជាងគេបំផុតនៅអាស៊ីក្តី ក៏ប្រទេសនេះ សម្រេចបានវឌ្ឍនភាពដ៏ធំធេងដោយអត្រាប្រេវ៉ាឡង់មនុស្សពេញវ័យធ្លាក់ចុះពី ៣.៩% ក្នុងឆ្នាំ១៩៩៧ មកត្រឹម ២.៦% ក្នុងឆ្នាំ២០០២។

៩. ការសិក្សាភាពក្រីក្របង្ហាញថា វិសមភាពប្រាក់ចំណូលបានកើនឡើងជាពិសេសនៅតំបន់ជនបទ។ កំណើនកសិកម្មដ៏យឺតបានធ្វើឱ្យវិសមភាពប្រាក់ចំណូលមានលក្ខណៈកាន់តែធ្ងន់ធ្ងរ។ ទោះបីជាមានការប្តេជ្ញារបស់រាជ-រដ្ឋាភិបាលក្តី វិសមភាពក៏ត្រូវគេឃើញច្បាស់ផងដែរនៅក្នុងស្ថានភាពនៃក្រុមជនជាតិភាគតិច ជនដែលផ្លាស់

ទីលំនៅដោយសារវិវាទនិងស្ត្រី។ ការសិស្សាភាពក្រីក្រក៏បង្ហាញផងដែរថា ភាពក្រីក្រកើនឡើងតាមទំហំគ្រួសារ និងចំនួនកូន និងមានកម្រិតខ្ពស់បំផុតនៅក្នុងគ្រួសារណាដែលមានមេគ្រួសារប្រកបរបរកសិកម្ម។ គ្រួសារដែលមានមេគ្រួសារជាស្ត្រីមិនមែនក្រជាងគ្រួសារដទៃទៀតទេ ប៉ុន្តែពួកគេច្រើនតែមានលក្ខណៈងាយរងគ្រោះដោយមានដីនិងធនធានពលកម្មតិច ដោយហេតុនេះហើយ ច្រើនតែពឹងផ្អែកលើយុទ្ធសាស្ត្រដោះស្រាយដ៏ប្រថុយប្រថាន ដូចជាការលក់ដូរទ្រព្យសម្បត្តិ ឬបញ្ឈប់កូនពីសាលារៀន ហើយបញ្ជូនកូនឱ្យទៅធ្វើការ។ ការអប់រំដើរតួនាទីដ៏សំខាន់មួយក្នុងការកំណត់អត្រាភាពក្រីក្រ។ អត្រាភាពក្រីក្រគឺមានលក្ខណៈស្រដៀងគ្នានៅពេលដែលមេគ្រួសារពុំបានរៀនសូត្រ ឬបានរៀនត្រឹមកម្រិតបឋមសិក្សា និងមានលក្ខណៈទាបច្រើនជាងគ្រួសារដែលមេគ្រួសារមានការអប់រំកម្រិតមធ្យមសិក្សា បច្ចេកទេស ឬឧត្តមសិក្សា។

១០. ប្រជាជនមួយចំនួនធំក៏មានលក្ខណៈងាយរងគ្រោះជាប្រចាំផងដែរ ដោយធ្លាក់ទៅក្នុងភាពក្រីក្រ និង ងាកចេញពីភាពក្រីក្រតែបន្តិចទៅតាមកត្តាផ្លាស់ប្តូរខាងក្រៅដែលប៉ះពាល់ដល់ជីវិតពួកគេ។ ជនក្រីក្រក៏ជួបប្រទះផងដែរនូវអសន្តិសុខស្បៀងអាហារ សូម្បីតែនៅក្នុងខេត្តទាំងឡាយដែលផលិតបរិមាណអង្ករលើសសេចក្តីត្រូវការក្តី។ ការសិក្សា ភាពក្រីក្រក្នុងលក្ខណៈចូលរួមក្នុងឆ្នាំ ២០០១ ដែលឧបត្ថម្ភដោយ ADB បានបង្ហាញថា ប្រជាជនក្រីក្រយល់ថាខ្លួនគ្មានអំណាច និងមានលទ្ធភាពស្ទួចស្តើងក្នុងការទទួលដីធ្លីនិងធនធានធម្មជាតិ ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសេវាកម្មសង្គមចាំបាច់ទាំងឡាយ។[២] ជនក្រីក្រជាច្រើនក៏បាននិយាយផងដែរថា ការបាត់បង់ទំនាក់ទំនងគ្រួសារ និងសហគមន៍គឺជា ការបារម្ភចំបងមួយ និង ថា ពួកគេពុំមានជំនឿលើរដ្ឋបាលថ្នាក់មូលដ្ឋាននិងថ្នាក់ខេត្តឡើយ។ គ្រោះថ្នាក់ និងជម្ងឺតម្កាត់ត្រូវបានលើកឡើងជាញឹកញាប់ថា គឺជាមូលហេតុនាំមុខនៃភាពងាយរងគ្រោះនិងភាពក្រីក្រ។ គ្រួសារចំណាយប្រាក់ចំណូលមួយចំណែកធំលើការថែទាំសុខភាព គ្រោះថ្នាក់ ឬ ជម្ងឺផ្សេងៗដែលជាវិនាសកម្មខាងហិរញ្ញវត្ថុ។[៣]

១១. ***វឌ្ឍនភាពឆ្ពោះទៅកាន់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៏កម្ពុជា*** - ថ្វីបើកម្ពុជាសម្រេចបាននូវគោលដៅអភិវឌ្ឍន៏សហស្សវត្សរ៍ខ្លះៗរបស់ខ្លួនក្តី (MDGs) ក៏ការសម្រេចបានគោលដៅទាំងអស់នេះនឹងជួបប្រទះការលំបាក។ ប្រទេសកម្ពុជាទំនងជាអាចនឹងបំពេញបាននូវចំណុចដៅ MDG របស់ខ្លួនលើការអប់រំកម្រិតបឋមសិក្សាជាសកល ប៉ុន្តែការសម្រេចបាននូវចំណុចដៅនៃការអប់រំមធ្យមសិក្សា (រួមទាំងការចូលរៀនរបស់ក្មេងស្រី) ទំនងជាមិនអាចទៅរួច។ គេក៏ឃើញមានវឌ្ឍនភាពខ្លះដែរចំពោះការសម្រេចបាននូវគោលដៅ

---

[២] ADB។ ឆ្នាំ ២០០១ ។ *ការវាយតម្លៃភាពក្រីក្រកម្ពុជាក្នុងលក្ខណៈចូលរួម* ។ ម៉ានីល។ ធនាគារពិភពលោកនិង ADB កំពុងធ្វើការវាយតម្លៃភាពក្រីក្រលក្ខណៈចូលរួមឱ្យបានទាន់សម័យ។

[៣] យុទ្ធសាស្ត្រទ្រទ្រង់វិស័យសុខាភិបាល ឆ្នាំ ២០០២-២០០៧ ប៉ាន់ស្មានថាគ្រួសារចំណាយប្រាក់ចំណូលរបស់ខ្លួនជាមធ្យមចំនួន ១២% លើការថែទាំសុខភាព។

ដែលទាក់ទិននឹងវិស័យសុខាភិបាល ប៉ុន្តែក្នុងអត្រាវឌ្ឍនភាពបច្ចុប្បន្ន ប្រហែលជាមិនគ្រប់គ្រាន់ទេដើម្បីសម្រេចបាននូវគោលដៅ MDGs ។ ប៉ុន្តែ កម្ពុជាទំនងជានឹងសម្រេចបាននូវគោលដៅ MDG របស់ខ្លួនក្នុងការកាត់បន្ថយអត្រាប្រេវ៉ាឡង់មេរោគអេដស៍ មុនដំណាច់ឆ្នាំ ២០១៥ ថ្វីបើរបៀប ឆ្លងមេរោគអេដស៍កំពុងប្រែប្រួលដោយមានករណីឆ្លងថ្មីភាគច្រើនបំផុត កើតឡើងក្នុងចំណោមស្ត្រីមានគ្រួសារ និងកូនរបស់ពួកគេដែលជាក្រុមពិបាកនឹងជួយ ។ ការសម្រេចបាននូវចំណុចគោលដៅ MDG ក្នុងការកាត់បន្ថយឱ្យបានពាក់កណ្តាលនូវចំនួនប្រជាជននៅក្រោមបន្ទាត់ភាពក្រីក្រជាតិ អោយបាននៅដំណាច់ឆ្នាំ ២០១៥ តម្រូវឱ្យមានកំណើនសេដ្ឋកិច្ចលឿនជាងច្រើន និង ការកំណត់ទិសដៅដែលកាន់តែជួយ ដល់ជនក្រីក្រសំរាប់ ទទួលនូវផ្លែផ្កានៃកំណើននោះ ។

## ឃ. បរិស្ថាននយោបាយ

១២. កិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស កាលពីខែ តុលា ឆ្នាំ ១៩៩១ បានផ្តួចផ្តើមដំណើរការនៃការស្តារឡើងវិញ និង ការកសាងជាតិសំរាប់ កម្ពុជា ។ ការបោះឆ្នោតពហុបក្សលើកទីមួយបានប្រព្រឹត្តទៅកាលពីខែកក្កដា ឆ្នាំ ១៩៩៣ ដោយមានការចូលរួមរបស់អង្គការសហប្រជាជាតិ (UN) ។ ក្នុងខែកញ្ញា ឆ្នាំ១៩៩៣ រដ្ឋធម្មនុញ្ញថ្មីមួយត្រូវបានអនុម័តដែលបានបង្កើតរាជរដ្ឋាភិបាលកម្ពុជា ដែលប្រកាន់យកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សក្រោមរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។ ប្រទេសកម្ពុជាគឺជាហត្ថលេខីមួយនៃសេចក្តីថ្លែងការណ៍ សហស្សវត្សរ៍និង គឺជាភាគីមួយនៃឯកសារសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗចំនួនប្រាំមួយ ។

១៣. គណៈបក្សនយោបាយធំៗចំនួនបីបានគ្របដណ្តប់លើនយោបាយកម្ពុជាក្នុងទសវត្សរ៍កន្លងមកៈ គណៈបក្សប្រជាជន (CPP) គណៈបក្សហ៊្វុនស៊ិនប៉ិច (FUNCINPEC)[៤] និង ថ្មីៗនេះ គណៈបក្សសមរង្ស៊ី (SRP) ។ ចាប់តាំងពីឆ្នាំ ១៩៩៣ មក ការបោះឆ្នោតទូទាំងប្រទេសចំនួនបីត្រូវបានរៀបចំឡើង រួមទាំងការបោះឆ្នោតឃុំសង្កាត់លើកទីមួយក្នុងខែ កុម្ភៈ ឆ្នាំ ២០០២ ។

១៤. ថ្វីបើ CPP ឈ្នះការបោះឆ្នោតកាលពីថ្ងៃទី ២៧ ខែកក្កដាក្តី ក៏ CPP មិនបានទទួលសម្លេងភាគច្រើនពីរភាគបីដែលតម្រូវដោយរដ្ឋធម្មនុញ្ញ ដើម្បីបង្កើតរដ្ឋាភិបាលមួយដោយខ្លួនឯងឡើយ ។ រាជរដ្ឋាភិបាលថ្មីមួយត្រូវបានបង្កើតឡើងនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ក្រោយការចរចារអស់ពេលយ៉ាងយូររវាង CPP និង FUNCIPEC (ដែលនៅពេលមួយក៏បានតំណាងផងដែរនូវផលប្រយោជន៍របស់ SRP) អំពីការបង្កើតរដ្ឋាភិបាលចម្រុះមួយ ។ ក្នុងអំឡុងពេលនេះ រដ្ឋសភាជាតិមិនបានជួបប្រជុំ ហើយការងារនីតិកម្មមិនបានដំណើរការ ។ ក្រៅពី

---

[៤] FUNCINPEC គឺជាពាក្យកាត់ភាសាបារាំងសម្រាប់ រណសិរ្សរួបរួមជាតិដើម្បីប្រទេសកម្ពុជាឯករាជ្យ អព្យាក្រិត្យ សន្តិភាព និង សហប្រតិបត្តិការ ។

បរិយាកាសទូទៅនៃភាពមិនប្រាកដប្រជាដែលត្រូវបានបង្កើតឡើងដោយចន្លោះពេលដ៏យូរនេះ បញ្ហាមួយចំនួនបានប៉ះពាល់ដល់សកម្មភាពទាំងឡាយរបស់ដៃគូអភិវឌ្ឍន៍ទាំងអស់ដែលរួមមាន: (១) អវត្តមានថវិកាដែលបានទទួលការអនុម័តដែលការនេះ បានរាំងស្ទះដល់លទ្ធភាពរបស់រដ្ឋាភិបាលក្នុងការខ្ចី ក៏ដូចជាក្នុងការអនុវត្តវិធានការគោលនយោបាយមួយចំនួនផងដែរ និង (២) ការគ្មានលទ្ធភាពក្នុងការអនុម័តច្បាប់ដែលចាំបាច់ដើម្បីបំពេញតាមល័ក្ខខ័ណ្ឌកញ្ចប់ដែលបានព្រមព្រៀងជាមុនក្រោមកម្មវិធីឥណទាន ។

១៥. ប៉ុន្តែ ការបង្កើតរដ្ឋាភិបាលថ្មីមួយនៅថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ បានបង្ហាញនូវជំហានដ៏ធំមួយឆ្ពោះទៅមុខនៅក្នុងការវិវឌ្ឍន៍នយោបាយកម្ពុជា។ ថ្វីបើការបង្កើតរាជរដ្ឋាភិបាលបានចំណាយពេលដ៏វែងក្តី ក៏ការបង្កើតរាជរដ្ឋាភិបាលបានកើតឡើងតាមនីតិវិធីចរចារ ដែលនៅក្នុងនោះ ភាពខុសគ្នាធំៗទាំងឡាយរវាងគណៈបក្ស-នយោបាយត្រូវបានដោះស្រាយ និង ដោយគ្មានការប្រើហិង្សាដែលជាលក្ខណៈសំគាល់នៃលទ្ធផលបោះឆ្នោតលើកមុន។ បរិស្ថាននយោបាយថ្មីនេះក៏ត្រូវបានទ្រទ្រង់ផងដែរដោយការដាក់រាជសម្បត្តិថ្មីៗនេះរបស់ព្រះមហាក្សត្រព្រះបាទ សីហនុ និង ការឡើងគ្រងរាជសម្បត្តិប្រកបដោយសន្តិភាពនៃបុត្រព្រះអង្គ ព្រះបាទ សីហមុនី។ លទ្ធិប្រជាធិបតេយ្យក៏កំពុងចាក់ឫសផងដែរនៅក្នុងវិស័យដទៃទៀត។ ការបោះឆ្នោតឃុំ-សង្កាត់ ក្នុងឆ្នាំ ២០០២ គឺជាជំហានដ៏សំខាន់មួយនៅក្នុងកម្មវិធីដ៏ពេញលេញមួយនៃវិមជ្ឈការនយោបាយ រដ្ឋបាល និង ហិរញ្ញវត្ថុ។ សង្គមស៊ីវិល និង ក្រុមអង្គការក្រៅរដ្ឋាភិបាល កំពុងចូលរួមកាន់តែច្រើននៅក្នុងវិស័យផ្សេងៗដែលជាការបារម្ភសាធារណៈ ហើយសារព័ត៌មានមួយដែលមិនសូវរីកចំរើន កំពុងចាប់ផ្តើមប្រើប្រាស់សេរីភាពរបស់ខ្លួនដែលទើបបានទទួល។ ប៉ុន្តែ ស្ថាប័នសង្គមស៊ីវិលប្រឈមមុខនឹងចំណោទធំៗ ដូចជាការទទួលព័ត៌មាន ការចូលរួមក្នុងការពិភាក្សាជាមួយរាជរដ្ឋាភិបាល និង ការចូលរួមក្នុងដំណើរការទាំងឡាយ។ សមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការចូលរួមពិភាក្សាជាមួយសង្គមស៊ីវិល កំពុងកើនឡើង ប៉ុន្តែ យន្តការចូលរួមនៅមិនទាន់បានក្លាយទៅជាចរន្តក្នុងការធ្វើផែនការសាធារណៈ ឬ ដំណើរការត្រួតពិនិត្យឡើយ។

## ង. អភិបាលកិច្ច និង សមត្ថភាពស្ថាប័ន[៥]

១៦. ស្ថាប័នភាគច្រើននៅកម្ពុជាស្ទើរតែមិនដំណើរការទេនៅពេលដែលរាជរដ្ឋាភិបាលចាប់ផ្តើមអាណត្តិទីមួយរបស់ខ្លួនក្នុងឆ្នាំ ១៩៩៣។ ថ្វីបើកម្ពុជាសម្រេចបាននូវវឌ្ឍនភាពដ៏សំខាន់ក្នុងការកសាងស្ថាប័នរបស់ខ្លួនឡើងវិញក្តី ក៏ប្រទេសនេះបន្តដំណើរការនៅក្រោមសក្តានុពលសេដ្ឋកិច្ចនិងសង្គមកិច្ចរបស់ខ្លួនជាច្រើនដោយសារអភិបាលកិច្ចទន់ខ្សោយ។ វិស័យគន្លឹះនៃអភិបាលកិច្ចដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ រួមមានការកាត់បន្ថយអំពើពុក-រលួយ និងការធ្វើកំណែទម្រង់លើប្រព័ន្ធច្បាប់និងយុត្តិធម៌ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) រដ្ឋបាលសាធារណៈ និង អភិបាលកិច្ចមូលដ្ឋាន។ រាជរដ្ឋាភិបាលយល់ច្បាស់អំពីចំណោទទាំងនេះ និង បានដាក់ចេញកំណែទម្រង់នៅ ក្នុងឯកសារគោលនយោបាយសំខាន់ៗ រួមមានផែនការសកម្មភាពអភិបាលកិច្ច ផែនការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចទី ២ (SEDP II) យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) និង យុទ្ធសាស្ត្រចតុកោណ។ ទោះបីជាមានកិច្ចប្រឹងប្រែងច្រើនក្នុងការរៀបចំគោលនយោបាយក្តី ក៏ការអនុវត្តន៍កំណែទម្រង់នៅមានលក្ខណៈយឺតយ៉ាវ។ គេក៏ឃើញមានភាពចាំបាច់ផងដែរ ក្នុងការឱ្យប្រជាពលរដ្ឋធម្មតាបានចូលរួមកាន់តែពេញលេញនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តខាងគោលនយោបាយ ដើម្បីកែលំអគណនេយ្យភាព និង កាត់បន្ថយអំពើពុករលួយ។

១៧. **កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌** - ការពង្រឹងប្រព័ន្ធយុត្តិធម៌ និងសុច្ចរិតភាពតុលាការ គឺជាគន្លឹះចំពោះ ការធានាធ្វើអោយវិធានច្បាប់ប្រកបដោយប្រសិទ្ធិភាព។ វិធានច្បាប់មាននាទីដ៏សំខាន់មួយក្នុងការផ្តល់អំណាចដល់ជនក្រីក្រ ការធានាប្រកបដោយប្រសិទ្ធិភាពចំពោះវិនិយោគឯកជន និងធានាឱ្យបាននូវដំណោះស្រាយវិវាទគ្មានលំអៀង។ ថ្វីបើក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌បានរៀបចំពង្រាងផែនការសកម្មភាពកំណែទម្រង់មួយរួចហើយក្តី ក៏ការខកខានមិនបានអនុវត្តច្បាប់មានស្រាប់ ធ្វើឱ្យខូចខាតដល់កិច្ចប្រឹងប្រែងធ្វើកំណែទម្រង់។ បញ្ហាកំណែទម្រង់ច្បាប់រួមមានភាពប្រទាំងប្រទើសនៃច្បាប់ តម្លាភាពមានកម្រិតនៅក្នុងដំណើរការនីតិកម្ម សមត្ថភាពទន់ខ្សោយក្នុងការធ្វើសេចក្តីព្រាងច្បាប់ និងកង្វះការចូលរួមដោយភាគីពាក់ព័ន្ធ។ បញ្ហាកំណែទម្រង់ប្រព័ន្ធយុត្តិធម៌រួមមាន អភិបាលកិច្ចទន់ខ្សោយនិងអំពើពុករលួយនៅក្នុងប្រព័ន្ធយុត្តិធម៌ ភាពចាំបាច់

---

[៥] ADB បានរៀបចំការវាយតម្លៃអភិបាលកិច្ចមួយក្នុងឆ្នាំ ២០០០ (ADB ។ ឆ្នាំ ២០០០។ *លើកកំពស់អភិបាលកិច្ចដើម្បីកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព* ។ ម៉ានីល) ។ ការបោះពុម្ពផ្សាយដែលត្រូវបានរៀបចំដោយធនាគារពិភពលោក និង ADB ក្នុងឆ្នាំ ២០០៣ (ធនាគារពិភពលោក និង ADB ។ ឆ្នាំ ២០០៣។ *របាយការណ៍វាយតម្លៃនិងត្រួតពិនិត្យចំណាយសាធារណៈ* ។ ភ្នំពេញ: ធនាគារពិភព-លោក និង ADB) ផ្តល់នូវការវាយតម្លៃលំអិតលើបញ្ហាអភិបាលកិច្ចនៅកម្ពុជា។ ADB ក៏បានរៀបចំផងដែរនូវការពិនិត្យមើលអភិបាល-កិច្ចក្នុងកម្រិតវិស័យ សម្រាប់ SCP និង សម្រាប់ការបន្ថែមលើការវាយតម្លៃអភិបាលកិច្ច (ADB ។ ឆ្នាំ ២០០៣។ *ការវាយតម្លៃលើការអនុវត្តន៍គោលនយោបាយនិងកំណែទម្រង់តាមវិស័យមួយចំនួននៅប្រទេសកម្ពុជា* ។ ម៉ានីល) ។

នៃកំណែទម្រង់ឧត្តមក្រុមប្រឹក្សាអង្គចៅក្រម ចំនួនដ៏តិចតួចនៃចៅក្រមនិងអ្នកច្បាប់ជំនាញ និងប្រាក់បៀវត្សរ៍ដ៏ទាបរបស់ចៅក្រមនិងរាជអាជ្ញា។

១៨. **ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM)** - ភាពទន់ខ្សោយនៅក្នុងការគ្រប់គ្រងចំណាយសាធារណៈបាននាំឱ្យមានការធ្វើវិភាជន៍ដែលគ្មានប្រសិទ្ធិភាពនូវធនធានសាធារណៈដ៏មានកម្រិត ដែលជាហេតុកាត់បន្ថយឥទ្ធិពលអភិវឌ្ឍន៍នៃធនធានទាំងនេះ។ ចំណាយសាធារណៈគឺមានចំនួន ១៩,៤% នៃ GDP ក្នុងឆ្នាំ ២០០៣ ពោលគឺមានលក្ខណៈទាបតាមនិយាមអន្តរជាតិ ហើយចំណូលធៀបនឹង GDP គឺមានចំនួន ១២,០% ដោយមានចំណូលពន្ធត្រឹមតែ ៨,៤% នៃ GDP ប៉ុណ្ណោះ ដែលស្ថិតនៅក្នុងកំរិតមួយទាបបំផុតក្នុងពិភពលោក។ អតុល្យភាពជាប្រចាំរវាងកាតព្វកិច្ចរដ្ឋាភិបាល និង ចំណូលក្នុងស្រុក គឺជាកត្តារួមចំណែកដ៏សំខាន់មួយ ចំពោះអភិបាលកិច្ចទន់ខ្សោយ និង អំពើពុករលួយ ដែលត្រូវបានឆ្លុះបញ្ចាំងយ៉ាងច្បាស់នៅក្នុងប្រាក់បៀវត្សរ៍ វិស័យសាធារណៈដ៏ទាប ការផ្តល់សេវាកម្មសំខាន់ៗទាំងឡាយមិនបានគ្រប់គ្រាន់ ការបង់ប្រាក់ក្រៅផ្លូវការដើម្បី ទទួលសេវាកម្ម ការផ្តល់មូលនិធិ មិនគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការនិងការថែទាំ និង មជ្ឈការអំណាចលើចំណូលដែលមានតិចតួច។

១៩. រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តចំពោះការធ្វើកំណែទម្រង់ PFM ដ៏ពេញលេញ និង ដោយមានការជួយឧត្តម្ភពីអ្នកផ្តល់ជំនួយ មានបំណង (១) កែលំអការរៀបចំថវិកាដោយពង្រឹង ទំនាក់ទំនងរវាងគោលនយោបាយនិងថវិកា និងដោយដាក់ឱ្យអនុវត្តនូវក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និង (២) កែលំអការអនុវត្តន៍ថវិកាដោយពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងដោយកែលំអប្រតិបត្តិការរតនាគារ។ អង្កេតតាមដានចំណាយសាធារណៈមួយកំពុងត្រូវបានផ្តួចផ្តើមសម្រាប់វិស័យអប់រំនិងសុខាភិបាល ដើម្បីកំណត់បញ្ហារាំងស្ទះនិងចន្លោះប្រហោងនៅក្នុងហិរញ្ញវត្ថុសាធារណៈនៅកម្រិតជាតិនិងមូលដ្ឋាន។ រាជរដ្ឋាភិបាលក៏នឹងត្រូវពង្រឹងផងដែរនូវប្រព័ន្ធគណនេយ្យភាពដើម្បីកាត់បន្ថយហានិភ័យចំណាយចំពោះមូលនិធិសាធារណៈ។

២០. **កំណែទម្រង់រដ្ឋបាលសាធារណៈ** - បញ្ហាចំពោះមុខដ៏ធ្ងន់ធ្ងរដែលប៉ះពាល់ដល់អង្គការរដ្ឋបាលស៊ីវិលពោលគឺ ប្រាក់បៀវត្សរ៍ទាប អវត្តមាននៃគោលនយោបាយច្បាស់លាស់សម្រាប់ការជ្រើសរើសនិងការតម្លើង ឋានន្តរស័ក្តិ និង ជំនាញទាបដែលនាំឱ្យមានសមត្ថភាពទាប។ កំណែទម្រង់អង្គការរដ្ឋបាលស៊ីវិលដ៏ពេញលេញគឺជាអាទិភាពដ៏សំខាន់មួយ ប្រសិនបើគេចង់កែលំអរការផ្តល់សេវា។ គេឃើញមានភាពចាំបាច់បន្ទាន់ចំពោះការធ្វើសនិទានកម្មលើអង្គការរដ្ឋបាលស៊ីវិល ការដាក់ឱ្យអនុវត្តការគ្រប់គ្រងស្នាដៃការងារប្រកបដោយប្រសិទ្ធិភាព និងការតម្លើងប្រាក់បៀវត្សរ៍របស់បុគ្គលិកដែលនៅសល់ឱ្យបានដល់កម្រិតមួយដែលអាចរស់បាន។ ត្រូវតែមានភាពចាំបាច់ផងដែរចំពោះការកែលំអការដាក់ពង្រាយបុគ្គលិកសាធារណៈតាមវិស័យនិងតាមភូមិសាស្ត្រ ក៏ដូចជាការកែលំអការសម្របសម្រួលរវាងក្រសួងទាំងឡាយ។

២១. **អំពើពុករលួយ** - ស្ថាប័នទន់ខ្សោយ និង យន្តការគណនេយ្យភាពមានកម្រិត គឺជាកេរ្តិ៍ដំណែលនៃប្រវត្តិសាស្ត្រថ្មីៗរបស់កម្ពុជា និង រួមចំណែកដល់អំពើពុករលួយកម្រិតខ្ពស់។ ថ្វីបើគេមានការលំបាកនឹងកំណត់ជាតួលេខក្តី ក៏ភស្តុតាងបង្ហាញថា អំពើពុករលួយរារាំងយ៉ាងធ្ងន់ធ្ងរដល់កំណើនសេដ្ឋកិច្ច កិច្ចអភិវឌ្ឍន៍វិស័យឯកជន និង ការកាត់បន្ថយភាពក្រីក្រ។ ការសិក្សាថ្មីៗមួយអំពីភាពប្រកួតប្រជែងរបស់ប្រទេស បានកំណត់ចំណាយនៃអំពើពុករលួយថាគឺជាឧបសគ្គដ៏សំខាន់ជាងគេតែមួយគត់ ដែលប្រឈមមុខដោយវិស័យឯកជនក្នុងការប្រកបអាជីវកម្មនៅប្រទេសកម្ពុជា។[៦] តាមការអង្កេតដទៃទៀតក៏បង្ហាញផងដែរថា អំពើពុករលួយគឺជាការបារម្ភដ៏ចំបងមួយរបស់គ្រួសារ សហគ្រាស មន្ត្រីសាធារណៈ អង្គការក្រៅរដ្ឋាភិបាល (NGO) និង គ្រឹះស្ថានសិក្សា។[៧]

២២. គម្លាតនៅក្នុងក្របខ័ណ្ឌច្បាប់ និង ការអនុវត្តន៍ច្បាប់ដែលមានស្រាប់ មានសភាពទន់ខ្សោយ ជាការរារាំងដល់កិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយ។ ថ្វីបើមានវឌ្ឍនភាពខ្លះៗឆ្ពោះទៅកាន់ការបង្កើតអាជ្ញាធរសវនកម្មជាតិ និងការដាក់ឱ្យអនុវត្តនីតិវិធីលទ្ធកម្មនៅក្នុងក្រសួងភាគច្រើនក្តី សេចក្តីព្រាងច្បាប់ប្រឆាំងអំពើពុករលួយបច្ចុប្បន្នត្រូវតែធ្វើការកែលំអរដើម្បីធ្វើឱ្យស្របតាមស្តង់ដារ និងការអនុវត្តន៍អន្តរជាតិ (ឧទាហរណ៍ដូចមានឆ្លុះបញ្ចាំងនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រឆាំងអំពើពុករលួយ) និង ចាំបាច់ត្រូវទទួលបានការអនុម័ត។

២៣. **វិមជ្ឈការ**[៨] រាជរដ្ឋាភិបាលចាត់ទុកវិមជ្ឈការជាកត្តាដ៏សំខាន់មួយចំពោះការពង្រឹងការចូលរួមរបស់មូលដ្ឋាននៅក្នុងរដ្ឋាភិបាល និង ការកែលំអការផ្តល់សេវាកម្មសាធារណៈ។ ទោះបីជាការបោះឆ្នោតឃុំ-សង្កាត់គឺជាជំហានដ៏សំខាន់ទីមួយក្តី ក៏គេចាំបាច់ត្រូវប្រឹងប្រែងបន្ថែមទៀត ដើម្បីផ្តល់ឱកាសជូនដល់ប្រជាពលរដ្ឋក្នុងការមានឥទ្ធិពលលើរដ្ឋាភិបាល និងការចូលរួមក្នុងរដ្ឋាភិបាល។ បច្ចុប្បន្ននេះ ក្រុមប្រឹក្សាឃុំ-សង្កាត់គ្រប់គ្រងធនធានដ៏ស្តួចស្តើងដែលជាហេតុនាំឱ្យមានការអនុវត្តន៍តិចតួចនូវសេវាកម្មនិងវិនិយោគ។ ក្រុមប្រឹក្សាឃុំ-សង្កាត់ នៅតែខ្វះអំណាចសមត្ថភាពរដ្ឋបាល និងធនធានហិរញ្ញវត្ថុដើម្បីបង្កើនល្បឿនអភិវឌ្ឍន៍របស់ខ្លួន និងមានមធ្យោបាយដ៏ស្តួចស្តើងសម្រាប់ការដោះស្រាយវិវាទ។ គោលនយោបាយរាជរដ្ឋាភិបាលស្តីពីវិមជ្ឈការ ពុំទាន់ត្រូវបានកំណត់អោយបានច្បាស់លាស់នៅឡើយ ហើយចាំបាច់ត្រូវធ្វើអោយមានសុខុដុមនីយកម្មកាន់តែខ្លាំងថែមទៀតរវាងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ។ បច្ចុប្បន្ននេះ គេឃើញមានកិច្ចប្រឹងប្រែងមួយដើម្បីបង្កើតទស្សនៈពេញលេញ មួយ ចំពោះវិមជ្ឈការនិងវិសហមជ្ឈការ។

---

[៦] ធនាគារពិភពលោក។ ឆ្នាំ ២០០៤។ កម្ពុជា: ច្បាមយកកាលានុវត្តភាពពិភពលោក: *ការវាយតម្លៃលើបរិយាកាសវិនិយោគ និង យុទ្ធសាស្ត្រកំណែទម្រង់*។ វ៉ាស៊ីនតោន: ធនាគារពិភពលោក

[៧] អង្កេតអតិថិជនរបស់ធនាគារពិភពលោក។ ខែ មិថុនា ឆ្នាំ ២០០៣: ការអង្កេតរបស់មូលនិធិអាស៊ី ឆ្នាំ ២០០៣ ។

[៨] វិមជ្ឈការគឺជាការផ្ទេរអំណាចរដ្ឋាភិបាល អាណត្តិ និង ធនធានពីរដ្ឋាភិបាលកណ្តាលទៅឱ្យអាជ្ញាធរថ្នាក់ក្រោមជាតិ។ វិសហមជ្ឈការគឺជាការផ្តល់កិច្ចការរបស់រដ្ឋបាលកណ្តាលឱ្យទៅរដ្ឋបាលថ្នាក់ក្រោម។

## ច. ការវាយតម្លៃស្ថានភាពផ្នែក យេនឌ័រ[៩]

២៤. ប្រទេសកម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសនៅអាស៊ី ដែលមានកម្រិតសមធមិយេនឌ័រទាបបំផុត ជាក់ស្តែង សន្ទស្សន៍អភិវឌ្ឍន៍ទាក់ទិននឹងយេនឌ័របានត្រឹមតែ ០,៥៥៧ ហើយសន្ទស្សន៍ផ្តល់អំណាចយេនឌ័របានត្រឹមតែ ០,៣៦៤។[១០] តរិយាបទសង្គម និងប្រពៃណី រមែងចាត់ទុកស្ត្រីអោយមានឋានៈទាបជាងបុរស។ ផលវិបាកនៃតរិយាបថជាប្រពៃណីទាំងនេះ បានស្តែងចេញយ៉ាងច្បាស់ជាភាពខុសគ្នាដ៏គួរអោយកត់សំគាល់ រវាងបុរសនិងស្ត្រី នៅក្នុងសមិទ្ធផលអប់រំនិងកម្រិតអក្ខរកម្មនៅក្នុងអត្រានៃពលកម្មរបស់កុមារានិងកុមារី នៅក្នុងលទ្ធភាពទទួលបាននូវសេវាកម្មសាធារណៈ និង ការដែលបុរសមានតួនាទីជាច្រើននៅក្នុងមុខតំណែងដែលមានសិទ្ធិធ្វើសេចក្តីសម្រេចនានា។ នៅក្នុងចំណោមអ្នកក្រីក្រ ស្ត្រីកម្ពុជាមានចំនួនច្រើនជាងបុរសនៅក្នុងគ្រប់ក្រុមសេដ្ឋកិច្ចទាំងអស់។[១១]

២៥. ស្ត្រីរួមចំណែកយ៉ាងច្រើនដល់កំណើនសេដ្ឋកិច្ច និងចំណូលជាតិព្រមទាំងដល់សុខុមាលភាពនៃគ្រួសាររបស់ពួកគាត់។ ស្ត្រីមានចំនួន ៥៤% នៃចំនួនអ្នកធ្វើការទាំងអស់នៅក្នុងវិស័យកសិកម្ម និងនេសាទ ហើយប្រាក់ចំណូលរបស់ពួកគាត់បានផ្គត់ផ្គង់ដល់ជាងពាក់កណ្តាលនៃការចំណាយទាំងអស់នៅក្នុងគ្រួសារ។ នៅក្នុងបរិបទនៃការប្តូរផ្លាស់ ទៅកាន់សេដ្ឋកិច្ចទីផ្សារ និងកិច្ចអភិវឌ្ឍន៍វិស័យឯកជន ស្ត្រីបានទទួលជោគជ័យដ៏ធំក្នុងការទទួលបាននូវការងារមានប្រាក់បំណាច់នៅក្នុងបណ្តាឆ្នាំថ្មីៗកន្លងទៅនេះ។ ប៉ុន្តែ ជោគជ័យទាំងនេះ គឺមានតែនៅក្នុងឧស្សាហកម្មសំលៀកបំពាក់តែប៉ុណ្ណោះ ដែលនាអនាគតដ៏ខ្លីខាងមុខនេះ វាមានលក្ខណៈមិនប្រាកដប្រជាឡើយ។ នៅក្នុងវិស័យរោងចក្រសំលៀកបំពាក់ កម្មការិនីច្រើនតែមានកំរិតវប្បធម៌ល្អគួរសម ហើយគ្រួសារជាច្រើននៅជនបទ រមែងបានទទួលការផ្ញើរប្រាក់ចំណូលទៀងទាត់ពីកូនស្រីរបស់ខ្លួន។ ក្រៅពីវិស័យកសិកម្ម និងសំលៀកបំពាក់ ស្ត្រីច្រើនប្រកបរបរជាអ្នកលក់ដូរតូចតាច ឬមានមុខរបរបន្តិចបន្តួចនៅផ្ទះ ចំនួនស្ត្រីដែលធ្វើរបៀបនេះ មានចំនួន ៤៩% នៃអ្នកលក់ដូរតូចតាចដោយខ្លួនឯងទាំងអស់។ បន្ថែម លើទស្សនៈកំណត់ដោយប្រពៃណី អំពីមុខរបរសំរាប់"បុរស" និងសំរាប់"ស្ត្រី"នោះ កម្រិតវប្បធម៌ទាបរបស់ស្ត្រី ធ្វើអោយពួកគាត់មានការលំបាកក្នុងការប្រកួតប្រជែងឆ្ពោះទៅរកការងារល្អៗដែរ។ ការមិនមានលទ្ធភាពប្រើប្រាស់ ឬគ្រប់គ្រងលើធនធានផលិតកម្ម និងលើសេវាកម្មទាំងឡាយ ដូចជាការខ្ចីឥណទាន មានដីធ្លី និងមានកម្មសិទ្ធិដីធ្លី ការបានទទួល

---

[៩] មូលនិធិអភិវឌ្ឍន៍អង្គការសហប្រជាជាតិសម្រាប់ស្ត្រី (UNIFEM) ធនាគារពិភពលោក (WB) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDP) និង ក្រសួងអភិវឌ្ឍន៍អន្តរជាតិអង់គ្លេស (DFID/UK), ឆ្នាំ ២០០៤, *ចំណែកដ៏យុត្តិធម៌មួយសម្រាប់ស្ត្រី: ការវាយតម្លៃយេនឌ័រកម្ពុជា*។ ភ្នំពេញ: UNIFEM, WB, ADB, UNDP, DFID/UK ។

[១០] UNDP, ឆ្នាំ ២០០៣ *របាយការណ៍អភិវឌ្ឍន៍មនុស្ស ឆ្នាំ ២០០៣*, ញូវយ៉ក: UNDP ។

[១១] ក្រសួងផែនការ។ ឆ្នាំ ២០០០។ *របាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជា ឆ្នាំ ២០០០*។ ភ្នំពេញ: រាជរដ្ឋាភិបាលកម្ពុជា។

បច្ចេកទេសកសិកម្ម និងសេវាកម្មផ្សព្វផ្សាយជាដើម គឺជាបញ្ហាយេនឌ័រដ៏សំខាន់ដែលភាពខុសគ្នារវាងបុរសនិងស្ត្រី នៅតែមាននៅឡើយ ។

២៦. ថ្វីបើមានការរីកចំរើននៅក្នុងការកាត់បន្ថយវិសមភាពយេនឌ័រនៅក្នុងវិស័យសង្គមក៏ដោយ ក៏គម្លាតយេនឌ័រ ឬភាពខុសគ្នារវាងបុរសនិងស្ត្រីនៅតែមានយ៉ាងធ្ងន់ធ្ងរនៅឡើយ ។ នៅក្នុងវិស័យអប់រំ ទោះបីជាមានកំណើនសមធម៌យេនឌ័រនៅកម្រិតបឋមសិក្សាក្តី (ចំនួនក្មេងស្រីចូលសាលាមានចំនួនប្រហាក់ប្រហែលនឹងចំនួនក្មេងប្រុស) ក៏ចំនួនខុសគ្នាគួរអោយកត់សំគាល់រវាងក្មេងប្រុសនិងក្មេងស្រីនៅតែមាន នៅក្នុងកម្រិតសិក្សាកាន់តែខ្ពស់ គម្លាតនេះកាន់តែច្បាស់ ហើយនៅក្នុងក្រុមក្មេងដែលមានអាយុ ១៤-១៧ឆ្នាំ អត្រាពលកម្មរបស់កុមារីមានចំនួន៥០%នៃចំនួនក្មេងស្រីដែលធ្វើការ គឺច្រើនជាងអត្រាពលកម្មរបស់កុមារា ដែលមានចំនួនត្រឹមតែ៣៦%ប៉ុណ្ណោះ ។ នៅក្នុងវិស័យសុខាភិបាល ថ្វីបើមានការរីកចំរើនក្នុងការកសាងឡើងវិញនូវសេវាកម្មសុខភាពក៏ដោយ ក៏អត្រាស្លាប់របស់ស្ត្រីនាពេលសំរាលកូននៅតែខ្ពស់ជាងបណ្តាប្រទេសនានាក្នុងដំបន់ដដែល គឺស្លាប់ចំនួន ៤៣៧នាក់ ក្នុងចំណោមស្ត្រីដែលបង្កើតកូនចំនួន១០ម៉ឺននាក់ សភាពការណ៍នេះ តម្រូវឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតលើសេវាសុខភាពបន្តពូជ និងកែលំអអោយបានប្រសើរជាងមុននូវលទ្ធភាពរបស់ស្ត្រីក្នុងការទទួលព័ត៌មាន និង ទទួលសេវាកម្ម ផ្នែកសុខាភិបាល ។

២៧. ស្ត្រីមានចំនួនតិចតួចណាស់ ទាំងនៅក្នុងមុខតំណែងដែលទទួលការបោះឆ្នោតជ្រើសរើសតាមអាណត្តិ និងទាំងនៅក្នុងមុខតំណែងតែងតាំង ជាបុគ្គលិកមន្ត្រីរបស់រដ្ឋ ពីកម្រិតមធ្យមដល់កំរិតខ្ពស់ ។ ស្ត្រីមានត្រឹមតែ ៨,៥% នៃចំនួនសមាជិកក្រុមប្រឹក្សា ឃុំ-សង្កាត់ទាំងអស់ និង ១២,២% នៃសមាជិករដ្ឋសភាជាតិតែប៉ុណ្ណោះ ។ ការដែលមានចំនួនស្ត្រីតិចតួចនេះ គឺទាក់ទិនដោយផ្ទាល់ទៅនឹងចំនួនដ៏តិចតួចនៃបេក្ខនារីនៅក្នុងបញ្ជីគណៈបក្សនានា ។ ក្របខ័ណ្ឌច្បាប់ដ៏ក្មេងខ្ចីរបស់ប្រទេសកម្ពុជា បានផ្តល់សិទ្ធិជាច្រើនដល់ស្ត្រី ប៉ុន្តែស្ត្រីភាគច្រើន ពុំបានយល់ដឹងអំពីសិទ្ធិទាំងនេះឡើយ ។ ភាពទន់ខ្សោយជាទូទៅនៅក្នុងប្រព័ន្ធយុត្តិធម៌ គួបផ្សំជាមួយនឹងឋានៈដ៏ទាបដែលសង្គមបានផ្តល់ចំពោះស្ត្រី ធ្វើឱ្យស្ត្រីមិនសូវមានលទ្ធភាពការពារខ្លួនតាមផ្លូវច្បាប់ឡើយ ។ ហេតុនេះ ស្ត្រីងាយនឹងរងគ្រោះ ត្រូវគេជួញដូរដើម្បីបំរើកាមគុណ ត្រូវទទួលអំពើហិង្សាក្នុងគ្រួសារនិងការចាប់រំលោភ ។ ឋានៈស្របច្បាប ដ៏ទាបរបស់ស្ត្រីនៅក្នុងវិវាទទ្រព្យសម្បត្តិ ក៏គឺជាការបារម្ភមួយផងដែរ ។ ទោះបីជាគេសម្រេចបាននូវវឌ្ឍនភាពខ្លះនៅក្នុងការបង្កើតគោលនយោបាយនានា សំដៅជម្រុញសមធម៌យេនឌ័រក៏ដោយក៏ការបញ្ជ្រាបយេនឌ័រ នៅតែស្ថិតជាបញ្ហាដ៏ធ្ងន់ធ្ងរដដែល ហើយឆន្ទៈដឹកនាំក្នុងការអនុវត្តន៍គោលនយោបាយទាំងនេះ ក៏នៅមានកំរិតនៅឡើយ ។

## ឆ. វិស័យឯកជន[១២]

២៨. វិស័យឯកជននៅកម្ពុជាគឺត្រូវបានគ្របដណ្តប់ដោយវិស័យមិនរៀបរយក្រៅផ្លូវការ ដែលមានចំនួនជាង ៨០% នៃ GDP និង ជិត ៩០% នៃការងារដែលនៅក្រៅរង្វង់វិស័យសាធារណៈ។ សកម្មភាពវិស័យមិនរៀបរយក្រៅផ្លូវការជាច្រើនបានប្រមូលផ្តុំក្នុងវិស័យកសិកម្ម។ វិស័យឧស្សាហកម្មមិនរៀបរយក្រៅផ្លូវការគឺមានចំនួនស្ទើរពាក់កណ្តាលនៃទិន្នផលឧស្សាហកម្មទាំងអស់ និង ភាគច្រើនសំរាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុក។ គេបានប៉ាន់ស្មានថាសហគ្រាសជាង ៩០% នៅកម្ពុជាមានទំហំតូច (មាននិយោជិត តិចជាង ១០០ នាក់) និងដំណើរការទាំងស្រុងនៅក្នុងវិស័យមិនរៀបរយក្រៅផ្លូវការ។ សហគ្រាសឯកជនប្រហែល ៧.០០០ ដែលបានចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មគឺជាវិស័យឯកជនរៀបរយផ្លូវការ ដែលបានប្រមូលផ្តុំតែទៅលើវិស័យសំលៀកបំពាក់និងទេសចរណ៍។ វិនិយោគបរទេសផ្ទាល់បានដើរតួនាទី ដ៏សំខាន់មួយក្នុងការអភិវឌ្ឍន៍វិស័យឯកជនរៀបរយផ្លូវការ និង គឺជាប្រភពចំបងនៃការនាំចេញ។ ប៉ុន្តែ ចាប់តាំងពីចុងទស្សវត្សរ៍ ១៩៩០មក វិនិយោគបរទេសផ្ទាល់បានធ្លាក់ចុះ។ កិច្ចប្រឹងប្រែងរបស់វិស័យឯកជនក្នុងការជម្រុញកំណើននិងការងារ ត្រូវបានរារាំងដោយ (១) អភិបាលកិច្ចទន់ខ្សោយដែលរួមមានក្របខ័ណ្ឌច្បាប់មិនទាន់លូតលាស់ និងរបបនិយតកម្មគ្មានប្រសិទ្ធិភាព ការិយាធិបតេយ្យច្រើនហួសហេតុ ក៏ដូចជាអំពើពុករលួយ ដែលមានពាសពេញ (២) ចំណាយដ៏ខ្ពស់និងកង្វះលទ្ធភាពក្នុងការទទួលបានហិរញ្ញប្បទានស្ថាប័ន (៣) ចំណាយខ្ពស់និងកង្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធនៅក្នុងវិស័យដឹកជញ្ជូននិងថាមពល (៤) ជំនាញនៃធនធានមនុស្ស ផ្នែកបច្ចេកទេសនិងការងារគ្រប់គ្រងមានកម្រិត និង (៥) លទ្ធភាពប្រើប្រាស់ដីធ្លីព័ត៌មាន និង លទ្ធភាពចូលដល់ ទីផ្សារប្រកួតប្រជែងមានកម្រិត។

២៩. ការអង្កេតលើសហគ្រាសបង្ហាញថា នីតិវិធីចុះបញ្ជីនិងផ្តល់អាជ្ញាប័ណ្ណដ៏ស្មុគស្មាញ និង ការបង់ប្រាក់ផ្លូវការ និងក្រៅផ្លូវការ គឺជាបន្ទុកដ៏ធ្ងន់ធ្ងរ។ ហេតុនេះ សហគ្រាសសុខចិត្តស្ថិតនៅក្នុងលក្ខណៈមិនរៀបរយក្រៅផ្លូវការ ដើម្បីជៀសវាងចំណាយដ៏ខ្ពស់ទាំងនេះ។ មូលដ្ឋានពន្ធដ៏មានកម្រិតរបស់ប្រទេសមានន័យថា បន្ទុកបង់ពន្ធត្រូវបានរ៉ែកពុនដោយសហគ្រាសមួយក្រុមតូចដែលបានចុះបញ្ជី។ អ្នកនាំចេញត្អូញត្អែរថា ការិយាធិបតេយ្យទាក់ទិននឹងចំណាត់ការនាំចេញបណ្តាលឱ្យមានការយឺតយ៉ាវខ្លាំង ខណៈដែលការរត់ពន្ធពីប្រទេសជិតខាងជះឥទ្ធិពលជាអវិជ្ជមានលើផលិតករក្នុងស្រុក។ ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនអន់ថយនិងការបង់ថ្លៃក្រៅផ្លូវការ និង ថ្លៃអគ្គិសនីខ្ពស់ ដែលបណ្តាលមកពីកង្វះសមត្ថភាពផលិតអគ្គិសនី ក៏បង្កើនចំណាយនៃការធ្វើអាជីវកម្មនៅកម្ពុជាផងដែរ។ បញ្ហាកាន់កាប់ដីធ្លីទាក់ទិននឹងការផ្តល់កម្មសិទ្ធិដីធ្លីដែលនៅមានកម្រិតទាបនៅឡើយ បានរារាំងវិនិយោគនៅក្នុងវិស័យកសិកម្មខណៈដែលកង្វះលទ្ធភាពទទួលឥណទាន ជាពិសេស សម្រាប់សហគ្រាសខ្នាតតូចនិងមធ្យម

[១២] ចូរមើល ADB។ ឆ្នាំ ២០០៤។ *ការវាយតម្លៃវិស័យឯកជនសម្រាប់ព្រះរាជាណាចក្រកម្ពុជា*។ ម៉ានីល និង លេខយោង ៦។

(SMEs) បានបន្ទុចបង្អាក់កំណើនក្នុងវិស័យឯកជន។ គេពុំឃើញមានយុទ្ធសាស្ត្រអភិវឌ្ឍន៍សម្រាប់វិស័យ SME ដែលជាវិស័យមួយសម្គាល់ទៅដោយជំនាញសហគ្រិន និងនិយាមគណនេយ្យមានកំរិតទាបនៅឡើយ។ SMEs មានលទ្ធភាពដ៏ស្តួចស្តើងក្នុងការទទួលព័ត៌មានទីផ្សារ និង បច្ចេកវិទ្យា។

៣០. យុទ្ធសាស្ត្រចតុកោណបញ្ជាក់ថា វិស័យឯកជនត្រូវតែជាក្បាលម៉ាស៊ីននៃកំណើន ក្នុងការបង្កើតការងារ និង ការកាត់បន្ថយភាពក្រីក្រ។ យុទ្ធសាស្ត្រចតុកោណតម្រូវឱ្យរដ្ឋាភិបាលដោះស្រាយអប្រសិទ្ធិភាពទាំងឡាយ ដែលបានលើកឡើងខាងលើនេះ។ កិច្ចអភិវឌ្ឍន៍វិស័យឯកជន បានចាប់បន្តធ្វើឡើងឈរលើការឈ្វេងយល់នូវសភាពការណ៍កាន់តែបន្ទាន់ចំពោះមុខនូវការបញ្ចប់ប្រព័ន្ធកូតា MFA ភាពចាំបាច់ក្នុងការលើកកំពស់ភាពប្រកួតប្រជែងចំពោះមុខការចូលក្នុងអង្គការ WTO និង អត្រាគ្មានការងារដ៏ខ្ពស់ក្នុងចំណោមអ្នកចំណូលថ្មីក្នុងទីផ្សារពលកម្ម។ ដើម្បីជាការឆ្លើយតប រាជរដ្ឋាភិបាលបានចាប់ផ្តើមកម្មវិធីអភិវឌ្ឍន៍វិស័យឯកជនដ៏ពេញលេញមួយ ដោយយកចិត្តទុកដាក់លើការសម្រួលពាណិជ្ជកម្ម ការអភិវឌ្ឍន៍ SMEs និង ការលើកកំពស់ការចូលរួមរបស់ឯកជនក្នុងការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ។ កំណែទម្រង់មួយចំនួនត្រូវបានដាក់ឱ្យអនុវត្តរួចហើយដើម្បីកាត់បន្ថយចំណាយនិងពេលវេលានៃប្រតិបត្តិការនាំចេញនិងនាំចូល លុបបំបាត់ឧបសគ្គចំពោះការធ្វើឱ្យ SME មានលក្ខណៈរៀបរយផ្លូវការ និង កែលំអតម្លាភាព នៅក្នុងការគ្រប់គ្រងការចូលរួមរបស់ឯកជននៅក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធទាំងឡាយ។ ការធានាឱ្យបានថា វិធានការកែទម្រង់ពិតជាត្រូវបានអនុវត្ត និង មានចីរភាព នឹងជាបញ្ហាប្រឈមដ៏ធំមួយ។

## ជ. បរិស្ថាន[១៣]

៣១. **ការគ្រប់គ្រងបរិស្ថាន** - សេដ្ឋកិច្ចប្រទេសកម្ពុជាពឹងផ្អែកយ៉ាងច្រើនលើកសិកម្ម នេសាទ និង ធនធានធម្មជាតិ និងប្រព័ន្ធបរិស្ថាន ពិសេសតំបន់ជុំវិញបឹងទន្លេសាប។ ការគ្រប់គ្រងបរិស្ថាននៅកម្ពុជាគឺមានសភាពទន់ខ្សោយ ហើយក្របខ័ណ្ឌច្បាប់ ពុំអាចឆ្លើយតបទៅនឹងតម្រូវការខាងបរិស្ថានរបស់ប្រទេសឡើយ។ ព័ត៌មាន និងការណែនាំដ៏សំខាន់ៗ អំពីការកាប់ព្រៃឈើទៅតាមបែបបទត្រឹមត្រូវ ការអនុញ្ញាតឱ្យធ្វើការនេសាទ ដោយរក្សាលំនឹងនៃទិន្នផលត្រី និង ការរក្សាធនធានទឹកក្រោមដី គឺនៅមានការខ្វះខាត ទាំងស្រុង។ ការចូលរួមដ៏តិចតួចរបស់ភាគីពាក់ព័ន្ធ ធ្វើអោយការគ្រប់គ្រងរបស់ សហគមន៍លើធនធានធម្មជាតិមានការខ្វះខាត។ តួនាទីនិងការទទួលខុសត្រូវនៃស្ថាប័នបរិស្ថានទាំងឡាយនៅ គ្រប់ លំដាប់ ថ្នាក់ ចាំបាច់ត្រូវបំភ្លឺឱ្យបានច្បាស់លាស់ដែលបច្ចុប្បន្ននេះមានរហូតដល់ ទៅ ១៤ ស្ថាប័នដែលជាប់ ពាក់ ព្វន័ក្នុងការគ្រប់គ្រង

---

[១៣] ចូរមើល ADB។ ឆ្នាំ ២០០៣។ *ការវាយតម្លៃបរិស្ថានសម្រាប់ប្រទេសកម្ពុជា*។ ម៉ានីល និង ធនាគារពិភពលោក។ ឆ្នាំ ២០០៣។ *ការត្រួតពិនិត្យបរិស្ថានកម្ពុជា*។ វ៉ាស៊ីនតោន: ធនាគារពិភពលោក។

បឹងទន្លេសាប។ សមត្ថភាពគ្រប់គ្រង គឺទន់ខ្សោយ ជាពិសេសនៅក្នុងថ្នាក់ខេត្ត។ ចំណោទបរិស្ថានធំៗរបស់រដ្ឋាភិបាល រួមមាន (១) ការថយចុះនៃគម្របព្រៃឈើ ដែលកាត់បន្ថយជីវៈចម្រុះ បណ្តាលឱ្យមានសំណឹកដី បង្កើនល្បឿននៃការហូរច្រោះដីល្បប់ហូរចាក់ចូលទន្លេធ្វើអោយទន្លេរាក់ និង បង្កើនទឹកជំនន់ (២) ទឹកសំណល់កខ្វក់គ្មានកន្លែងចាក់ចោលឱ្យបានត្រឹមត្រូវ (៣) ប្រព័ន្ធធារាសាស្ត្រគ្មាន ចេរភាព (៤) ការខូចខាតធនធានជលផលទឹកសាប និងធនធានឆ្នេរសមុទ្ទ និង (៥) ការការពារមិនបានត្រឹមត្រូវនូវតំបន់ជីវៈចម្រុះ និងតំបន់ការពារ។

៣២. ចំណូលជាង ២០% នៃគ្រួសារក្រីក្រគឺមានប្រភពមកពីធនធានរួម ភាគច្រើន គឺការនេសាទនិងព្រៃឈើ និង មានតួនាទីជាប្រព័ន្ធសុវត្ថិភាពនៃជីវភាពរស់នៅពេលដែលគេរកប្រភពដទៃទៀតមិនបាន។ កិច្ចប្រឹងប្រែងដើម្បីផ្តល់ឱ្យសិទ្ធិជាផ្លូវការរបស់សហគមន៍ ក្នុងការទទួលផលនេសាទនិងព្រៃឈើ គឺស្ថិតនៅក្នុងដំណាក់ការដំបូងនៅឡើយ ហើយសមត្ថភាពដែលជួយដល់ការគ្រប់គ្រងសហគមន៍ ឬក៏ ការធានាឱ្យបាននូវការអនុវត្តន៍ច្បាប់ឱ្យបានគ្រប់គ្រាន់ដើម្បីការពារផលប្រយោជន៍ជនក្រីក្រដែលអាចរងគ្រោះ ដោយពាណិជ្ជករធំៗ គឺនៅមានក៏រិតនៅឡើយ។ ថ្វីបើការធ្វើសម្បទានព្រៃឈើឯកជនទាំងឡាយ ដែលមានលក្ខណៈមិនល្អខាងបរិស្ថាន ឬដែលមិនចំណេញខាងសេដ្ឋកិច្ច ត្រូវបានលុបចោលក្តី ក៏ការកាប់ឈើខុសច្បាប់ នៅតែបន្ត។ រាជរដ្ឋាភិបាលបានធ្វើសម្បទាននេសាទឯកជនជាច្រើននៅក្នុងបឹងទន្លេសាប ឱ្យក្រុមសហគមន៍ គ្រប់គ្រង។ ទោះបីជាប្រការនេះគឺជាជំហានដ៏សំខាន់មួយឆ្ពោះទៅកាន់ការលើកកំពស់លទ្ធភាពរបស់ជនក្រីក្រក្នុង
ការទទួលបាននូវធនធាននេសាទក្តី ចាំបាច់ត្រូវតែមានការពង្រឹងបន្ថែមទៀត នូវក្របខ័ណ្ឌច្បាប់ និងសមត្ថភាពនៅមូលដ្ឋាន ដើម្បីធានាឱ្យសហគមន៍ទទួលបាននូវអត្ថប្រយោជន៍ ពីការគ្រប់គ្រងធនធាននេសាទ ប្រកបដោយចេរភាព។

៣៣. **អាងទន្លេសាប** - នៅជុំវិញបឹងទន្លេសាប ប្រជាជនប្រហែល ១,៧ លាននាក់ ពឹងផ្អែកលើរបរនេសាទសម្រាប់ជីវភាពរស់នៅ។ នៅក្នុងរដូវប្រាំង ទន្លេសាបហូរចូលទៅក្នុងទន្លេមេគង្គ និងទន្លេបាសាក់ នៅជិតក្រុងភ្នំពេញ។ ទន្លេទាំងពីរនេះ ហូរទៅកាន់តំបន់ដីសណ្តរមេគង្គនៃប្រទេសវៀតណាម។ នៅពេលដែលទឹកទន្លេមេគង្គឡើងជាមួយនឹងទឹកភ្លៀងរដូវវស្សា ទន្លេសាបហូរបញ្ច្រាស់ទៅកាន់ទិសពាយព្យចាក់ចូលបឹងទន្លេសាប ដែលបង្កើនកម្ពស់ទឹករបស់វាឡើងទៅដល់ ១០ ម៉ែត្រ និង បង្កើនផ្ទៃទឹករបស់វាពី ៣.០០០ គីឡូម៉ែត្រការ៉េដល់ទៅ ១៦.០០០ គីឡូម៉ែត្រការ៉េ។ វដ្តទឹកដ៏ពិសេសនេះ បង្កើតតំបន់ព្រៃឈើលិចទឹកដ៏ធំ ដែលមានជីវៈចម្រុះជាច្រើន និង ផ្តល់ប្រូតេអ៊ីនចំនួន ៤០-៧០% នៃតំរូវការរបស់ប្រជាជនកម្ពុជា។ ទោះបីជាមានសម្បត្តិធម្មជាតិ និងបរិស្ថានដ៏សម្បូរណ៍បែបនៃអាងទន្លេសាបក្តី ក៏តំបន់នេះ គឺជាតំបន់មួយក្នុងចំណោម តំបន់ដ៏ក្រីក្របំផុតនៅក្នុងប្រទេសកម្ពុជា។ កំណើនប្រជាជនមានល្បឿនលឿន ប្រជាជនជាយុវវ័យ និង សូចនាករសង្គមមានក៏រិតទាប ។

ភាពប្រណាំងប្រជែង បានដាក់សំពាធលើធនធានធម្មជាតិ ដែលធ្វើឱ្យអាងទាំងមូលនេះស្ថិត ក្នុងហានិភ័យដោយការទាញយកប្រយោជន៍ច្រើនហួសពេក។

### ឈ. កិច្ចសហប្រតិបត្តិការក្នុងតំបន់

៣៤. រាជរដ្ឋាភិបាលចាត់ទុកសមាហរណកម្មតំបន់និងអន្តរជាតិគឺជាសសរទ្រូងដ៏សំខាន់នៃរបៀបវារៈអភិវឌ្ឍន៍របស់ខ្លួន។ កិច្ចសហប្រតិបត្តិការតំបន់នឹងផ្តល់ឱ្យកម្ពុជានូវសេដ្ឋកិច្ចមាត្រដ្ឋាន និង កាលានុវត្តភាពក្នុងការទាក់ទាញវិនិយោគ បង្កើតការងារ បង្កើតប្រាក់ចំណូល និង កាត់បន្ថយភាពក្រីក្រ។ គន្លឹះនៃការប្តេជ្ញាចិត្តរបស់កម្ពុជាចំពោះការលើកកំពស់ទំនាក់ទំនងក្នុងតំបន់ គឺតួនាទីដ៏សកម្មរបស់ប្រទេសនេះ នៅក្នុងមហាអនុតំបន់មេគង្គ (GMS) និងសមាជិកភាពរបស់ខ្លួននៅក្នុងសមាគមនៃប្រទេសជាតិអាស៊ីអគ្នេយ៍ (ASEAN)។ កម្ពុជា ក៏កំពុងធ្វើការខិតខំប្រឹងប្រែងផងដែរដើម្បីធ្វើសុខដុមនីយកម្មនូវគោលនយោបាយពាណិជ្ជកម្មនិងវិនិយោគនៅក្នុងបរិបទនៃ ASEAN និងតំបន់ពាណិជ្ជកម្មសេរីអាស៊ីបូព៌ា។

## ២. យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល

### ក. គោលដៅនិងយុទ្ធសាស្ត្រអភិវឌ្ឍន៍

៣៥. យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ដូចមានឆ្លុះបញ្ចាំងនៅក្នុងយុទ្ធសាស្ត្រចតុកោណ គឺផ្អែកលើ SEDP II និង NPRS និង គឺជាសំយោគនៃអាទិភាពទាំងឡាយនៃឯកសារទាំងនេះ។[១៤] SEDP II គឺជាកម្មវិធីអភិវឌ្ឍន៍ដ៏ពេញលេញមួយ ដែលផ្តោតការយកចិត្តទុកដាក់លើការជម្រុញកំណើន សមាហរណកម្មតំបន់ និង ការកាត់បន្ថយភាពក្រីក្រ។ វាគឺជាឯកសារផែនការគោលរបស់រាជរដ្ឋាភិបាល។ NPRS គឺពឹងផ្អែកយ៉ាងជិតស្និទ្ធលើ SEDP II និងកំណត់របៀបវារៈកាត់បន្ថយភាពក្រីក្រ ដោយផ្តល់នូវក្របខ័ណ្ឌការងារដែលជួយសំរួលការគាំទ្រដោយដៃគូ អភិវឌ្ឍន៍អន្តរជាតិ និង សូចនាករមួយដ៏ពេញលេញដើម្បីតាមដានវឌ្ឍនភាពឆ្ពោះទៅកាន់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ NPRS កំណត់លទ្ធផលកាត់បន្ថយភាពក្រីក្រជាអាទិភាពចំនួនប្រាំបី ដែលលទ្ធផលនិមួយៗមានសកម្មភាពលំអិត: (១) រក្សាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច (២) កែលំអជីវភាពនៅជនបទ (៣) ពង្រីកកាលានុវត្តភាពការងារ (៤) លើកកំពស់សមត្ថភាព (៥) ពង្រឹងស្ថាប័ននិងកែលំអអភិបាល-កិច្ច (៦) កាត់បន្ថយភាពងាយរងគ្រោះ និង ពង្រឹងការចូលរួមសង្គម (៧) ជម្រុញសមធម៌យេនឌ័រ (៨)

---

[១៤] យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រគឺជាឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ប្រទេស។

យកចិត្តទុកដាក់លើប្រជាជនតាមរយៈសុខភាពមាតា ការបង្កើនលទ្ធភាពទទួលការអប់រំ និង កាលានុវត្តភាពនៅជនបទ។

៣៦. ក្រោយការបង្កើតរាជរដ្ឋាភិបាលថ្មីនៅក្នុងខែ កក្កដា ឆ្នាំ ២០០៤ សម្តេចនាយករដ្ឋមន្ត្រីបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណ ដែលសំដៅដឹកនាំការអនុវត្តន៍របៀបវារៈគោលនយោបាយសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលក្នុងអាណត្តិគ្រប់គ្រងដែលនៅសល់របស់ខ្លួន។ យុទ្ធសាស្ត្រចតុកោណបង្ហាងនូវជ្រុងចតុកោណកែងមួយចំនួនដែលជាប់ទាក់ទងគ្នាដោយកំណត់យកអភិបាលកិច្ចជាស្នូលនៃយុទ្ធសាស្ត្រ។ ចតុកោណកែងដទៃទៀត យកចិត្តទុកដាក់លើបរិស្ថានដែលគេចង់បានដើម្បីអនុវត្តយុទ្ធសាស្ត្រ និងលើការជម្រុញកំណើនសេដ្ឋកិច្ចតាមរយៈកិច្ចអភិវឌ្ឍន៍វិស័យកសិកម្ម ការស្តារឡើងវិញនិងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត កិច្ចអភិវឌ្ឍន៍វិស័យឯកជន និងការកសាងសមត្ថភាព និងការអភិវឌ្ឍន៍ធនធានមនុស្ស (សូមមើលប្រអប់ ១)។ ទោះបីជាមានទស្សនទានរឹងមាំក្តីក៏បច្ចុប្បន្ននេះ យុទ្ធសាស្ត្រចតុកោណនៅខ្វះផែនការសកម្មភាព និងចាំបាច់ត្រូវកំណត់អាទិភាព និងថវិកាសំរាប់អនុវត្ត។ ដើម្បីអនុវត្តចក្ខុវិស័យអភិវឌ្ឍន៍ដែលបានលើកឡើងនៅក្នុងយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍របស់ខ្លួនបានឯកភាពគ្នាលើការរៀបចំឯកសារផែនការតែមួយ ពោល គឺផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្នុងរយៈពេលវដ្តផែនការថ្មីខាងមុខនេះសម្រាប់ឆ្នាំ ២០០៦-២០១០។

## ខ. ការគៀងគរធនធាន និង វិនិយោគ

៣៧. NPRS និង យុទ្ធសាស្ត្រចតុកោណគឺផ្អែកលើការព្យាករលើអត្រាកំណើន GDP ពិតប្រចាំឆ្នាំជាមធ្យម ៦-៧%។ ប្រការនេះ តម្រូវឱ្យមានការកើនឡើងយ៉ាងច្រើននៃបរិមាណ និងផលិតភាពនៃវិនិយោគលើសពីចំនួនប៉ាន់ស្មាន ២០% នៃ GDP ក្នុងឆ្នាំ ២០០៤។ លើសពីនេះទៀត សកម្មភាព និង វិនិយោគទាំងឡាយដែលបានកំណត់នៅក្នុង NPRS តម្រូវឱ្យមានហិរញ្ញប្បទានជាង ១,៥ ពាន់លានដុល្លារពីឆ្នាំ ២០០៣-២០០៥។ ដោយហេតុថា ជំនួយសម្បទានកាន់តែមានក៏រិត ចាំបាច់ត្រូវធ្វើការខិតខំប្រឹងប្រែងទ្វេរដង ក្នុងការគៀងគរចំណូលក្នុងស្រុកដើម្បីធ្វើហិរញ្ញប្បទានសំរាប់ជំរុញកំណើនសេដ្ឋកិច្ច និង ការកាត់បន្ថយភាពក្រីក្រ។ ដូចមានបង្ហាញនៅក្នុងយុទ្ធសាស្ត្រចតុកោណ ប្រការនេះ តម្រូវឱ្យមានកិច្ចខំប្រឹងប្រែងច្រើន ដើម្បីកែលំអការប្រមូលចំណូលពន្ធដារ និងចំណូលក្រៅពន្ធដារ ដោយកាត់បន្ថយអំពើពុករលួយ និង ការគេចពន្ធ រំលាយរចនាសម្ព័ន្ធនៃការលើកលែងពន្ធ ពង្រីកមូលដ្ឋានពន្ធ និង ពង្រឹងរដ្ឋបាលពន្ធដារនិងគយ។ អាទិភាពបំពេញបន្ថែមមួយទៀត គឺការកែលំអប្រសិទ្ធិភាពចំណាយ សំដៅសំរេចបានលទ្ធផលជាអាទិភាព។ បន្ថែមលើនេះទៅទៀត ចាំបាច់ត្រូវមានការកែលំអរបរិយាកាសវិនិយោគ និង ធ្វើការកាត់បន្ថយចំណាយនៃការធ្វើអាជីវកម្មសម្រាប់វិស័យឯកជន។

**ប្រអប់១: យុទ្ធសាស្ត្រចតុកោណកម្ពុជា ឆ្នាំ ២០០៤-២០០៨**

យុទ្ធសាស្ត្រចតុកោណ ឆ្នាំ ២០០៤-២០០៨ មានគោលបំណងដើម្បីលើកកំពស់កំណើនសេដ្ឋកិច្ច បង្កើតការងារ សមធម៌ និង យុត្តិធម៌សង្គម តាមរយៈការអនុវត្តន៍ SEDP II និង NPRS ។ យុទ្ធសាស្ត្រចតុកោណ មានរចនាសម្ព័ន្ធជា**ចតុកោណ-កែងជាប់ទាក់ទងគ្នា**។

**ទីមួយ** ស្នូលនៃយុទ្ធសាស្ត្រគឺ **អភិបាលកិច្ចល្អ** ដោយយកចិត្តទុកដាក់លើវិស័យចំនួនបួន: (១) កិច្ចប្រឹងប្រែងប្រឆាំងអំពើពុករលួយ (២) ច្បាប់និងប្រព័ន្ធយុត្តិធម៌ (៣) រដ្ឋបាលសាធារណៈ និង វិមជ្ឈការ និង (៤) ការរំសាយកងកម្លាំងប្រដាប់អាវុធ ។

**ទីពីរ** បរិស្ថានសម្រាប់ការអនុវត្តន៍យុទ្ធសាស្ត្រនេះ រួមមានសមាសភាគចំនួនបួន: (១) សន្តិភាព ស្ថេរភាព និងសណ្តាប់ធ្នាប់សង្គម (២) ភាពជាដៃគូជាមួយភាគីពាក់ព័ន្ធ រួមទាំងវិស័យឯកជន ដៃគូអភិវឌ្ឍន៍ និង សង្គមស៊ីវិល (៣) ការស្តារឡើងវិញនិងការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និង (៤) ការកសាងសមត្ថភាព និងកិច្ចអភិវឌ្ឍន៍ធនធានមនុស្ស ។

**ទីបី** "ចតុកោណកំណើន" ជាយុទ្ធសាស្ត្រទាំងបួន គឺ: (១) ផលិតភាព ចំរុះភាព និងភាពប្រកួតប្រជែងនៃវិស័យកសិកម្ម (២) កំណើនវិស័យឯកជន និង បង្កើតការងារ (៣) ការស្តារឡើងវិញ និងការកសាងហេដ្ឋារចនាសម្ព័ន្ធជារូបវ័ន្ត និង (៤) ការកសាងសមត្ថភាព និង កិច្ចអភិវឌ្ឍន៍ធនធានមនុស្ស ។

**ទីបួន** "ចតុកោណកំណើន" ជាយុទ្ធសាស្ត្រនិមួយៗមានជ្រុងបួន:

- ចតុកោណកំណើន ១: (១) ការកែលំអផលិតភាព និងចំរុះភាពកសិកម្ម (២) កំណែទម្រង់ដីធ្លី និង ការបោស-សំអាតមីន (៣) កំណែទម្រង់វិស័យនេសាទ និង (៤) កំណែទម្រង់វិស័យព្រៃឈើ ។
- ចតុកោណកំណើន ២: (១) ការពង្រឹងវិស័យឯកជននិងវិនិយោគ (២) ការលើកស្ទួយឧស្សាហកម្មខ្នាតតូច (SMEs) (៣) ការបង្កើតការងារ និង ការកែលំអល័ក្ខខ័ណ្ឌការងារ និង (៤) ការបង្កើតប្រព័ន្ធសុវត្ថិភាពសង្គមសម្រាប់មន្ត្រី បុគ្គលិក និង កម្មករ ។
- ចតុកោណកំណើន ៣: (១) ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (២) ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារា-សាស្ត្រ (៣) ថាមពលនិងបណ្តាញអគ្គិសនី និង (៤) ព័ត៌មានវិទ្យានិងទូរគមនាគមន៍ ។

- ចតុកោណកំណើន ៤: (១) ការលើកកំពស់គុណភាពវិស័យអប់រំ (២) ការលើកស្ទួយសេវាសុខាភិបាល (៣) សមធមិយេនឌ័រកាន់តែច្រើន និង (៤) គោលនយោបាយប្រជាសាស្ត្រ ផ្អែកលើគោលការណ៍ច្បាស់។

## គ. តួនាទីនៃជំនួយអភិវឌ្ឍន៍

៣៨. ជំនួយបរទេសបានរួមចំណែកដល់ការអនុវត្តន៍គម្រោងអភិវឌ្ឍន៍វិស័យសាធារណៈធំៗនៅកម្ពុជា។ ដោយគិតពីឆ្នាំ ១៩៩២ ដល់ឆ្នាំ ២០០៣ កម្ពុជាទទួលបានជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ចំនួន ៥,២ ពាន់លានដុល្លារ ក្នុងនោះមាន ២៨% បានមកពីប្រភពពហុភាគី, ៦៤% ពីប្រភពឧភតោភាគី និង ៨% ពីអង្គការ ក្រៅរដ្ឋាភិបាល (NGOs)។ ជំនួយគ្មានសំណងគឺមានចំនួន ៨០% នៃ ODA។ ក្នុងឆ្នាំ ២០០៣ ប្រាក់ចំនួនប្រហែល ៥៤៦ លានដុល្លារជា ODA ត្រូវបានបញ្ចេញ ដែលស្មើនឹងជិត ៨% នៃ GDP។ ការសន្យាដែលបានធ្វើឡើងនៅក្នុងកិច្ចប្រជុំប្រចាំឆ្នាំនៃក្រុមពិគ្រោះយោបល់បានកើនឡើងពី ៤៧១ លានដុល្លារក្នុងឆ្នាំ ១៩៩៩ ដល់ ៥៤៨ លានដុល្លារក្នុងឆ្នាំ ២០០០ និង ៦៣៥ លានដុល្លារក្នុងឆ្នាំ ២០០២។ ដោយផ្អែកលើនិយមន័យកែប្រែនៃ ODA អ្នកផ្តល់ជំនួយបានសន្យាទឹកប្រាក់ ចំនួន ៥០៤ លានដុល្លារសំរាប់ឆ្នាំ ២០០៤។[១៥] ផ្អែកលើមូលដ្ឋានធៀបសំរាប់ប្រជាជនម្នាក់ៗ ប្រទេសកម្ពុជាបានទទួល ODA ច្រើនជាងបណ្តាប្រទេសមានប្រាក់ចំណូលទាបដទៃទៀតយ៉ាងច្រើនក្នុងទស្សវត្សរ៍កន្លងមកនេះ។ ជំនួយភាគច្រើន ត្រូវបានប្រើប្រាស់ដើម្បីលើកស្ទួយវិស័យសុខាភិបាល និងអប់រំ កសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និង កសាងសមត្ថភាពស្ថាប័ន។ ចំពោះមុខ តម្រូវការហិរញ្ញវត្ថុដ៏ច្រើនរបស់កម្ពុជា និង ដោយហេតុថា ការគៀងគរចំណូលក្នុងស្រុកមានកំរិត និង មូលដ្ឋានវិស័យឯកជន នៅទន់ខ្សោយ កម្ពុជានឹងបន្តពឹងផ្អែកយ៉ាងច្រើនលើ ODA ក្នុងរយៈពេលជាមធ្យមខាងមុខ។ ប៉ុន្តែ វិធានការដើម្បីបង្កើនធនធានពីក្រៅចាំបាច់ត្រូវ ដើរទន្ទឹមគ្នានឹងប្រសិទ្ធិភាពការងារ ភាពស្អាតស្អំ ដើម្បីប្រើប្រាស់ធនធានអោយមានប្រសិទ្ធិភាព។

៣៩. អាទិភាពដ៏សំខាន់មួយគឺការពង្រឹងសមត្ថភាពនិងប្រសិទ្ធិភាពនៃការគ្រប់គ្រងជំនួយរបស់រាជរដ្ឋាភិបាល ដែលផ្សារភ្ជាប់ទៅនឹង MDGs ដើម្បីសម្រេចបានកាន់តែច្រើនបន្ថែមទៀតនូវភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និងផ្លែផ្កានៃកិច្ចអភិវឌ្ឍន៍។ ថ្វីបើការសម្របសម្រួលជំនួយគឺជាភារកិច្ចរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្តី ជាការចាំបាច់ត្រូវពង្រឹងទំនាក់ទំនង និង ធ្វើសុខដុមនីយកម្មនីតិវិធីជាមួយស្ថាប័នសំខាន់ៗដទៃទៀត ដែលពាក់ព័ន្ធនឹង ODA ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងផែនការផងដែរ។ ចំពោះភាពទន់ខ្សោយបច្ចុប្បន្ននេះ ODA

---

[១៥] និយមន័យកែប្រែនេះរួមមានការផ្លាស់ប្តូរនៃវិធីសាស្ត្រនិងការរាប់បញ្ចូលដែលចូលជាធរមានថ្មីៗនេះ ដើម្បីគោរពតាមនិយមន័យផ្លូវការនៃគណៈកម្មាធិការ/អង្គការជំនួយអភិវឌ្ឍន៍សម្រាប់កិច្ចសហប្រតិបត្តិការនិងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច (DAC/OECD) អំពីជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA)។ ផ្អែកលើនិយមន័យកែប្រែនេះ តួលេខប្រៀបធៀបក្នុងឆ្នាំ ២០០២ គឺមានចំនួន ៥១៤ លានដុល្លារ។

មួយភាគធំ ត្រូវបានចាត់ចែងនៅក្រៅថវិកា ហើយដោយហេតុនេះ វាមានការលំបាកនឹងធ្វើការគណនា។ ការសម្របសម្រួលជំនួយដើម្បីលើកកំពស់ប្រសិទ្ធិភាពអភិវឌ្ឍន៍ ក៏ត្រូវធ្វើការគណនាផងដែរ ដោយហេតុថាជាង ៥០% នៃជំនួយអភិវឌ្ឍន៍ទាំងអស់ ត្រូវបានប្រើប្រាស់សម្រាប់ការកសាងសមត្ថភាព ការឧបត្ថមបន្ថែមប្រាក់បៀវត្សរ៍សំរាប់ការអនុវត្តន៍គម្រោង ដោយមិនមានការសម្របសម្រួលច្បាស់លាស់។ ចំនួនដៃគូអភិវឌ្ឍន៍មួយចំនួនបានផ្តល់ជំនួយ ដោយគ្មានក្របខ័ណ្ឌយុទ្ធសាស្ត្រច្បាស់លាស់ ដែលប្រការនេះ ធ្វើអោយជំនួយមិនមានប្រសិទ្ធិភាពពេញលេញ។ ដោយខ្វះឯកភាពក្នុងក្របខ័ណ្ឌអនុវត្តន៍គំរោង និង ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ធ្វើអោយមានភាពទន់ខ្សោយ ដល់ប្រព័ន្ធគ្រប់គ្រងថ្នាក់ជាតិ និង បង្កើនលើចំណាយផ្សេងៗ។ លើសពីនេះទៀត អនុសាសន៍គោលនយោបាយខុសៗគ្នា ដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ អាចជាកត្តាធ្វើអោយគោលនយោបាយអភិវឌ្ឍន៍មិនប្រកបដោយចេរភាព។

៤០. ប៉ុន្តែ គំនិតផ្តួចផ្តើមមួយចំនួន កំពុងដំណើរការដើម្បីជម្រុញភាពជាដៃគូអភិវឌ្ឍន៍ឱ្យបានប្រសើរឡើង។ គំនិតផ្តួចផ្តើមទាំងនេះ រួមមានវិធានការទាំងឡាយ ដើម្បីអនុវត្តសេចក្តីថ្លែងការណ៍ក្រុងរ៉ូម ស្តីពីសុខុដុមនីយកម្មនៃជំនួយបរទេស ការរៀបចំឡើងវិញ នូវរចនាសម្ព័ន្ធនៃក្រុមការងារបច្ចេកទេសរដ្ឋាភិបាល-អ្នកផ្តល់ជំនួយ (TWGs) នៅក្នុងកម្រិត វិស័យនិងប្រធានបទ ការធ្វើសុខុដុមនីយកម្មនៃយុទ្ធសាស្ត្រប្រចាំប្រទេសដោយ ADB នាយកដ្ឋានអភិវឌ្ឍន៍អន្តរជាតិ របស់ចក្រភពអង់គ្លេស (DFID) និង ធនាគារពិភពលោក និង ការសម្របសម្រួលកម្មវិធីរបស់អង្គការទាំងនេះ ដោយផ្អែកលើឧត្តមភាពប្រៀបធៀប និង ការពឹងផ្អែកកាន់តែច្រើនឡើងលើកម្មវិធីអភិវឌ្ឍន៍ក្នុងទូទាំងវិស័យ។ រាជរដ្ឋាភិបាល ក៏បានសហការផងដែរជាមួយ ADB និង ធនាគារពិភពលោក ក្នុងការរៀបចំឯកសាររួម ស្តីពីនិយាម នីតិវិធីប្រតិបត្តិការដើម្បីកែលំអការអនុវត្តន៍គម្រោងអ្នកផ្តល់ជំនួយ។ ការរៀបចំឯកសារផែនការតែមួយ សម្រាប់ឆ្នាំ ២០០៦-២០១០ ក៏ផ្តល់ផងដែរនូវឱកាសមួយដើម្បីធានាឱ្យបាននូវផែនការអភិវឌ្ឍន៍កាន់តែច្រើន ដោយបង្កើនសុខុដុមនីយកម្មរវាងរាជរដ្ឋាភិបាល និង អ្នកផ្តល់ជំនួយនៅជុំវិញក្របខ័ណ្ឌអភិវឌ្ឍន៍ឯកភាពគ្នាមួយ។

## ឃ. ការវាយតម្លៃរបស់ធនាគារអភិវឌ្ឍន៍អាស៊ីលើយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល

៤១. ដំណើរការរៀបចំ SEDP II និង NPRS បានដាក់ឱ្យអនុវត្តនូវអភិក្រម (Approach) និងប្រធានបទថ្មីៗចំពោះការធ្វើផែនការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា ដែលរួមមាន (១) ការចូលរួមដោយចំហរនិងច្រើនដោយភាគីពាក់ព័ន្ធទាំងឡាយ (២) ការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការនេះ (៣) ការយកចិត្តទុកដាក់កាន់តែច្រើនលើប្រធានបទអន្តរវិស័យ រួមមានអភិបាលកិច្ច ស្នាដៃរបស់វិស័យសាធារណៈ និង

អភិវឌ្ឍន៍វិស័យឯកជន និង (៤) ការប្រើសូចនាករឯកភាពគ្នាដែលផ្សារភ្ជាប់ទៅនឹង MDGs ដើម្បីត្រួតពិនិត្យវឌ្ឍនភាពនៅក្នុងការកាត់បន្ថយភាពក្រីក្រ។

៤២. ក្នុងត្រីមាសទីមួយឆ្នាំ ២០០៤ ការសិក្សាលើការអនុវត្តន៍ NPRS ឆ្នាំទីមួយដោយរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយសំខាន់ៗ បានកត់សំគាល់ភាពចាំបាច់ក្នុងការ (១) ដោះស្រាយភាពទន់ខ្សោយនៅក្នុងការកំណត់តំលៃ និងអាទិភាព (២) កែលំអទំនាក់ទំនងរវាងយុទ្ធសាស្ត្រនិងថវិកា និង ការដាក់ឱ្យអនុវត្តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (៣) ពង្រីកការទទួលខុសត្រូវ ភាពជាម្ចាស់ និង ការសម្របសម្រួលរបស់រដ្ឋាភិបាល (៤) កសាងសមត្ថភាពជាតិដើម្បីតាមដានភាពក្រីក្រ ក៏ដូចជាដើម្បីវាយតម្លៃកម្មវិធីនិងគោលនយោបាយជាគន្លឹះទាំងឡាយផងដែរ និង (៥) ពង្រឹងបន្ថែមទៀតនូវយុទ្ធសាស្ត្រអភិវឌ្ឍន៍ជនបទនិងហេដ្ឋារចនាសម្ព័ន្ធដែលជួយដល់ប្រជាពលរដ្ឋក្រីក្រ។ ដៃគូអភិវឌ្ឍន៍ច្រើនតែនាំមុខក្នុងការរៀបចំយុទ្ធសាស្ត្រដែលជាហេតុនាំអោយមានការកាត់បន្ថយការចូលរួម និងការកំណត់អាទិភាពរបស់រាជរដ្ឋាភិបាល។

៤៣. យុទ្ធសាស្ត្រចតុកោណតំណាងឱ្យកិច្ចប្រឹងប្រែងដ៏ពិតប្រាកដដោយរាជរដ្ឋាភិបាលដើម្បីបង្ហាញភាពជាម្ចាស់លើដំណើរការអភិវឌ្ឍន៍។ យុទ្ធសាស្ត្រនេះកសាងឡើងដោយផ្អែកលើការវិភាគដ៏ជាក់លាក់អំពីមូលហេតុនៃភាពក្រីក្រ និងបានកំណត់ថា អភិបាលកិច្ចគឺជាល័ក្ខខ័ណ្ឌបឋមដ៏សំខាន់បំផុតសម្រាប់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច។ ប៉ុន្តែចំណុចដៅកំណើននៃយុទ្ធសាស្ត្រចតុកោណហាក់បីដូចជាធ្វើការសង្កត់ខ្លាំងពេក ចំពោះផលប៉ះពាល់ជាអវិជ្ជមានខ្លាំងនៃការបញ្ចប់ MFA ដែលត្រូវបានព្យាករណ៍ថានឹងបន្ថយល្បឿនកំណើនសេដ្ឋកិច្ចមកត្រឹម ២,៣% ក្នុងឆ្នាំ ២០០៥ និង ចំពោះកង្វះជម្រើសភ្លាមៗជំនួសឱ្យវិស័យកាត់ដេរដែលជាវិស័យនាំមុខនៃកំណើន។ លើសពីនេះទៀត ការដាក់បញ្ចូល កំណែទម្រង់និងការផ្លាស់ប្តូរដែលចាំបាច់គឺមានលក្ខណៈធំទូលាយពេក។ ការអនុវត្តន៍ប្រកបដោយប្រសិទ្ធិភាព តម្រូវឱ្យមានការរៀបចំរបៀបវារៈមួយដែលមានកំណត់មុខព្រួញ និងតំលៃច្បាស់លាស់។

## ៣. បទពិសោធន៍អភិវឌ្ឍន៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី

### ក. ឥទ្ធិពលនៃជំនួយកន្លងមក

៤៤. ADB បានចាប់ផ្តើមផ្តល់ប្រាក់កំចីឡើងវិញឱ្យដល់កម្ពុជាក្នុងឆ្នាំ ១៩៩២ ហើយគិតត្រឹមថ្ងៃទី ៣១ ខែតុលា ឆ្នាំ ២០០៤ ឥណទានវិស័យសាធារណៈរបស់មូលនិធិអភិវឌ្ឍន៍អាស៊ី (ADF) មានចំនួន ៧៧៥.៧០ លានដុល្លារបានត្រូវអនុម័ត។[១៦] ក្នុងចំនួននេះ ឥណទានចំនួន ១១ (២៣៨,៩ លានដុល្លារ) ត្រូវបានបិទ ហើយចំនួន

[១៦] ចំនួននេះជិតមួយភាគបីមានប្រភពចេញពីគម្រោង GMS។

២១ទៀតកំពុងមានសកម្មភាព (៥៣៦,៨ លានដុល្លារ)។ ក្នុងចំណោមឥណទានសកម្មទាំង២១នេះ ឥណទានចំនួន ១៧ ត្រូវបានប្រកាសសុពលភាព (៤៤០,៥០ លានដុល្លារ)និង ឥណទានចំនួនបួនដែលមានចំនួន ៩៦,៣៥ លានដុល្លារកំពុងរង់ចាំការប្រកាសសុពលភាព ដោយសារការចុះហត្ថលេខាលើកិច្ចព្រមព្រៀងឥណទានត្រូវបានពន្យារពេលដោយត្រូវរង់ចាំការបង្កើតរាជរដ្ឋាភិបាលថ្មី។[១៧] ចាប់ពីឆ្នាំ ១៩៩២ ដល់ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៤ ជំនួយ បច្ចេកទេស (TA) គ្មានសំណងចំនួន ១១២ ដែលមានទឹកប្រាក់សរុប ៧៣,៦៤ លានដុល្លារត្រូវបានអនុម័ត។ ក្នុងចំនួននេះ TAs ចំនួន ៣៤ (៣០%) ដែលមានទឹកប្រាក់ចំនួន ១៨,៧៧ លានដុល្លារ គឺជា TAs សម្រាប់រៀបចំគម្រោង ហើយ TAs ដែលនៅសល់ទាំង៧៨ (៧០%) ដែលមានទឹកប្រាក់ ៥៤,៨៧ លានដុល្លារ គឺជា TAs សម្រាប់ផ្តល់ប្រឹក្សា និង ប្រតិបត្តិការ ដែលភាគច្រើនគឺសម្រាប់ការកសាងសមត្ថភាព និង ការពង្រឹងស្ថាប័ន។ ADB ក៏បានអនុម័តផងដែរ នូវ TAs មូលនិធិជប៉ុនសម្រាប់ការកាត់បន្ថយភាពក្រីក្រ (JFPR) ដែលមានទឹកប្រាក់ចំនួន ៩,៩ លានដុល្លារ។ បច្ចុប្បន្ន គេឃើញមាន TAs កំពុងដំណើរការចំនួន ៣០ ដែលមានទឹកប្រាក់ចំនួន ១៧,៥៥ លានដុល្លារ។

៤៥. ជំនួយរបស់ ADB ជូនដល់កម្ពុជាអាចត្រូវបានចែកចេញជាបីរយៈពេលៈ (១) ឆ្នាំ ១៩៩២-១៩៩៥ ដែលអនុវត្តយុទ្ធសាស្ត្រអន្តរកាលមួយដែលផ្តោតលើជំនួយស្តារសម្បទាឡើងវិញ និង ការស្តារឡើងវិញ (២) ឆ្នាំ ១៩៩៦-២០០០ ដែលអនុវត្តយុទ្ធសាស្ត្រប្រតិបត្តិការប្រចាំប្រទេស (COS) ឆ្នាំ ១៩៩៥ សំដៅប្តូរពីការស្តារសម្បទាឡើងវិញទៅជាកិច្ចអភិវឌ្ឍន៍តាមវិស័យវិញ និង (៣) ឆ្នាំ ២០០១-២០០៤ ដែលអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍សំរាប់ប្រទេសកម្ពុជា (COS) ដែលបានរៀបចំឡើងនៅឆ្នាំ ២០០០។ COS ឆ្នាំ ២០០០ កំណត់ការកាត់បន្ថយភាពក្រីក្រជាគោលដៅចំបងដែលនឹងត្រូវសម្រេចបានតាមរយៈ (១) កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពតាមរយៈកិច្ចអភិវឌ្ឍន៍កសិកម្មនិងជនបទ (២) អភិវឌ្ឍន៍ធនធានមនុស្សនិងសង្គម (៣) ការបង្កើតបរិស្ថានអំណោយផលមួយសម្រាប់កិច្ចអភិវឌ្ឍន៍វិស័យឯកជន។ អភិបាលកិច្ចល្អ គឺជាប្រធានបទអន្តរវិស័យនៃ COS។

---

[១៧] ឥណទានទាំងបួននេះគឺ: ADB. ឆ្នាំ ១៩៩៣-*របាយការណ៍និងអនុសាសន៍របស់ប្រធានជូនចំពោះក្រុមប្រឹក្សាភិបាល ស្តីពីសំណើឥណទានជូនដល់ព្រះរាជាណាចក្រកម្ពុជាសម្រាប់*គម្រោងប្រព័ន្ធធារាសាស្ត្រភាគពាយព្យ និង ឥណទាន ២០៥២-CAM-ADB (ADB. ឆ្នាំ ១៩៩៣-*របាយការណ៍និងអនុសាសន៍របស់ប្រធានជូនចំពោះក្រុមប្រឹក្សាភិបាល ស្តីពីសំណើឥណទានជូនដល់ព្រះរាជាណាចក្រកម្ពុជាសម្រាប់*គម្រោងតភ្ជាប់អគ្គិសនីមហាអនុតំបន់មេគង្គ-GMS)។ ថ្វីបើឥណទានទាំងនេះត្រូវបានចុះហត្ថលេខានៅថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ក្តី ក៏គម្រោងប្រព័ន្ធធារាសាស្ត្រភាគពាយព្យ និង គម្រោងតភ្ជាប់អគ្គិសនី GMS នៅមិនទាន់ត្រូវបានប្រកាសសុពលភាពនៅឡើយ ដោយសារមានការយឺតយ៉ាវក្នុងការដាក់ជូនទូវយោបល់ផ្នែកគតិយុត្តិ។

៤៦. ចាប់តាំងពីពេលចាប់ផ្តើមផ្តល់ឥណទានឡើងវិញក្នុងឆ្នាំ ១៩៩២ គម្រោងចំនួនប្រាំមួយត្រូវបានវាយតម្លៃក្រោយពេលអនុវត្តដោយរបាយការណ៍បញ្ចប់គម្រោង ហើយគម្រោងបីនៃគម្រោងទាំងនេះត្រូវបានចាត់ថ្នាក់ថាបានទទួលជោគជ័យ ឬ បានទទួលជោគជ័យយ៉ាងខ្ពស់។ ក្នុងអំឡុងពេលនេះ របាយការណ៍បញ្ចប់គម្រោង TA (TCRs) ចំនួន ២៩ និង របាយការណ៍សវនកម្មលទ្ធផលការងារ TA (TPAR) ចំនួនប្រាំបី ក៏ត្រូវបានបញ្ចប់ផងដែរ។ ក្នុង TCRs ទាំងនេះ គម្រោងចំនួន ២៨ ត្រូវបានចាត់ថ្នាក់ថា បានទទួលជោគជ័យ ឬ បានទទួលជោគជ័យខ្លាំង។ ក្នុង TPARs ទាំងនេះ គម្រោងមួយត្រូវបានចាត់ថ្នាក់ថាបានទទួលជោគជ័យខ្លាំង គម្រោងចំនួនប្រាំបានទទួលជោគជ័យ និង គម្រោងចំនួនពីរ បានទទួលជោគជ័យមួយចំណែក។ TAs ដែលបានទទួលជោគជ័យមួយចំណែកគឺ TAs ផ្តល់ប្រឹក្សាលើការកសាងសមត្ថភាព។ លទ្ធផលការងារមិនបានល្អនៅក្នុងផ្នែកនេះគឺដោយសារកង្វះការយកចិត្តទុកដាក់ចំពោះការពង្រឹងស្ថាប័ន ដែលជាលទ្ធផល ធ្វើឱ្យស្ថាប័នទាំងឡាយបរាជ័យក្នុងការសម្រេចបានលទ្ធផលគម្រោង។

៤៧. ចំនួនតិចតួចនៃគម្រោងដែលបានបញ្ចប់ គួបផ្សំនឹងរយៈពេលខ្លីចាប់តាំងពីពេលបញ្ចប់ ធ្វើឱ្យគេមានការលំបាកក្នុងការវាយតម្លៃលើផលប៉ះពាល់ទូទៅនៃប្រតិបត្តិការរបស់ ADB នៅក្នុងប្រទេសកម្ពុជា។ លទ្ធផលកំពុងមានការវិវត្តនៅឡើយ។ លើសពីនេះទៀត ចំពោះមុខកំណើននៃការយកចិត្តទុកដាក់លើអភិក្រមក្នុងទូទាំង-វិស័យ (SWAps) គេកំពុងតែមានការលំបាកក្នុងការញែកលទ្ធផលអភិវឌ្ឍន៍ដែលអាចផ្សារភ្ជាប់ទៅនឹងអន្តរាគមន៍ ADB តែឯកឯង ជាជាងការគួបផ្សំជាមួយនឹងអន្តរាគមន៍របស់ដៃគូអភិវឌ្ឍន៍ដទៃទៀត។ លទ្ធផលគម្រោងក៏ទទួលផលប៉ះពាល់ផងដែរពីកត្តាខាងក្រៅទាំងឡាយ ដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់។ ផ្អែកលើលទ្ធផលដែលកំពុងវិវត្តនៅឡើយនេះ ការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេសថ្មីៗមួយ (CAPE) សម្រាប់ប្រទេសកម្ពុជា បានសន្និដ្ឋានថា កម្មវិធីជំនួយជារួមរបស់ ADB ក្នុងអំឡុងពេលឆ្នាំ ១៩៩២-២០០២ គឺមានលក្ខណៈឆ្លើយតប និងសមស្រប។[១៨] ប៉ុន្តែ CAPE ផ្តល់ជាអនុសាសន៍ថា (១) គេត្រូវដោះស្រាយបញ្ហាអភិបាលកិច្ចឱ្យបានច្បាស់លាស់ក្នុងពេលអនាគត (មិនមែនគ្រាន់តែជាប្រធានបទអន្តរវិស័យប៉ុណ្ណោះទេ) ដើម្បីឱ្យការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចអាចត្រូវបានកែលំអជាបុព្វល័ក្ខខ័ណ្ឌមួយសម្រាប់កំណើនប្រកបដោយចីរភាព (២) គេត្រូវយកចិត្តទុកដាក់បន្ថែមទៀតលើការបង្កើតបរិយាកាសអំណោយផលសម្រាប់កិច្ចអភិវឌ្ឍន៍វិស័យឯកជន ដើម្បីលើកស្ទួយ SMEs និងទាក់ទាញវិនិយោគបរទេសបន្ថែមទៀត (៣) ជំនួយអនាគតគប្បីត្រូវកំណត់អាទិភាពសម្រាប់អោយមានលទ្ធផលកាន់តែមានប្រសិទ្ធិភាព ដោយប្រើឧត្តមភាពដែល ADB មានប្រៀប (ឧទាហរណ៍

---

[១៨] ការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេសមួយសម្រាប់ប្រទេសកម្ពុជា ត្រូវបានធ្វើឡើងដោយនាយកដ្ឋានវាយតម្លៃប្រតិបត្តិការរបស់ ADB ក្នុងឆមាសទីពីរនៃឆ្នាំ២០០៣ ដើម្បីវាយតម្លៃលទ្ធផលការងារនៃកម្មវិធីជំនួយប្រចាំប្រទេសរបស់ ADB ពីឆ្នាំ ១៩៩២- ២០០២។

លទ្ធផលការងារតាមវិស័យ និងកម្រិតនៃអន្តរាគមន៍របស់ ADB នៅក្នុងវិស័យនោះ ប្រៀបធៀបទៅនឹងស្ថាប័នផ្តល់មូលនិធិដទៃទៀត) គួបផ្សំ ជាមួយនឹងតម្រូវការរបស់ប្រទេស ។

៤៨. CAPE បានកំណត់ចំណុចខ្លាំងនិងចំណុចខ្សោយរបស់កម្មវិធីជំនួយទូទៅរបស់ ADB ។ ចំណុចខ្លាំងរបស់ ADB ផ្តើមចាប់ពីភាពឆ្លើយតបទៅនឹងតម្រូវការ ដោយសារ ADB ផ្តល់ជំនួយបានលឿននិងបត់បែនទៅតាមការជាក់ស្តែង ជាពិសេស ក្នុងអំឡុងពេលនៃតំណាក់កាលស្រោចស្រង់ឡើងវិញនៃកិច្ចអភិវឌ្ឍន៍កម្ពុជានៅដើមទស្សវត្សរ៍ ១៩៩០ និង នៅក្នុងអំឡុងពេលនៃគ្រោះអាសន្នបណ្តាលមកពីទឹកជំនន់និងគ្រោះរាំងស្ងួតក្នុងឆ្នាំ ២០០១-២០០២ ។ កម្មវិធីរបស់ ADB មានទំហំជាមធ្យម ៦១ លានដុល្លារក្នុងមួយឆ្នាំ និង រួមមានឥណទានដែលផ្តោតលើការបង្កើតល័ក្ខខ័ណ្ឌទាំងឡាយសម្រាប់កិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច ក៏ដូចជាឥណទានផ្សេងៗដែលឆ្លើយតបទៅនឹងបញ្ហាភាពក្រីក្រដោយផ្ទាល់ ។ រាជរដ្ឋាភិបាលបានវាយតម្លៃខ្ពស់លើ ទំហំនិងតុល្យភាពនៃផលប័ត្រឥណទាន (portfolio) របស់ ADB ។ CAPE បាន កត់សំគាល់បញ្ហាជាក់លាក់ដូចខាងក្រោមនេះ ។

(១) **អភិក្រមប្រកបដោយជោគជ័យរយៈពេលវែង និង អភិក្រមក្នុងទូទាំងវិស័យ:** ការងារឈានមុខគេរបស់ ADB ក្នុងការជម្រុញអភិក្រមក្នុងទូទាំងវិស័យនៅក្នុងវិស័យអប់រំ ត្រូវបានគេទទួលស្គាល់ ។ គេក៏ឃើញមានការផ្តល់មតិវិជ្ជមានផងដែរលើជំនួយរយៈពេលវែងរបស់ ADB ចំពោះវិស័យអប់រំ សុខាភិបាល ហិរញ្ញវត្ថុ កសិកម្ម និង ការគ្រប់គ្រងធនធានធម្មជាតិ ។

(២) **ទំនាក់ទំនងផ្សារភ្ជាប់ក្នុងតំបន់តាមរយ:GMS:** ការនាំមុខរបស់ ADB នៅក្នុងការលើកស្ទួយទំនាក់ទំនងផ្សារភ្ជាប់រវាងកម្ពុជានិងប្រទេសជិតខាងរបស់ខ្លួន តាមរយៈបណ្តាញផ្លូវ និងអគ្គិសនី និង ក្នុងការពង្រឹងសមត្ថភាពស្ថាប័នដើម្បីដោះស្រាយបញ្ហាទាំងឡាយ ទាំងនៅក្នុងកម្រិតនយោបាយ និង ទាំងនៅក្នុងកម្រិតប្រតិបត្តិការ ត្រូវបានស្វាគមន៍ ។

(៣) **ការពិភាក្សាគោលនយោបាយប្រកបដោយប្រសិទ្ធិភាពនិងជាបន្តបន្ទាប់:** កម្មវិធីដ៏ធំរបស់ ADB និង ការរួមផ្សំគ្នារវាងការផ្តល់ឥណទាននិងជំនួយបច្ចេកទេស បានជម្រុញឱ្យមានការពិភាក្សាគោលនយោបាយប្រកបដោយប្រសិទ្ធិភាព ដែលត្រូវបានវាយតម្លៃខ្ពស់ដោយភាគីពាក់ព័ន្ធទាំងឡាយ ។ ADB បានទ្រទ្រង់ការអនុម័តច្បាប់មួយចំនួន (រួមមាន ច្បាប់ធនាគារ សវនកម្ម ដីធ្លី និង ព្រៃឈើ) ។ ជំនួយបច្ចេកទេស ADB ក៏បានទ្រទ្រង់ផងដែរដល់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ អាជ្ញាធរសវនកម្មជាតិ និង ប្រព័ន្ធ PFM ។

៤៩. ក្នុងចំណោមចំណុចខ្សោយសំខាន់ៗដែលកាត់បន្ថយប្រសិទ្ធិភាពនៃអន្តរាគមន៍របស់ ADB នៅកម្ពុជា CAPE បានកត់សំគាល់ចំណុចដូចតទៅនេះ (១) ការខកខានមិនបានឆ្លើយតបយ៉ាងច្បាស់លាស់ទៅនឹងភាពចាំបាច់នៃការកែលំអអភិបាលកិច្ចតាមរយៈកំណែទម្រង់វិស័យសាធារណៈជាអាទិភាពមួយ (២) វិធីសាស្ត្រចំពោះការពង្រឹងស្ថាប័នមិនមានភាពទូលំទូលាយដែលបាននាំឱ្យមាន TAs ផ្តល់ប្រឹក្សាខាងការកសាងសមត្ថភាពជាច្រើនដែលផ្តោតការយកចិត្តទុកដាក់លើការផ្តល់ការបណ្តុះបណ្តាលបុគ្គល ជាជាងលើកិច្ចអភិវឌ្ឍន៍ស្ថាប័ន និង ការផ្ទេរជំនាញ (៣) កង្វះសូចនាករតាមវិស័យរយៈពេលមធ្យមនៅក្នុងកម្មវិធីជំនួយប្រចាំប្រទេស ដើម្បីត្រួតពិនិត្យវឌ្ឍនភាពឆ្ពោះទៅកាន់គោលដៅ COS ទាំងឡាយ និង MDGs និង (៤) ការសម្របសម្រួលជំនួយនៅទន់ខ្សោយ។ ការសម្របសម្រួលខ្សោយបណ្តាលឱ្យមាន (១) លទ្ធផលដាច់ៗពីគ្នា ភាពត្រួតគ្នានៃកិច្ចប្រឹងប្រែង និង ការដាក់បន្ទុកច្រើនជ្រុលលើរដ្ឋាភិបាល (២) ការកាត់បន្ថយឱកាសដើម្បីគៀងគរការផ្តល់ហិរញ្ញប្បទានរួមគ្នា (៣) អសង្គតភាពនៅក្នុងការអនុវត្តន៍កំណែទម្រង់គោលនយោបាយមួយចំនួននិង (៣) ការពិភាក្សាគោលនយោបាយក្នុងលក្ខណៈរួមគ្នាជាមួយរាជរដ្ឋាភិបាលមានកម្រិត ចំពោះបញ្ហាដ៏ស្មុគស្មាញនិងដ៏មានលក្ខណៈរសើបទាំងឡាយដូចជា អំពើពុករលួយជាដើម។

## ខ. ស្នាដៃនិងស្ថានភាពផលប័ត្រ

៥០. គិតត្រឹមថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៤ ការវាយតំលៃជារួមលើឥណទានកំពុងដំណើរការនៅក្នុងផលប័ត្រ ត្រូវបានគេចាត់ទុកថា មានលក្ខណៈជាទីពេញចិត្តក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍ទាំងឡាយ។ ចំពោះវឌ្ឍនភាពនៃការអនុវត្តន៍ឥណទានចំនួន ១៧ (៨១%) គឺមានលក្ខណៈ "ជាទីគាប់ចិត្ត" ហើយឥណទានចំនួនបួន (១៩%) គឺមានលក្ខណៈ "មិនជាទីគាប់ចិត្ត" ដោយសារឥណទានទាំងនេះមិនទាន់មានសុពលភាពនៅឡើយ ដោយសារមូលហេតុដូចបានលើកឡើងខាងលើ (កថាខ័ណ្ឌ ៤៤)។ ឥណទានទាំងបួននេះក៏មានន័យផងដែរថា ផលប័ត្រចំនួន ១៩% ត្រូវបានចាត់ទុកថាមានហានិភ័យ ដែលមានលក្ខណៈខ្ពស់ជាងកម្រិតមធ្យម ១៨% ក្នុងទូទាំង ADB គិតត្រឹមថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៤។ ការផ្តល់កិច្ចសន្យា (១៤%) និងអត្រាបញ្ចេញឥណទាន (១៧,៨%) គិតត្រឹមថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០០៤ គឺនៅលើកម្រិតមធ្យមក្នុងទូទាំង ADB (១៣,៣% ចំពោះការផ្តល់កិច្ចសន្យា និង ១០,៩% ចំពោះការបញ្ចេញឥណទាន) ក្នុងរយៈពេលដូចគ្នា។ ក្នុងឆ្នាំ ២០០៣ ការផ្តល់កិច្ចសន្យាជាក់ស្តែងមាន ចំនួន ៦១,៨៨ លានដុល្លារ (៨៥,០៨% នៃការព្យាករណ៍សម្រាប់ឆ្នាំនោះ) ហើយការបញ្ចេញឥណទានមានចំនួន ៧៣,២៨ លានដុល្លារ (៧៣,៩៣% នៃការព្យាករណ៍)។ ក្នុងឆ្នាំ ២០០៤ ស្នាដៃនៃការផ្តល់កិច្ចសន្យា (៤៣,៤% នៃការព្យាករណ៍សម្រាប់ឆ្នាំនោះ)

និងការបញ្ចេញឥណទាន (៧៤.៤% នៃការព្យាករណ៍) ត្រូវរងផលប៉ះពាល់ជាអវិជ្ជមាន ដោយការពន្យារពេលនៃការបញ្ចេញកញ្ចប់ឥណទានដែលបណ្តាលមកពីការយឺតយ៉ាវក្នុងការបង្កើត រដ្ឋាភិបាល។

៥១. វិធានការជាច្រើន ត្រូវបានអនុវត្តក្នុងបណ្តាឆ្នាំថ្មីៗនេះ ដើម្បីកែលំអរស្នាដៃផលប័ត្រ។ វិធានការទាំងនេះរួមមាន (១) ដំណើរការបេសកកម្មពិនិត្យផលប័ត្រប្រចាំប្រទេសរួមគ្នាជាមួយធនាគារពិភពលោក និង រាជរដ្ឋាភិបាលដើម្បីសម្របសម្រួលការពិភាក្សាគោលនយោបាយអំពីបញ្ហាទាំងឡាយនៃការអនុវត្តន៍ផលប័ត្រ និង ការកសាងសមត្ថភាព (២) ការត្រួតពិនិត្យកាន់តែហ្មត់ចត់លើគម្រោងកំពុងដំណើរការទាំងឡាយ គួបផ្សំជាមួយនឹងកិច្ចប្រជុំរាល់ពីរខែម្តងជាមួយនាយកគម្រោង និង/ឬ អ្នកចាត់ការគម្រោង ដើម្បីដោះស្រាយឧបសគ្គចំពោះការអនុវត្តន៍ និង (៣) បង្កើនប្រតិភូកម្មគម្រោងមកបេសកកម្មប្រចាំប្រទេសកម្ពុជារបស់កម្ពុជា និងការពិគ្រោះយោបល់ កាន់តែជិតស្និទ្ធជាមួយស្ថាប័នប្រតិបត្តិទាំងឡាយ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយបេសកកម្មប្រចាំប្រទេស ដើម្បីបង្កើនល្បឿននៃការឯកភាពលើលទ្ធកម្មនិងពាក្យសុំដកទឹកប្រាក់។ បេសកកម្មប្រចាំប្រទេសផ្តល់ឱវាទញឹកញាប់ជូនដល់ស្ថាប័នប្រតិបត្តិទាំងឡាយ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អំពីបញ្ហាទាំងឡាយក្នុងការអនុវត្តន៍គម្រោង។ ទោះបីជាមានវឌ្ឍនភាពក្តី ក៏ការវាយតម្លៃកម្មវិធីនិងជំនួយប្រចាំប្រទេស (CAPE) បានកត់សំគាល់ថា គេនៅតែត្រូវការការកសាងសមត្ថភាព ជាពិសេសដើម្បីបណ្តុះបណ្តាលបុគ្គលិក កែលំអរភាពត្រៀមជាស្រេចនៃគម្រោងមុនពេលចាប់ផ្តើមអនុវត្ត ធ្វើសុខដុមនីយកម្មឯកសារនិងនីតិវិធីដេញថ្លៃក្នុងស្រុក និង ធ្វើនិយាមកម្ម ការណែនាំប្រតិបត្តិការ និងសៀវភៅប្រតិបត្តិការ។

៥២. មានបញ្ហាជាក់លាក់ទាក់ទិននឹងគោលនយោបាយ និងគម្រោងដែលត្រូវការការយកចិត្តទុកដាក់បន្ថែមទៀតប្រសិនបើគេចង់ឱ្យស្នាដៃផលប័ត្របានប្រសើរឡើង។ ប្រទេសកម្ពុជា ខ្វះក្របខ័ណ្ឌច្បាប់សម្រាប់ការផ្លាស់ប្តូរទីលំនៅដោយបង្ខំ និងមានតែនីតិវិធីក្រៅផ្លូវការ និងការចាត់ចែងខាងស្ថាប័នដែលគ្មានផែនការតែប៉ុណ្ណោះ។ សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការប្តូរទីលំនៅមួយ ត្រូវបានរៀបចំក្រោមជំនួយបច្ចេកទេស ADB[១៩] ក្នុងឆ្នាំ ២000 និងត្រូវបានតម្លើងទៅជាអនុក្រឹត្យជាមួយនឹងជំនួយនៃជំនួយបច្ចេកទេស (TA) មួយទៀតក្នុងឆ្នាំ ២00៥ ដែលនៅក្នុងនោះ គេចាំបាច់ត្រូវកែលំអរការចាត់ចែងខាងនិយតកម្ម និងការអនុវត្តន៍ គួបផ្សំជាមួយការអភិវឌ្ឍសមត្ថភាព។ ប៉ុន្តែបច្ចុប្បន្ននេះ គេឃើញមានបញ្ហាចម្បងៗ ដែលទាក់ទងនឹងការមិនប្រព្រឹត្តតាមគោលនយោបាយរបស់ ADB ស្តីពីការប្តូរទីលំនៅដោយបង្ខំ បញ្ហាកិច្ចព្រមព្រៀងឥណទានគម្រោង និងផែនការប្តូរទីលំនៅដែលបានអនុម័តរួចហើយ។ ចំណុចពិស្តារនៃការមិនប្រព្រឹត្តតាមគោលការណ៍នៅក្នុងគម្រោង

---

[១៩] ជំនួយបច្ចេកទេសប្រចាំតំបន់ (RETA) ៥៩៣៥ ( ADB។ ឆ្នាំ ២000។ *ជំនួយបច្ចេកទេសសម្រាប់ការកែលំអនិងការកសាងសមត្ថភាពនៃគោលនយោបាយជាតិស្តីពីការប្តូរទីលំនៅ*។ ម៉ានីល)។

កំពុងដំណើរការចំនួនប្រាំពីរត្រូវបានលើកឡើងជូនរាជរដ្ឋាភិបាល ដែលបានទទួលស្គាល់ភាពធ្ងន់ធ្ងរនៃស្ថានភាព និង សន្យាចាត់វិធានការកែតម្រូវ។ បញ្ហាជាក់លាក់ដទៃទៀតដែលទាក់ទិននឹងគម្រោង រួមមាន លទ្ធភាពអនុវត្ត មូលនិធិថែទាំផ្លូវដែលបានអនុម័តរួចហើយ ការបញ្ចេញមូលនិធិរបស់សហភាគីឱ្យបានទាន់ពេលវេលា ការប្រើ-ប្រាស់គណនីមូលនិធិខ្ចីរដ្ឋាភិបាលឱ្យបានសមស្រប និងការកែលំអបន្ថែមទៀតលើនីតិវិធីឯកភាពនៅតាមក្រសួង ពាក់ព័ន្ធ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបង្កើនល្បឿននៃការពិនិត្យឯកសារពាក្យសុំដកនិងលទ្ធកម្ម។ បញ្ហាគោលនយោបាយមួយចំនួន ដូចជាប្រព្រឹត្តិកម្មនៃពន្ធតម្លៃបន្ថែម (VAT) លើវត្ថុធាតុដើមសម្រាប់ការផលិត អគ្គិសនី និងការផ្គត់ផ្គង់ទឹកផឹក និងភាពចាំបាច់នៃគោលនយោបាយដ៏ច្បាស់លាស់មួយស្តីពីឯកជននីយកម្មចំការ កៅស៊ូ និងវត្ថុធាតុដើមកសិកម្ម ក៏ចាំបាច់ត្រូវតែធ្វើការដោះស្រាយផងដែរ។

## ខ. សេចក្តីសន្និដ្ឋាន និង មេរៀនសម្រាប់យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស

៥៣. ក្នុងរយៈពេលប្រតិបត្តិការជាង ១០ ឆ្នាំនៅកម្ពុជា ការពិនិត្យឡើងវិញរបស់ការវាយតម្លៃកម្មវិធី និង ជំនួយប្រចាំប្រទេស (CAPE) និងការវិភាគដទៃទៀត ស្របជាមួយនឹងការពិភាក្សាជាមួយរាជរដ្ឋាភិបាល និង ភាគីពាក់ព័ន្ធដទៃទៀត បានផ្តល់មេរៀនសំខាន់ៗមួយចំនួន។ មេរៀនមួយគឺភាពចាំបាច់នៃភាពអត់ធ្មត់ និង ការព្យាយាម។ ការចូលរួមឡើងវិញរបស់កម្ពុជានៅក្នុងសហគមន៍អន្តរជាតិ មានអាយុទើបតែជាងមួយទស្សវត្សរ៍ ប៉ុណ្ណោះ។ បញ្ហាប្រឈមដ៏ពិសេសចំពោះមុខប្រទេស មានន័យថា អន្តរាគមន៍អភិវឌ្ឍន៍ត្រូវតែមានរយៈពេលវែង ដែលតម្រូវអោយមានហិរញ្ញប្បទានជាបន្តបន្ទាប់លើកម្មវិធីជាច្រើនសំរាប់រយៈពេលវែងមួយ។ ដោយហេតុថា សមត្ថភាពនៅតាមស្ថាប័នរាជរដ្ឋាភិបាល នៅមានកំរិត លទ្ធផលរំពឹងទុកលើការអនុវត្តគម្រោង ត្រូវមានភាព ប្រាកដប្រជា គួបផ្សំជាមួយនឹងការយល់ដឹងច្បាស់លាស់អំពីស្ថានភាពសង្គមនិងនយោបាយនៃអភិបាលកិច្ច និង កំណែទម្រង់។

៥៤. ជំនួយបច្ចេកទេស (TAs) មួយចំនួន ដែលបានផ្តល់នូវការជួយគាំទ្រសមត្ថភាព មានលក្ខណៈមិនគ្រប់ ជ្រុងជ្រោយ។ ប្រការនេះ ត្រូវតែធ្វើការកែលំអរ សំដៅធ្វើអោយជំនួយបច្ចេកទេសមានភាពទូលំទូលាយ និង មានប្រសិទ្ធិភាព។ ក្នុងអនាគត ការយកចិត្តទុកដាក់ត្រូវតែផ្តោតលើការកែលំអប្រព័ន្ធគ្រប់គ្រង ប្រតិបត្តិការ និង ថវិការបស់ស្ថាប័នទាំងមូល។ ការវិភាគស្ថាប័ន គប្បីត្រូវបានធ្វើឡើងជាមុន ហើយការផ្ទេរជំនាញ គប្បីត្រូវ បានបង្កើតឡើងនាពេលបន្ទាប់។ ប្រការទាំងនេះ គប្បីត្រូវបានត្រួតពិនិត្យយ៉ាងទៀងទាត់ក្នុងអំឡុងការអនុវត្ត គំរោង។

៥៥. មេរៀនមួយទៀត គឺថា ការយល់ដឹងអំពីអំពើពុករលួយ គឺមានលក្ខណៈមិនស៊ីជំរៅ ទាំងរាជរដ្ឋាភិបាល និង ទាំងដៃគូអភិវឌ្ឍន៍។ ការវិភាគដ៏ប្រុងប្រយ័ត្នលើកម្រិត ប្រភេទ ឫសគល់ អ្វីដែលមានពីមុន និង ព្រំដែននៃអំពើពុករលួយនៅកម្ពុជា និង ដោយប្រៀបធៀបជាមួយប្រទេសដទៃទៀត គឺចាំបាច់សម្រាប់ឱ្យគេអាចរៀបចំវិធានការប្រឆាំងអំពើពុករលួយជាក់ស្តែងនិងប្រកបដោយប្រសិទ្ធិភាព។ ប្រការនេះ តម្រូវឱ្យមានការទទួលស្គាល់ថា ការកាត់បន្ថយភាពក្រីក្រគឺជាដំណើរការរយៈពេលវែងមួយ ដែលចាប់ផ្តើមពីការពង្រឹងស្ថាប័ន និង ការយល់ដឹងដល់ប្រជាជនដើម្បីអោយពួកគេធ្វើការឆាំងអំពើពុករលួយដែលមានលក្ខណៈជាស្ថាប័ន។

៥៦. ការបង្កើនការសម្របសម្រួលក្នុងចំណោមដៃគូអភិវឌ្ឍន៍ និង ភាគីពាក់ព័ន្ធទាំងឡាយ និង ការពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងជំនួយ នៅតែគឺជាបញ្ហាសំខាន់មួយ។ ថ្វីបើមានសញ្ញាវិជ្ជមាននៃការកែលំអការសម្របសម្រួលដៃគូអភិវឌ្ឍន៍ក្តី ក៏ចាំបាច់ ត្រូវប្រឹងប្រែងបន្ថែមទៀតដើម្បីជៀសវាងភាពប្រទាំងប្រទើសនៅក្នុងការអនុម័តកំណែទម្រង់គោលនយោបាយ និង ដើម្បីកាត់បន្ថយចំណាយប្រតិបត្តិការរបស់រាជរដ្ឋាភិបាល។

៥៧. ការជួយរាជរដ្ឋាភិបាលក្នុងការពង្រឹងទំនាក់ទំនងក្នុងចំណោម NGOs សំខាន់ៗ ក្រុមសហគមន៍ វិស័យឯកជន និង ក្រសួងពាក់ព័ន្ធ គឺជាវិធីមួយដែលនៅក្នុងនោះអភិបាលកិច្ច ការចូលរួមរបស់សហគមន៍ និង ការផ្តល់សេវាកម្ម អាចត្រូវបានជម្រុញទាំងអស់ក្នុងពេលតែមួយ។

# ៤. យុទ្ធសាស្ត្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី

## ក. សេចក្តីសង្ខេបនៃចំណោទអភិវឌ្ឍន៍សំខាន់ៗ

៥៨. គោលដៅចំបងរបស់ ADB នៅប្រទេសកម្ពុជា គឺការកាត់បន្ថយភាពក្រីក្រប្រកបដោយចេរភាព។ ឧបសគ្គចំពោះមុខចំពោះការកាត់បន្ថយភាពក្រីក្រនៅមានច្រើន និង រួមមានកំណើនសេដ្ឋកិច្ចមិនគ្រប់គ្រាន់និងដែលមានមូលដ្ឋានដ៏ចង្អៀត លទ្ធភាពស្តួចស្តើងក្នុងការទទួលសេវាកម្ម និង គុណភាពសេវាកម្មដ៏អន់ ភាពគ្មានដីធ្លី កង្វះលទ្ធភាពប្រើប្រាស់ធនធានធម្មជាតិ ការមិនដាក់បញ្ចូលក្នុងសង្គម អភិបាលកិច្ចអន់ខ្សោយ និង អំពើពុករលួយ។ ចំណោទអភិវឌ្ឍន៍សំខាន់ៗទាំងឡាយ រួមមានៈ ការបង្កើនកាលានុវត្តភាពសម្រាប់ការលូតលាស់ សេដ្ឋកិច្ច ការកែលំអជីវភាព និង ការកាត់បន្ថយភាពងាយរងគ្រោះ និង ការសម្រួលដល់ការចូលរួមក្នុងអភិបាលកិច្ចនៅគ្រប់កម្រិតទាំងអស់។

## ខ. ការយកចិត្តទុកដាក់ជាយុទ្ធសាស្ត្រនៃយុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស

៥៩. ដើម្បីឆ្លើយតបទៅនឹងចំណោទខាងលើ យុទ្ធសាស្ត្ររបស់ ADB នឹងផ្តោតការយកចិត្តទុកដាក់លើការគាំទ្រកំណើនសេដ្ឋកិច្ចដែលមានមូលដ្ឋានទូលាយ កិច្ចអភិវឌ្ឍន៍សង្គមដែលមានការចូលរួម និង អភិបាលកិច្ចល្អ។ ការយកចិត្តទុកដាក់លើអាងទន្លេសាបដើម្បីដោះស្រាយគម្លាតភូមិសាស្ត្រក្នុងកិច្ចអភិវឌ្ឍន៍ និងការយកចិត្តទុកដាក់អនុតំបន់ដើម្បីទទួលអត្ថប្រយោជន៍ពីកាលានុវត្តភាពកាន់តែទូលាយ ត្រូវបានផ្តល់ក្នុងក្របខ័ណ្ឌ GMS ដែលមានការគាំទ្រដោយ ADB ផងដែរ។ រូប ១ បង្ហាញការយកចិត្តទុកដាក់ជាយុទ្ធសាស្ត្រនៃយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេស (CSP)។

៦០. **កំណើនសេដ្ឋកិច្ចដែលមានមូលដ្ឋានទូលាយ** - កំណើនសេដ្ឋកិច្ចដែលមានមូលដ្ឋានទូលាយគឺមានសារៈសំខាន់ដើម្បីគាំទ្រដល់ការកាត់បន្ថយភាពក្រីក្រ និង បង្កើនចំណូលរដ្ឋាភិបាល ដើម្បីឱ្យសេវាកម្មសាធារណៈអាចទទួលបានហិរញ្ញប្បទានសមរម្យ។ ទោះបីជាគេឃើញមានកំណើនសេដ្ឋកិច្ចរឹងមាំគួរសមក្នុងទស្សវត្សរ៍កន្លងមកនេះក្តី ក៏កំណើនេះមានតែនៅក្នុងវិស័យមួយចំនួនតូច និង មានផលប៉ះពាល់តិចតួចលើប្រជាពលរដ្ឋក្រីក្រ។ ប្រទេសកម្ពុជាចាំបាច់ត្រូវដោះស្រាយឧបសគ្គជាច្រើនដើម្បីជំរុញកំណើន ស្វែងរកប្រភពកំណើនថ្មី ដោះស្រាយការលំបាកខាងហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធហិរញ្ញវត្ថុទន់ខ្សោយ មូលដ្ឋានជំនាញទាប និង ភាពទន់ខ្សោយនៅក្នុងអភិបាលកិច្ច។ ADB នឹងធ្វើការងារដើម្បីគាំទ្រល័ក្ខខ័ណ្ឌអំណោយផលសម្រាប់កំណើនប្រកបដោយចេរភាពដែលទ្រទ្រង់ប្រជាពលរដ្ឋក្រីក្រនិងដែលនាំមុខដោយវិស័យឯកជន តាមរយៈវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត កិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការគាំទ្រសមាហរណកម្មតំបន់កាន់តែធំ កិច្ចអភិវឌ្ឍន៍ប្រកបដោយចេរភាពនៃ SMEs និង វិនិយោគលើវិស័យកសិកម្មនិងប្រព័ន្ធធារាសាស្ត្រ។

៦១. **កិច្ចអភិវឌ្ឍន៍សង្គមដោយមានការចូលរួម** - ថ្វីបើប្រទេសកម្ពុជា សម្រេចបានវឌ្ឍនភាពនៅក្នុងការបង្កើនធនធានមនុស្សរបស់ខ្លួនក្តី ក៏សុចនាករ MDG របស់ប្រទេសនៅតែស្ថិតនៅក្នុងចំណោមសុចនាករដ៏ទាបបំផុតនៅក្នុងតំបន់ដែរ។ ថ្វីបើការផ្តល់សេវាកម្មជាមូលដ្ឋាន បានកើនឡើងក្តី ក៏គុណភាពនៃសេវាកម្ម នៅមានកំរិតទាប។ CSP នឹងជួយលើកស្ទួយសុខុមាលភាពរបស់ប្រជាពលរដ្ឋក្រីក្រ ដោយកែលំអរជីវភាព និងកាត់បន្ថយភាពងាយរងគ្រោះដោយបង្កើនលទ្ធភាពរបស់ប្រជាពលរដ្ឋក្រីក្រក្នុងការទទួលបានធនធាន (ទាំងរូបវ័ន្ត និងទាំងធម្មជាតិ) និង ដោយពង្រឹងធនធានមនុស្ស។ ជាពិសេស ADB នឹងយកចិត្តទុកដាក់ការគាំទ្ររបស់ខ្លួនលើការកែលំអរវិស័យអប់រំ ការផ្តល់លទ្ធភាពដល់ក្រុមងាយរងគ្រោះ ដូចជាស្ត្រី និង ក្រុមជាតិភាគតិច ការទប់ស្កាត់ជម្ងឺឆ្លង ការផ្គត់ផ្គង់ទឹក និងបរិក្ខាអនាម័យនៅជនបទ និង ការជម្រុញការគ្រប់គ្រង និងការការពារប្រកបដោយចេរភាព ដែលផ្អែកលើមូលដ្ឋាននៃធនធានធម្មជាតិនៅក្នុងអាងទន្លេសាប។

៦២. **អភិបាលកិច្ចល្អ** - អភិបាលកិច្ចទន់ខ្សោយនៅតែជាឧបសគ្គចំបងចំពោះការសម្រេចបានកំណើនសេដ្ឋកិច្ចកាន់តែលឿន និង ចំពោះការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ជាការឆ្លើយតប ADB នឹងអនុម័តនូវតួនាទីកាន់តែសកម្មក្នុងគំនិតផ្ដួចផ្ដើមអភិបាលកិច្ចតាមរយៈគម្រោងរបស់ខ្លួន។ នៅក្នុងកម្មវិធីជំនួយអនាគតរបស់ខ្លួន ADB នឹងយកចិត្តទុកដាក់លើអភិបាលកិច្ចដោយផ្ទាល់ ដោយ (១) កែលំអគណនេយ្យភាព និង ការផ្ដល់សេវាកម្ម (២) ការគាំទ្រកំណែទម្រង់ច្បាប់ បទប្បញ្ញត្តិ និង គោលនយោបាយ (៣) ពង្រឹងការកសាងសមត្ថភាពស្ថាប័ន និង (៤) កែលំអរប្រសិទ្ធិភាព និង ប្រសិទ្ធិផលនៃការអនុវត្តន៏គម្រោង។ តាមរយៈអភិក្រមនេះ ADB នឹងជួយរាជរដ្ឋាភិបាល ក្នុងការសម្រេចនូវការកែលំអរជាបណ្ដើរៗ បន្តិចម្ដងៗ និង (តាមលទ្ធភាពធ្វើទៅបាន) នៅក្នុងការកែលំអរអភិបាលកិច្ចរបស់ខ្លួន។

៦៣. ADB យល់ថា សសរទ្រូងជាយុទ្ធសាស្ត្រទាំងបីនេះ (កំណើនសេដ្ឋកិច្ចដែលមានមូលដ្ឋានទូលាយ កិច្ចអភិវឌ្ឍន៍សង្គមដោយមានការចូលរួម និង អភិបាលកិច្ចល្អ) គឺមានទំនាក់ទំនងគ្នា និង ជួយពង្រឹងគ្នាទៅវិញទៅមក។ ប្រសិនបើស្ថាប័នទាំងឡាយនៅកម្ពុជា មិនត្រូវបានពង្រឹងនោះទេ កំណើនសេដ្ឋកិច្ចនឹងរអាក់រអួល ហើយភាពងាយរងគ្រោះនឹងកើនឡើង។ កំណើនសេដ្ឋកិច្ច និង កិច្ចអភិវឌ្ឍន៏វិស័យឯកជន នឹងបានជាគ្រឹះយ៉ាងរឹងមាំសម្រាប់អភិបាលកិច្ចល្អ ដោយបង្កើតឡើង នូវមូលដ្ឋានដ៏រឹងមាំមួយសម្រាប់តម្លាភាព និង វិធានច្បាប់។ ស្ថេរភាពសង្គម គឺជាលទ្ធផល និង បុព្វល័ក្ខខ័ណ្ឌចាំបាច់ សម្រាប់កំណើនសេដ្ឋកិច្ច និង អភិបាលកិច្ចល្អ។

រូប ១: យុទ្ធសាស្ត្រចំបងរបស់ CSP



## ១. ជម្រើសតាមវិស័យ

៦៤. អន្តរាគមន៍តាមវិស័យនៅក្នុងកម្មវិធីជំនួយអនាគតរបស់ ADB ចំពោះកម្ពុជា នៅក្នុងបរិបទនៃការកាត់បន្ថយ ADF នឹងផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោមនេះៈ ឧបសគ្គចំពោះមុខចំពោះការកាត់បន្ថយភាពក្រីក្រ ការកំណត់អាទិភាពទាំងឡាយបានមកពីការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ឧត្តមភាពប្រៀបធៀបរបស់ ADB ស្នាដៃកន្លងមកនៅក្នុងវិស័យនីមួយៗ ការវាយតម្លៃដ៏ប្រាកដប្រជាលើការប្តេជ្ញារបស់រាជរដ្ឋាភិបាលចំពោះកំណែទម្រង់ និង លទ្ធភាពនៃអន្តរាគមន៍ដោយដៃគូអភិវឌ្ឍន៍ដទៃទៀតនៅក្នុវិស័យជាក់លាក់ទាំងឡាយ។ ថ្វីបើតម្រូវការមានសភាពធំធេង ហើយមានកំណើននៃចំនួនសកម្មភាពទាំងឡាយដែលត្រូវបានអនុវត្តដោយកម្មវិធី GMS ក្តី ក៏ ADB នឹងប្រឹងប្រែងបន្ថែមទៀតដើម្បីធ្វើជម្រើសចំពោះអន្តរាគមន៍របស់ខ្លួន ដើម្បីលើកកំពស់ប្រសិទ្ធិភាពនៃជំនួយ។ ប៉ុន្តែ ដោយសារ ADB គឺជាអ្នកផ្តល់ជំនួយមួយក្នុងចំណោមអ្នកផ្តល់ជំនួយដ៏ធំបំផុតទាំងឡាយនៅកម្ពុជា (គិតតាមការផ្តល់មូលនិធិ និង ការចូលរួមតាមវិស័យ) ការដកខ្លួនចេញពី វិស័យមួយនឹងតម្រូវឱ្យមានការពិចារណាដ៏ប្រុងប្រយ័ត្ន និងកិច្ចសហប្រតិបត្តិការជាមួយអ្នកផ្តល់ជំនួយដទៃទៀត ដើម្បីធានាអោយបាននូវការជំនួសដោយធាធានគ្រប់គ្រាន់ដោយភ្នាក់ងារអភិវឌ្ឍន៍ដទៃទៀត ដើម្បីបំពេញបន្ថែមលើការដក-ថយរបស់ ADB។ ការយល់ឃើញបែបនេះ ត្រូវបានឯកភាពគ្នាជាមួយធនាគារពិភពលោកនៅក្នុងវិស័យសុខាភិបាល ហើយ ADB នឹងដកខ្លួនចេញបន្តិចម្តងៗពីវិស័យនេះ ខណៈដែលធនាគារពិភពលោកបង្កើនវត្តមានរបស់ខ្លួននៅក្នុងវិស័យសុខាភិបាល។ ការចេញពីវិស័យសុខាភិបាល បានអនុញ្ញាតអោយ ADB អាចគាំទ្រការផ្គត់ផ្គង់ទឹក និងអនាម័យនៅជនបទដែលជាវិស័យមួយដ៏សំខាន់ក្នុងការសម្រេចឱ្យបាននូវ MDGs។ ADB ក៏មានតួនាទីជាកាតាលិករលើវិស័យនេះ ដោយ ADB នឹងខិតខំទាក់ទាញរាជរដ្ឋាភិបាល និងអ្នកផ្តល់ជំនួយដទៃទៀត អោយចូលក្នុងវិស័យដ៏សំខាន់នេះដែលនៅពេលនេះមានការខ្វះមូលនិធិជាច្រើន។ ADB, DFID និងធនាគារពិភពលោក ក៏បានធ្វើសុខដុមនីយកម្មផងដែរលើយុទ្ធសាស្ត្ររបស់ពួកគេ ការធ្វើការសម្របសម្រួលកម្មវិធីនឹងបានឯកភាពគ្នាលើវិស័យទាំងឡាយដែលដៃគូមួយមានឧត្តមភាពប្រៀបធៀប នឹងមានការឯកភាពគ្នាលើតួនាទីជាអ្នកនាំមុខ។ អភិក្រមនេះ ត្រូវបានពិភាក្សាយ៉ាងច្រើនជាមួយរាជរដ្ឋាភិបាល ដើម្បីទទួលបានការគាំទ្រដ៏ពេញលេញពីរាជរដ្ឋាភិបាល។ "ស្ថាប័ននាំមុខ" ក៏នឹងផ្តល់ការគាំទ្រផងដែរ ដល់រាជរដ្ឋាភិបាលក្នុងការរៀបចំ និងការអនុវត្តន៍យុទ្ធសាស្ត្រតាមវិស័យ។ ADB នឹងមានតួនាទីនាំមុខនៅក្នុងវិស័យជាអាទិភាពចំនួនបួនៈ (១) កសិកម្ម និងធនធានទឹក (២) អប់រំ (៣) ហិរញ្ញវត្ថុ និង (៤) ដឹកជញ្ជូន។ នៅក្នុងវិស័យណាដែលនៅក្នុងនោះដៃគូមួយ មានតួនាទីនាំមុខក្នុងការជួយរាជរដ្ឋាភិបាល រៀបចំយុទ្ធសាស្ត្រ និង កម្មវិធីតាមវិស័យ ដៃគូដទៃទៀតនឹងមានតួនាទីគាំទ្រដោយបន្តផ្តល់ជំនួយបច្ចេកទេស និងផ្តល់ឥណទានវិនិយោគ និង ចូលរួមក្នុងការពិភាក្សា

ថ្នាក់ជាតិស្តីពីគោលនយោបាយអភិវឌ្ឍន៍ និងបញ្ហាទាក់ទិនទាំងឡាយនៅក្នុងវិស័យពាក់ព័ន្ធ។ ក្នុងន័យនេះ ADB នឹងបន្តគាំទ្រដល់វិស័យថាមពល (ដែលនៅក្នុងនោះ ធនាគារពិភពលោក នឹងនាំមុខ)។

## ២. អាទិភាពប្រធានបទក្រៅអភិបាលកិច្ច

៦៥. **កិច្ចអភិវឌ្ឍន៍វិស័យឯកជនៈ** ADB នឹងជួយរាជរដ្ឋាភិបាលក្នុងការកែលំអបរិយាកាសអំណោយផលមួយ សម្រាប់កិច្ចអភិវឌ្ឍន៍វិស័យឯកជន តាមរយៈការរួមផ្សំគ្នារវាងការវិនិយោគ និង កំណែទម្រង់គោលនយោបាយ ស្ថាប័ន និង និយតកម្ម។ ក្នុងន័យនេះ អន្តរាគមន៍របស់ ADB នឹងត្រូវសំដៅកាត់បន្ថយបន្ថែមទៀតនូវការលំបាក ធំៗខាងហេដ្ឋារចនាសម្ព័ន្ធ (ជាពិសេស នៅក្នុងវិស័យដឹកជញ្ជូននិងអគ្គិសនី) ដែលបានធ្វើឱ្យចំណាយនៃការធ្វើ អាជីវកម្មកើនខ្ពស់។ អន្តរាគមន៍ទាំងនេះក៏នឹង ផ្តល់ផងដែរនូវកិច្ចអភិវឌ្ឍន៍ធនធានមនុស្ស (អប់រំ និង ការបណ្តុះបណ្តាលវិជ្ជាជីវៈនិង/ឬជំនាញ) ដើម្បីធ្វើឱ្យមានកម្លាំងពលកម្មកាន់តែមានផលិតភាពខ្ពស់ និង កំណែទម្រង់ វិស័យហិរញ្ញវត្ថុដើម្បីកាត់បន្ថយចំណាយនិងបង្កើនលទ្ធភាពក្នុងការទទួលបានហិរញ្ញវត្ថុ។ ក្នុងពេលខាងមុខ គេនឹង ឃើញមានការយកចិត្តទុកដាក់កាន់តែខ្លាំងលើគំនិតផ្តួចផ្តើមវិស័យឯកជនទាំងឡាយ ដែលមានឥទ្ធិពលខ្លាំងលើការ កាត់បន្ថយភាពក្រីក្រ។ ជាក់ស្តែង ADB នឹងគាំទ្រ SMEs ក្នុងការបង្កើនផលិតភាព ភាពប្រកួតប្រជែង និង សក្តានុពលបង្កើតការងាររបស់ពួកគេ។ ប្រតិបត្តិការវិស័យឯកជនក៏នឹងត្រូវចាប់ធ្វើផងដែរនៅពេលណាដែល កាលានុវត្តភាពកើតមាន។ ទោះបីជាលទ្ធភាពសម្រាប់កិច្ចអភិវឌ្ឍន៍ប្រតិបត្តិការវិស័យឯកជនបច្ចុប្បន្ននេះ នៅ មានកម្រិតក្តី ក៏លទ្ធភាពអនាគតក្នុងផ្នែកសម្រួលពាណិជ្ជកម្ម និង ក្នុងវិស័យផ្លូវរថភ្លើង ផ្លូវ និង ហិរញ្ញវត្ថុ ក៏កំពុង ត្រូវបានពិនិត្យរិះរកយ៉ាងសកម្មដោយនាយកដ្ឋានប្រតិបត្តិការវិស័យឯកជនរបស់ ADB ។ ការគាំទ្ររបស់ ADB អាច មានទម្រង់ជាឥណទានផ្ទាល់ ហិរញ្ញប្បទានដើមទុន ឬ ផលិតផលដែលនឹងជួយលើកកំពស់ឥណទាន។

៦៦. **យេនឌ័រ** ការរើសអើងមើលស្រាលស្ត្រីដែលបំពាក់ដោយមូលហេតុសង្គម-វប្បធម៌ នៅតែជាការ បារម្ភមួយ។ ធនាគារអភិវឌ្ឍន៍អាស៊ី នឹងបន្តផ្តោតសកម្មភាពការងាររបស់ខ្លួនលើការបង្កើតឱកាសនានាដើម្បី អោយស្ត្រីកាន់តែអាចចូលរួមក្នុងវិស័យសេដ្ឋកិច្ច និង លើកកំពស់ជីវភាពរបស់ស្ត្រីអោយបានប្រសើរជា លំដាប់។ ជាក់ស្តែង ធនាគារអភិវឌ្ឍន៍អាស៊ីនឹងៈ (១) បង្កើនការយកចិត្តទុកដាក់បញ្ជ្រាបយេនឌ័រនៅក្នុងគម្រោងកម្មវិធី របស់ខ្លួនដោយពង្រឹងទំនាក់ទំនងសហប្រតិបត្តិការរវាងក្រសួងពាក់ព័ន្ធ និងក្រសួងកិច្ចការនារី (២) រួមចំណែក ជំរុញដល់សមធម៌យេនឌ័រ និងការពង្រឹងស្ត្រីតាមរយៈសកម្មភាពនានានៅក្នុងគំរោងអប់រំ គំរោងកសិកម្ម គំរោងគ្រប់គ្រងធនធានធម្មជាតិ គំរោងអភិវឌ្ឍន៍ជនបទ និងគំរោងអភិវឌ្ឍន៍សហគ្រាសខ្នាតតូចនិងមធ្យម (៣) បន្តពង្រឹងសមត្ថភាពរបស់ក្រសួងកិច្ចការនារីក្នុងការវិភាគគោលនយោបាយ និងការតស៊ូមតិដើម្បីទាក់ទាញការ គាំទ្រចំពោះយេនឌ័រ និង (៤) ជម្រុញទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងក្របខ័ណ្ឌ

អនុតំបន់ទន្លេមេគង្គ ដើម្បីរួមគ្នាដោះស្រាយភាពងាយរងគ្រោះរបស់ស្ត្រីចំពោះការជួញដូរមនុស្ស អន្តោប្រវេសន៍ និងជម្ងឺឆ្លងនានាពីប្រទេសមួយទៅប្រទេសមួយទៀត ។

៦៧. **បរិស្ថាន** – ADB នឹងផ្តោតការយកចិត្តទុកដាក់លើការប្រើប្រាស់ធនធានធម្មជាតិ ប្រកបដោយចេរភាព ដើម្បីលើកកំពស់ជីវភាព និង កាត់បន្ថយភាពក្រីក្រ។ ដោយសារភោគទ្រព្យធម្មជាតិ និង សារៈសំខាន់របស់វា ចំពោះការទ្រទ្រង់ប្រជាជនកម្ពុជា ទន្លេសាប នឹងនៅតែគឺជាតំបន់មួយដែលទទួលការយកចិត្តទុកដាក់ជាពិសេស ហើយអន្តរាគមន៍ នឹងផ្តោតលើការគ្រប់គ្រងធនធានធម្មជាតិ ដែលផ្អែកលើសហគមន៍ នៅក្នុងអភិក្រម សមាហរណកម្មក្នុងទូទាំងអាងទន្លេសាប។ ADB នឹងជម្រុញការកែលំអចំពោះប្រព័ន្ធព័ត៌មានដែលមានសារៈ សំខាន់ចំពោះការគ្រប់គ្រងបរិស្ថាន នឹងគាំទ្រការកសាងសមត្ថភាពស្ថាប័ននៃស្ថាប័នទាំងឡាយ ដែលទទួលបន្ទុក លើបរិស្ថាន និង ធនធានធម្មជាតិ ទាំងនៅកម្រិតជាតិ និង ទាំងនៅកម្រិតមូលដ្ឋាន។ នៅក្នុងអាងទន្លេសាប ADB នឹងចូលរួមអោយមានជំរើសផ្សេងៗទៀតក្នុងការប្រកបមុខរបររបស់សហគមន៍ទាំងឡាយ ដែលសកម្មភាពរបស់ ខ្លួនបច្ចុប្បន្នមានលក្ខណៈមិនស្របគ្នាជាមួយនឹងការការពារបរិស្ថាន។ ទោះបីជាមានការយកចិត្តទុកដាក់ដោយ ផ្តោតលើអាងទន្លេសាបក្តី ក៏ចេរភាពបរិស្ថាន នឹងត្រូវបានដោះស្រាយនៅក្នុងគ្របខ័ណ្ឌនៃការគ្រប់គម្រោង តាមវិស័យទាំងអស់ តាមរយៈការប្រកាន់យកដ៏ខ្ជាប់ខ្ជួននូវនីតិវិធីវាយតម្លៃបរិស្ថានរបស់ ADB។ តទៅអនាគត នឹងមានការយកចិត្តទុកដាក់កាន់តែច្រើនឡើងថែមទៀត មិនត្រឹមតែលើសមិទ្ធិផលរបស់គម្រោងប៉ុណ្ណោះទេ ប៉ុន្តែ ក៏នឹងមានការយកចិត្តទុកដាក់ផងដែរ លើផលប៉ះពាល់ជារួមរបស់គម្រោងលើផ្នែកនានាជាច្រើនទៀត។

### ៣. ការយកចិត្តទុកដាក់ខាងភូមិសាស្ត្រ

៦៨. ដើម្បីកែលំអសមិទ្ធិផលអភិវឌ្ឍន៍នៃកម្មវិធីជំនួយរបស់ខ្លួន ADB នឹងផ្តោតអន្តរាគមន៍របស់ខ្លួនកាន់តែ ច្រើនថែមទៀត លើតំបន់អាងទន្លេសាប ដើម្បីបង្កអោយមានកិច្ចសហការកាន់តែច្រើនឡើងក្នុងចំណោម អន្តរាគមន៍ផ្សេងៗទាំងឡាយ និង ដើម្បីផ្តោតការគាំទ្រចំពោះការកាត់បន្ថយភាពក្រីក្រ និង ការគ្រប់គ្រងបរិស្ថាន លើតំបន់មួយដ៏ក្រីក្របំផុត និង ដែលមានលក្ខណៈរសើបបំផុតខាងបរិស្ថាននៅក្នុងប្រទេសកម្ពុជា (សូមមើល ឧបសម្ព័ន្ធ ៣)។ អាងទន្លេសាបរួមមានតំបន់ទាំងអសចំនួនប្រាំបីខេត្ត នៃខេត្តក្រុងទាំង ២៤ នៃប្រទេសកម្ពុជា និង គ្របដណ្តប់លើផ្ទៃដីចំនួន ៨០.០០០ គីឡូម៉ែត្រការ៉េ (៤៤% នៃផ្ទៃដីសរុបរបស់កម្ពុជា)[២០] ជាមួយ ប្រជាជនសរុបចំនួន ៣,៦ លាននាក់ ត្រូវជាមួយភាគបីនៃចំនួនប្រជាជនកម្ពុជាសរុប។

[២០] ខេត្តទាំងនេះរួមមាន បន្ទាយមានជ័យ បាត់ដំបង កំពុងឆ្នាំង កំពង់ធំ ឧត្តរមានជ័យ ព្រះវិហារ ពោធិ៍សាត់ និង សៀមរាប។ លើសពីនេះ ទៀត ADB នឹងគាំទ្រការគ្រប់គ្រងធនធានធម្មជាតិនៅក្នុងតំបន់ដទៃទៀតប្រសិនបើចាំបាច់ចំពោះរដ្ឋបាលបរិស្ថានលើអាងទន្លេសាប។

៦៩. ការយកចិត្តទុកដាក់របស់ ADB លើអាងទន្លេសាបមានផលប៉ះពាល់មួយចំនួន។ ទីមួយ ADB នឹងរៀបចំអន្តរាគមន៍ទាំងឡាយ ដើម្បីកែលំអរដ្ឋបាលបរិស្ថាន និង ជីវភាពនៅក្នុងអាងទន្លេសាប។ ទីពីរ ADB នឹងធានាឱ្យបានថា នៅពេលណាដែលអាចធ្វើទៅបាន ចំពោះគម្រោងថ្នាក់ក្រោមជាតិទាំងឡាយ (ពោលគឺ គម្រោងទាំងឡាយណាដែលមិនផ្តោតលើថ្នាក់ជាតិ) នឹងស្ថិតនៅក្នុងអាងទន្លេសាប។ ជាពិសេស ADB នឹងផ្ទេរជាបណ្តើរៗនូវអន្តរគមន៍ខ្លះៗរបស់ខ្លួននៅក្នុងវិស័យកសិកម្ម ថាមពល និង ការផ្គត់ផ្គង់ទឹកនិងអនាម័យនៅជនបទទៅកាន់តំបន់អាង ទន្លេសាប។ ថ្វីបើ ADB នឹងបន្តគាំទ្រគម្រោងដឹកជញ្ជូននៅក្នុងទូទាំងប្រទេសក្តី ក៏គម្រោងជាច្រើនទាំងនេះនឹង ស្ថិតនៅក្នុងអាងទន្លេសាបដែរ។ ទោះជាយ៉ាងណាក៏ដោយ ADB នឹងពិនិត្យលើការយកចិត្តទុកដាក់ខាងភូមិសាស្ត្រនេះ ក្នុងបរិបទនៃកម្មវិធីទាំងឡាយរបស់អ្នកផ្តល់ជំនួយដទៃទៀតនៅក្នុងទន្លេសាប។ អន្តរកាលទៅកាន់អាងទន្លេសាបនឹងមានលក្ខណៈជាបណ្តើរៗ និង ប្រហែលជានឹងមិនត្រូវបានបញ្ចប់ទេនៅរយៈពេលនៃ CSP ឆ្នាំ ២០០៥-២០០៩។

## ៤. កិច្ចសហការជាមួយកម្មវិធីមហាអនុតំបន់មេគង្គ

៧០. ចំពោះមុខដង់ស៊ីតេដ៏ខ្ពស់នៃភាពក្រីក្រនៅក្នុងប្រទេស GMS ជាច្រើន និងភាពបំពេញគ្នាទៅវិញទៅមកនៃ CSP សំរាប់កម្ពុជា និង យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការតំបន់សម្រាប់ GMS [២១] កិច្ចប្រឹងប្រែងបន្ថែមទៀតនឹងត្រូវបានធ្វើឡើងក្នុងអនាគតដើម្បីពង្រឹងកិច្ចសហការរវាង CSP និង កាលានុវត្តភាពដ៏ទូលាយដែលផ្តល់ឱ្យដោយកម្មវិធី GMS។ ក្នុងន័យនេះ គម្រោងទាំងឡាយដែលត្រូវបានកំណត់សម្រាប់កម្ពុជានៅក្នុងយុទ្ធសាស្ត្រ និង កម្មវិធីសហប្រតិបត្តិការតំបន់នេះ នឹងត្រូវបានពិនិត្យឡើងវិញយ៉ាងទៀងទាត់ ដើម្បីធានាឱ្យបាននូវសមាហរណកម្ម និង ការគាំទ្រចំពោះការសម្រេចបាននូវលទ្ធផលទាំងឡាយដែលត្រូវបានកំណត់នៅក្នុង CSP។ ទោះបីជាគម្រោងនៅក្នុងវិស័យដឹកជញ្ជូន ថាមពល ទូរគមនាគមន៍ និងទេសចរណ៍ នឹងបន្តទទួលការយកចិត្តទុកដាក់ដោយសារតួនាទីរបស់វិស័យទាំងនេះនៅក្នុងការជម្រុញកំណើនក្តី ក៏នឹងមានការយកចិត្តទុកដាក់ផងដែរលើការដោះស្រាយភាពទន់ខ្សោយនៃសមត្ថភាពស្ថាប័នដើម្បីធានាឱ្យបាននូវចីរភាពនៃអត្ថប្រយោជន៍គម្រោង។ ការយកចិត្តទុកដាក់លើការលើកស្ទួយជីវភាព និង ការកាត់បន្ថយភាពងាយរងគ្រោះ តាមរយៈគម្រោងស្តីពីការគ្រប់គ្រងនិងទប់ស្កាត់ទឹកជំនន់ និង លើការកាត់បន្ថយផលវិបាកសង្គមជាអវិជ្ជមាននៃកំណើនចលនាឆ្លងកាត់ព្រំដែន (?)

[២១] ADB ។ ឆ្នាំ ២០០៤។ *យុទ្ធសាស្ត្រនិងកម្មវិធីសហប្រតិបត្តិការតំបន់ ឆ្នាំ ២០០៤-២០០៨ GMS ហួសពីព្រំដែន*។ ម៉ានីល

# ៥. កម្មវិធីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

## ក. កម្រិតជំនួយជារួម

៧១. កម្ពុជាត្រូវបានគេចាត់ថ្នាក់ជាប្រទេសអ្នកកំចីប្រាក់ប្រភេទ (ក) ចាប់តាំងពីពេលដែល ADB ចាប់ផ្តើមផ្តល់ឥណទានឡើងវិញតាំងពីឆ្នាំ ១៩៩២ មក និងអាចខ្ចីបានតែពីប្រភព ADF ប៉ុណ្ណោះ។ ថ្វីបើកញ្ចប់ធនធាន ADF IX បានកើនឡើងក្តី ក៏តួរលេខផែនការចង្អុលបង្ហាញ (IPF) របស់កម្ពុជាសម្រាប់ឆ្នាំ ២០០៥-២០០៦ គឺមានចំនួន ១០៤,៣០ លានដុល្លារ ឬ ៥២,១៥ លានដុល្លារក្នុងមួយឆ្នាំ (ប្រាក់ចាយសល់ក្នុងឆ្នាំនីមួយៗ អាចលើកទៅពេលក្រោយបានដែលអនុញ្ញាតចំនួនអប្បបរិមា ៣៩,១១ លានដុល្លារក្នុងមួយឆ្នាំ និងចំនួនអតិបរិមា ៦៥,១៩ លាន ដុល្លារក្នុងមួយឆ្នាំ)។ ការបែងចែក IPF មានកំរិតទាបជាងមុនឱ្យដល់កម្ពុជានេះ គឺដោយសារការកែប្រែគោលនយោបាយស្តីពីការបែងចែកផ្អែកលើសមិទ្ធផលដោយផ្តោតទម្ងន់ធ្ងន់លើអភិបាលកិច្ច។ ប្រការនេះ គឺមានលក្ខណៈល្អប្រសើរជាងការបែងចែកធនធានដោយផ្អែកលើចំនួនប្រជាជន ដោយសារទម្ងន់ស្រាលជាង ត្រូវបានផ្តល់លើចំនួនប្រជាជន ("ភាពលំអៀងប្រទេសតូច") នៃប្រទេសនីមួយៗ។ ក្នុងអំឡុង ឆ្នាំ ២០០៥-២០០៦ គម្រោងអនុតំបន់ (GMS) គឺជាការបន្ថែមលើការបែងចែកប្រចាំប្រទេស។ ADB នឹងបន្តរក្សាភាពទន់ភ្លន់ក្នុងកម្មវិធីជំនួយរបស់ខ្លួនដោយប្រើការគួបផ្សំគ្នានៃការផ្តល់ឥណទានកម្មវិធី កម្មវិធីអភិវឌ្ឍន៍តាមវិស័យ ការផ្តល់ឥណទានតាមវិស័យ និងមូលនិធិពិសេសដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់កម្ពុជា។ កម្មវិធីក្រៅការផ្តល់ឥណទានឆ្នាំ ២០០៥-២០០៦ ដែលផ្អែកលើធនធានមូលនិធិជំនួយបច្ចេកទេសពិសេស (TASF) និងមូលនិធិពិសេសជប៉ុន (JSF) (និងដែលមិនរាប់បញ្ចូលការផ្តល់ហិរញ្ញប្បទានពីប្រភពផ្សេងៗតាមរយៈ ADB និងជំនួយបច្ចេកទេសប្រចាំតំបន់) ត្រូវបានរំពឹងថា នឹងមានចំនួនជាមធ្យមប្រហែល ៣,៣ លានដុល្លារក្នុងមួយឆ្នាំ។ ក្នុងចំនួននេះ មូលនិធិប្រហែល ៧១% នឹងត្រូវបានប្រើសម្រាប់ជំនួយបច្ចេកទេសដើម្បីត្រៀមរៀបចំគម្រោង និងមូលនិធិនៅសល់សម្រាប់ជំនួយប្រឹក្សាបច្ចេកទេស។ ជំនួយប្រឹក្សាបច្ចេកទេស នឹងផ្តោតជាពិសេសលើការពង្រឹងស្ថាប័ន និងការកសាងសមត្ថភាពដើម្បីអភិវឌ្ឍន៍ស្ថាប័នតាមវិស័យឱ្យកាន់តែមានប្រសិទ្ធភាព កែលំអអភិបាលកិច្ច និងលើកកំពស់សមិទ្ធផលជារួមនៃជំនួយអភិវឌ្ឍន៍។ ADB នឹងបន្តអនុវត្តយ៉ាងសកម្មនូវការគៀងគជំនួយពីប្រភពផ្សេងៗ ជាពិសេសហិរញ្ញប្បទានរួមពីជំនួយឥតសំណង និងប្រភពឥណទានសម្បទាន សម្រាប់កម្មវិធីផ្តល់ឥណទាន និងកម្មវិធីជំនួយឥតសំណងរបស់ខ្លួន។

៧២. ចំពោះមុខបញ្ហាអភិវឌ្ឍន៍ដ៏ច្រើនដែលនឹងត្រូវដោះស្រាយនៅកម្ពុជា ADB នឹងប្រើប្រាស់នូវឧបករណ៍ប្រតិបត្តិការ និង ហិរញ្ញវត្ថុរបស់ខ្លួនអោយអស់ពីលទ្ធភាព។ អភិក្រមក្នុងទូទាំងវិស័យ (SWAps) និងអភិក្រមផ្អែកលើកម្មវិធី (PBAs) នឹងត្រូវបានជម្រុញនៅទីណាដែលអាចធ្វើទៅបាន និង អាស្រ័យលើតម្រូវការ

(សូមមើលកថាខ័ណ្ឌ ៩០ ខាងក្រោមនេះ)។ ការពិភាក្សា និង កំណែទម្រង់គោលនយោបាយ នឹងត្រូវបានបន្តដោះស្រាយតាមរយៈកម្មវិធីអភិវឌ្ឍន៍តាមវិស័យ។ នៅទីណាដែលកំណែទម្រង់កំពុងដំណើរការ ត្រូវបានដឹកនាំដោយអ្នកផ្តល់ជំនួយដទៃទៀត ADB នឹងផ្តល់ឥណទានលើមូលដ្ឋានគម្រោងនីមួយៗ សំរាប់គាំទ្រការកែទំរង់នោះ។ ការបញ្ចូលរបៀបថ្មីក្នុងកម្មវិធីផ្តល់ឥណទានជូនកម្ពុជា គឺការមានហិរញ្ញប្បទានជំនួយឥតសំណង។ ជាប្រទេសក្រីក្រដែលមានបន្ទុកបំណុលធ្ងន់ ប្រទេសកម្ពុជាអាចទទួល បានដល់ ៥០% នៃជំនួយ ADF សរុបរបស់ខ្លួនក្នុងទម្រង់ជាជំនួយឥតសំណងក្រោមក្របខ័ណ្ឌបែងចែក ជំនួយឥតសំណងនៃ ADF IX។ ប្រការនេះគឺជាការវិវត្តជាវិជ្ជមានមួយសម្រាប់ប្រទេសមួយដែល ខណៈដែលមានអនុបាត សងការប្រាក់បំណុលប៉ាន់ស្មាន (ប្រៀបធៀបនឹងការនាំចេញទំនិញនិងសេវា) ត្រឹមតែ ២,៩% ក្នុងឆ្នាំ ២០០៣ មានអនុបាតសងការប្រាក់បំណុលចំពោះចំណូលរដ្ឋាភិបាលចំនួន ១៤,៨% ដែលដាក់ប្រទេសកម្ពុជាទៅក្នុងប្រភេទ ប្រទេសមានបន្ទុកបំណុលធ្ងន់។ លើសពីនេះទៀត ជាមួយនិងការបញ្ចប់ MFA នៅចុងឆ្នាំ ២០០៤ និង លទ្ធភាពនៃផលប៉ះពាល់អវិជ្ជមានរបស់វាលើប្រភពនាំចេញចំបងរបស់ប្រទេស ពោលគឺសំលៀកបំពាក់ ប្រទេសកម្ពុជានៅតែងាយរងគ្រោះខ្លាំងពីការវិវឌ្ឍន៍ជាអវិជ្ជមានខាងក្រៅ។ ប្រទេសកម្ពុជា មានចំណាត់ថ្នាក់ជាប្រទេសមួយ នៃប្រទេសក្រីក្របំផុតនៅអាស៊ី និង ទំនងជានឹងសម្រេចមិនបាននូវគោលដៅ MDG នៃការកាត់បន្ថយឱ្យបានពាក់កណ្តាលនៃចំនួនប្រជាជនដែលរស់នៅក្រោមបន្ទាត់ភាពក្រីក្រជាតិ មុនដំណាច់ឆ្នាំ ២០១៥។ ចំណុចគោលដៅដែលមិនមែនជាប្រាក់ចំណូលជាច្រើននៃ MDG ក៏នឹងមិនអាចសម្រេចបានផងទេ។ ចំពោះមុខភាពក្រីក្រខ្ពស់ តម្រូវការជាបន្ទាន់នូវវិនិយោគ សង្គម និង លទ្ធភាពដ៏មានកម្រិតនៃវិនិយោគបែបនេះ ដោយសារតែមូលដ្ឋានចំណូលរដ្ឋាភិបាលទាបខ្លាំង ជំរើសជំនួយឥតសំណង និងការប្រើប្រាស់មានមុខព្រួញច្បាស់លាស់ គឺជាការជំរុញអោយការប្រើប្រាស់ធនធានដែលមានស្រាប់កាន់តែមានប្រសិទ្ធិភាពខ្ពស់។ រាជរដ្ឋាភិបាល បានបង្ហាញថា ខ្លួនមានបំណងប្រើជំនួយឥតសំណង ADF ក្នុងទម្រង់ដាច់តែឯង ឬចម្រុះជាមួយប្រាក់ឥណទាន សម្រាប់គម្រោងទាំងឡាយដែលឆ្លើយតបទៅនឹងគោលដៅជាតិកាត់បន្ថយភាពក្រីក្រដែលមានកំណត់នៅក្នុង MDGs។ អភិក្រមនេះ គឺស្របជាមួយគោលបំណងចំបងរបស់ ADB នៃការកាត់បន្ថយភាពក្រីក្រប្រកបដោយចេរភាពនៅកម្ពុជា និង អាទិភាពជាយុទ្ធសាស្ត្ររបស់ CSP។ ក្នុងកម្មវិធីផ្តល់ឥណទានឆ្នាំ ២០០៥ ហិរញ្ញប្បទានជំនួយឥតសំណង ត្រូវបានគ្រោងសម្រាប់គម្រោងទាំងឡាយណាដែលពាក់ព័ន្ធនឹងការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យនៅជនបទ និងសម្រាប់ទប់ស្កាត់ជម្ងឺឆ្លង។

## ខ. ជំនួយធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់អាទិភាពជាយុទ្ធសាស្ត្រ

### ១. កំណើនសេដ្ឋកិច្ចមានមូលដ្ឋានទូលាយដែលទ្រទ្រង់ប្រជាពលរដ្ឋក្រីក្រ

## ក. ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច

៧៣. **វិស័យដឹកជញ្ជូន** - ដូចជាហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចជាច្រើនដែរ វិស័យដឹកជញ្ជូនត្រូវបានបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរដោយវិវាទរាប់ឆ្នាំនៅកម្ពុជា។ ទោះបីជាគេបានសម្រេចវឌ្ឍនភាពគួរឱ្យកត់សំគាល់ចាប់តាំងពីដើមទសវត្សរ៍ ១៩៩០ ក្នុងការស្តារឡើងវិញនូវបណ្តាញផ្លូវសំខាន់ៗដែលភ្ជាប់មជ្ឈមណ្ឌលសំខាន់ៗទាំងឡាយនៅក្នុងប្រទេសកម្ពុជា និង សេដ្ឋកិច្ចជាតិជាមួយប្រទេសជិតខាងក្តី ក៏គេនៅមានការងារច្រើនទៀតដែលត្រូវធ្វើ។ ផ្លូវភាគច្រើន ជាពិសេសផ្លូវទៅកាន់សហគមន៍ជនបទនិងកសិកម្ម គឺស្ថិតក្នុងស្ថានភាពដ៏យ៉ាប់យ៉ឺន។ ប្រការនេះនាំឱ្យមានចំណាយដឹកជញ្ជូនខ្ពស់ និង រារាំងដល់លទ្ធភាពរបស់ជនក្រីក្រក្នុងការទៅដល់ទីផ្សារនិងក្នុងការទទួលសេវាកម្មសង្គម ដែលមានផលប៉ះពាល់ជាអវិជ្ជមានលើភាពប្រកួតប្រជែង ការពង្រីកកាលានុវត្តភាពសេដ្ឋកិច្ច ជីវភាពនៅជនបទ និង ការកាត់បន្ថយភាពក្រីក្រ។ បញ្ហានិងឧបសគ្គសំខាន់ៗតាមវិស័យ រួមមានកង្វះយន្តការគ្រប់គ្រងនិងហិរញ្ញប្បទានអាចទុកចិត្តបានសម្រាប់ការថែរក្សាផ្លូវ ភាពចាំបាច់នៃការបង្រួបបង្រួមនិងការគ្រប់គ្រងប្រកបដោយតម្លាភាពនៃចំណាយសាធារណៈលើផ្លូវដើម្បីបង្កើតប្រសិទ្ធិភាពក្នុងការធ្វើវិភាជន៍ ការពង្រឹងស្ថាប័ននិងការកសាងសមត្ថភាពនៃស្ថាប័នតាមវិស័យ ក្របខ័ណ្ឌច្បាប់និងនិយតកម្មមិនគ្រប់គ្រាន់ដើម្បីជម្រុញការចូលរួមឯកជនកាន់តែច្រើននៅក្នុងវិស័យ និងកង្វះសមត្ថភាពក្នុងចំណោមអ្នកម៉ៅការវិស័យឯកជនក្នុងស្រុក។ ការកែលំអលទ្ធភាពធ្វើដំណើរគឺជាគ្រឹះនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដោយសារវានឹងជួយកាត់បន្ថយតម្លៃនៃវត្ថុធាតុ-ដើមកសិកម្ម បង្កើនតម្លៃដែលមានឱ្យកសិករ និង ផ្តល់ឱកាសរកបានប្រាក់ចំណូលក្រៅពីការងារកសិកម្ម។

៧៤. ADB គឺជាដៃគូនាំមុខមួយនៅក្នុងវិស័យដឹកជញ្ជូន និង បានជួយតភ្ជាប់កម្ពុជាទៅនឹងប្រទេសវៀតណាម និង ថៃឡង់ដ៍ តាមរយៈគម្រោងផ្លូវជាតិ និង តភ្ជាប់ផ្លូវសំខាន់ៗទាំងឡាយទៅនឹងសហគមន៍នៅមូលដ្ឋាន។ ADB នឹងបន្តជួយរាជរដ្ឋាភិបាលក្នុងការកែលំអលទ្ធភាពធ្វើដំណើរ ដោយស្តារបន្ថែមទៀតនូវផ្លូវជាតិ និងផ្លូវក្នុងខេត្តបន្ទាប់បន្សំរបស់កម្ពុជា និង ដោយកសាងឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធស្ថាប័ននិងរូបវ័ន្តនៃរាជាអាយស្ម័យានភូមិន្ទកម្ពុជា។ ការងារនេះនឹងត្រូវបានធ្វើជាមួយនឹងការចូលរួមវិស័យឯកជនកាន់តែច្រើនទាំងនៅក្នុងវិស័យផ្លូវនិងទាំងក្នុងវិស័យផ្លូវរថភ្លើង។ ADB ក៏នឹងគាំទ្រផងដែរដល់មូលនិធិសម្រាប់ការជួសជុលនិងការថែទាំផ្លូវ ដោយជួយបង្កើតយន្តការផ្តល់មូលនិធិដែលមានលក្ខណៈស្ថាប័នសមស្រប។ ADB នឹងជួយអភិវឌ្ឍសមត្ថភាពធ្វើគោល-នយោបាយ និងសមត្ថភាពត្រួតពិនិត្យបទប្បញ្ញត្តិរបស់ស្ថាប័នដឹកជញ្ជូនតាមផ្លូវ។ កម្មវិធី GMS របស់ ADB នឹងបន្តគាំទ្រដល់ការធ្វើសុខុដុមនីយកម្មលើនិយតកម្មពាណិជ្ជកម្មនិងការដឹកជញ្ជូនឆ្លងដែន ដោយធានាឱ្យបានថាកម្ពុជាបានទទួលតម្លៃបន្ថែមទៀតពីតួនាទីរបស់ខ្លួនជា "ផ្លូវភ្ជាប់" រវាងប្រទេសថៃឡង់ដ៍និងវៀតណាម។ កម្មវិធី GMS ក៏នឹងផ្តល់ការគាំទ្រ TA ផងដែរចំពោះកំណែទម្រង់គោលនយោបាយនៃវិស័យទូរគមនាគមន៍ ជាការគាំទ្របន្ត និងការគាំទ្រជាបន្តបន្ទាប់នៅក្នុងវិស័យនេះ។

៧៥. **វិស័យអគ្គិសនី** - ការផ្គត់ផ្គង់គ្រប់គ្រាន់នូវអគ្គិសនីដែលអាចទុកចិត្តបាននិងដែលមានតម្លៃសមរម្យ គឺជាបុព្វល័ក្ខខ័ណ្ឌសម្រាប់កំណើសេដ្ឋកិច្ចដែលនាំមុខដោយវិស័យឯកជន។ កម្ពុជាមានអត្រាប្រើអគ្គិសនីទាបបំផុតនៅអាស៊ី និង ស្ថិតនៅក្នុងចំណោមប្រទេសដែលមានថ្លៃអគ្គិសនីដ៏ខ្ពស់បំផុតក្នុងពិភពលោក។ ប្រជាជនត្រឹមតែ ១៥% ប៉ុណ្ណោះនៃចំនួនប្រជាជនសរុបបានទទួលសេវាកម្មពីប្រព័ន្ធអគ្គិសនី។ ADB នឹងបន្តតួនាទីគាំទ្រដ៏សំខាន់របស់ខ្លួននៅក្នុងការស្តារឡើងវិញនូវការផ្គត់ផ្គង់អគ្គិសនីនៅភ្នំពេញ និង ទីរួមខេត្តសំខាន់ៗ និង ការជួយផ្តល់អគ្គិសនីដែលមានតម្លៃប្រកួតប្រជែងនិងដែលអាចទុកចិត្តបានជូនដល់អ្នកចែកចាយឯកជននៅជនបទ។ លើសពីនេះទៀតជំនួយ ADB នឹងផ្តោតលើការពង្រីកប្រព័ន្ធបង្កើត បញ្ជូន និង ចែកចាយអគ្គិសនី ដែលរាប់បញ្ចូលតំបន់ជនបទនិងតំបន់ក្រីក្រផងដែរ។ ការងារនេះនឹងត្រូវបានអនុវត្តក្នុងកិច្ចសហការដ៏ជិតស្និទ្ធជាមួយគម្រោងវិស័យអគ្គិសនី GMS ដែលកំពុងដំណើរការ និង នាពេលអនាគត ដើម្បីធានាឱ្យបាននូវតម្លៃទាបជាង និង សេដ្ឋកិច្ចមាត្រដ្ឋាន។

### ខ. កិច្ចអភិវឌ្ឍន៍ SME និង វិស័យហិរញ្ញវត្ថុ

៧៦. ADB នឹងជួយបង្កើតបរិយាកាសអំណោយផលសម្រាប់SMEsដោយ(១) បង្កើតក្របខ័ណ្ឌអភិវឌ្ឍន៍មួយនិងរចនាសម្ព័ន្ធស្ថាប័នសមស្រប ដើម្បីឱ្យគោលនយោបាយចំពោះ SMEs ត្រូវបានសម្របសម្រួលនិងអនុវត្តយ៉ាងមានប្រសិទ្ធិភាពក្នុងចំណោមក្រសួងផ្សេងៗ (២) លើកកំពស់អភិបាលកិច្ច និង និយតកម្មអាជីវកម្ម ដោយកែលំអនីតិវិធីចុះបញ្ជីក្រុមហ៊ុន និង រៀបចំប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណអាជីវកម្មមួយប្រកបដោយតម្លាភាព (៣) កែលំអលទ្ធភាពទទួលហិរញ្ញវត្ថុរបស់ SMEs ដោយបង្កើតប្រព័ន្ធព័ត៌មានឥណទាន ជួយសហគ្រាសក្នុងប្រព័ន្ធគណនេយ្យនិងពន្ធដារ និង រៀបចំក្របខ័ណ្ឌច្បាប់សម្រាប់ភតិសន្យា និង (៤) ជួយក្នុងកិច្ចអភិវឌ្ឍន៍សេវាអាជីវកម្ម និង ភាពជាដៃគូរវាងវិស័យសាធារណៈនិងឯកជន។

៧៧. ថ្វីបើអន្តរាគមន៍របស់ ADB និង IMF ដែលកំពុងដំណើរការក្នុងការគាំទ្រវិស័យហិរញ្ញវត្ថុបានពង្រឹងប្រព័ន្ធធនាគារក្តី (មូលដ្ឋានប្រាក់បញ្ញើបានកើនឡើងពីត្រឹមតែ ៤% នៃ GDP នៅដើមទស្សវត្សរ៍ ១៩៩០ មកដល់ ១២%នៅដំណាច់ទស្សវត្សរ៍នោះ) ក៏វិស័យហិរញ្ញវត្ថុបន្តបង្ហាញអន្តរការីកម្មកម្រិតទាប មិនទាន់បានរីកសាយភាយហើយនៅខ្វះការអភិវឌ្ឍន៍គ្រឹះស្ថានក្រៅធនាគារ និង ផលិតផលនិងសេវានៅមានកម្រិត។ កត្តាមួយចំនួនបានរារាំងដល់កំណើនឥណទាន រួមមានយន្តការមិនគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការបង្ខំឱ្យអនុវត្តកិច្ចសន្យា ហិរញ្ញវត្ថុកង្វះព័ត៌មានអាចទុកចិត្តបានអំពីអ្នកខ្ចី ចំណាយប្រតិបត្តិការខ្ពស់ តម្លាភាពនៅមានកម្រិតទាប និង សមត្ថភាពធនធានមនុស្សទន់ខ្សោយ។ ចំពោះមុខតួនាទីដ៏សំខាន់នៃវិស័យហិរញ្ញវត្ថុក្នុងកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច ADB នឹងបន្តដើរតួនាទីនាំមុខរបស់ខ្លួនដើម្បីគាំទ្រកិច្ចអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ហើយបច្ចុប្បន្ននេះ កំពុងតែសហការជាមួយរាជរដ្ឋាភិបាលដើម្បីសម្រួលជាថ្មីនូវផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល។ ការចូលរួមនាពេល

ខាងមុខរបស់ ADB នឹងអាស្រ័យតាមលទ្ធផលនៃការសម្រួលថ្មីនូវផែនការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុនេះ ប៉ុន្តែត្រូវបានរំពឹងថានឹងផ្តោតទៅលើ (១) ការពង្រឹងការត្រួតពិនិត្យធនាគារនិងគ្រឹះស្ថានក្រៅធនាគារ (២) កិច្ចអភិវឌ្ឍន៍បន្ថែមទៀតនូវប្រព័ន្ធទូទាត់ និង ទីផ្សារអន្តរធនាគារ (៣) ការពង្រឹងបទប្បញ្ញត្តិគណនេយ្យថ្មីដើម្បីកែលំអតម្លាភាព និង សម្រួលការចែករំលែកព័ត៌មាន (៤) ការកសាងហេដ្ឋារចនាសម្ព័ន្ធច្បាប់ដើម្បីគាំទ្រអន្តរការិយកម្មហិរញ្ញវត្ថុ និង សកម្មភាពពាណិជ្ជកម្ម (៥) ជម្រុញកិច្ចអភិវឌ្ឍន៍វិស័យឯកជននៃអាជីវកម្មធានារ៉ាប់រង ទន្ទឹមគ្នានឹងការពង្រឹងក្របខ័ណ្ឌនិយតកម្មនិងប្រព័ន្ធត្រួតពិនិត្យ និង (៦) វិនិយោគបន្ថែមទៀតលើការកសាងសមត្ថភាពធនធានមនុស្ស ។

៧៨. **វិស័យទេសចរណ៍**មានសក្តានុពលក្នុងការគាំទ្រដល់កំណើនសេដ្ឋកិច្ចនិងការបង្កើតការងារបន្ថែមទៀត និងគឺជាវិស័យគន្លឹះមួយសម្រាប់ការចូលរួមនៃវិស័យឯកជន ។ ADB បានគាំទ្រកិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍នៅកម្ពុជា តាមរយៈការកែលំអវិស័យដឹកជញ្ជូន (ផ្លូវនិងអាកាសយានដ្ឋាន) និង កិច្ចអភិវឌ្ឍន៍ទីប្រជុំជននៅតាមតំបន់ទេសចរសំខាន់ៗ ។ ការគាំទ្រនាអនាគតក្នុងវិស័យនេះ នឹងយកចិត្តទុកដាក់លើការជម្រុញវិស័យទេសចរណ៍តំបន់នៅក្នុង GMS ។

### គ. វិស័យកសិកម្ម និង ការគ្រប់គ្រងធនធានទឹក

៧៩. ទោះបីជាផលិតកម្មសេដ្ឋកិច្ចកម្ពុជាមួយចំណែកធំគឺបានមកពីវិស័យកសិកម្មក្តី ក៏វិស័យនេះមានការរីកលូតលាស់យឺតដែរ ។ ដោយចំនួនប្រជាជនក្រីក្រ ៩០% រស់នៅតំបន់ជនបទ ដូច្នេះអត្រាកំណើនទាបនៅក្នុងវិស័យកសិកម្មគឺជាឧបសគ្គចំបងមួយចំពោះការកាត់បន្ថយភាពក្រីក្រ ។ ការបង្កើនផលិតភាពកសិកម្ម កសិកម្មចំរុះ និងភាពប្រកួតប្រជែងនៃវិស័យកសិកម្ម នឹងជយយលើកស្ទួយកំណើនសេដ្ឋកិច្ច ជួយបង្កើតការងារ ធ្វើអោយមានសមធមិ និងមានយុត្តិធមិសង្គម ។ យុទ្ធសាស្រ្តរបស់ ADB និងជួយកសាងជុំវិញគម្រោងវិស័យកសិកម្មដែលមានកន្លងមក និងដែលកំពុងដំណើរការ ដោយផ្តោតយកចិត្តទុកដាក់លើ (១) ការលើកកំពស់សមត្ថភាពកសិករដើម្បីបង្កើនផលិតភាព ការធ្វើសកិកម្មចំរុះ ឆ្ពោះទៅរកផលិតផលដែលមានតម្លៃខ្ពស់ និងផ្សារភ្ជាប់ទៅនឹងទីផ្សារ (២) កែលំអរបរិស្ថានទីផ្សារសម្រាប់កំណើនសហគ្រាសឯកជន ដែលផ្អែកលើកសិកម្ម និង (៣) ពង្រឹងសមត្ថភាពស្ថាប័នដើម្បីការធ្វើពាណិជ្ជកម្មវិស័យកសិកម្ម ប្រកបដោយលក្ខណៈប្រកួតប្រជែង ។ ប្រការនេះ នឹងរួមមានការពង្រឹងការគាំទ្រខាងការផ្សព្វផ្សាយជូនដល់ក្រុមកសិករ ការគាំទ្រខាងផ្តល់ប្រឹក្សា និងការជម្រុញការនាំចេញជូនដល់សហគ្រាសកសិកម្ម ក៏រឹតគុណភាពទំនិញ និងសុវត្ថិភាពសម្រាប់ផលិតផលកសិកម្ម ព័ត៌មានអំពីតម្លៃ និងការអនុវត្តន៍សម្បទានដីធ្លី ។ ការគាំទ្ររបស់ ADB ដល់កិច្ចអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្រ្ត នឹងគឺជាស្នូលនៃការគាំទ្ររបស់ខ្លួនចំពោះវិស័យកសិកម្ម និងយកចិត្តទុកដាក់លើការកែលំអការគ្រប់គ្រងទឹក ដើម្បីទទួលបានផលដំណាំ និង

ប្រាក់ចំណូលខ្ពស់និងទៀងទាត់។ ADB នឹងជម្រុញអភិក្រមសមាហរណកម្មអាងទឹកចំពោះការគ្រោងប្រព័ន្ធធារាសាស្ត្រ និងលើកទឹកចិត្តដល់សហគមន៍ប្រើប្រាស់ទឹកសម្រាប់កសិកម្មឱ្យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រទំហំតូច និងមធ្យមក្នុងលក្ខណៈប្រកបដោយចីរភាព។ ទោះបីជាមុខព្រួញចំបងនៃអន្តរាគមន៍របស់ ADB នៅក្នុងវិស័យកសិកម្ម គឺសំដៅលើការបង្កើនការធ្វើពាណិជ្ជកម្មក្តី ក៏បញ្ហាសន្តិសុខស្បៀង នឹងត្រូវបានដោះស្រាយដោយសមាសភាគវិស័យកសិកម្ម និងប្រព័ន្ធធារាសាស្ត្រនៃគម្រោងក្រោមយុទ្ធសាស្ត្រអាងទន្លេសាបដែរ។

### តារាង ១: សំណើគម្រោងដើម្បីឆ្លើយតបទៅនឹងកំណើនសេដ្ឋកិច្ចដែលមានមូលដ្ឋានទូលាយ

| គម្រោងដែលបានស្នើឡើង | ឆ្នាំកម្មវិធី |
|---|---|
| **គម្រោងផ្តល់ឥណទាន** | |
| កសិកម្ម និង ធនធានធម្មជាតិ | |
| • កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម | ២០០៤,២០០៥[ក] |
| • គម្រោងអភិវឌ្ឍន៍វិស័យកសិកម្ម | ២០០៤,២០០៥[ក] |
| • គម្រោងប្រព័ន្ធធារាសាស្ត្រភាគពាយព្យ | ២០០៤,២០០៥[ក] |
| • កិច្ចអភិវឌ្ឍន៍វិស័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនិងធនធានទឹក | ២០០៧ |
| ថាមពល | |
| • គម្រោងបញ្ជូននិងចែកចាយអគ្គិសនីទីពីរ | ២០០៦ |
| វិស័យដឹកជញ្ជូន និង គមនាគមន៍ | |
| • គម្រោងអភិវឌ្ឍន៍និងថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន | ២០០៦ |
| • GMS: ការស្តារនីតិសម្បទាផ្លូវរថភ្លើងឡើងវិញនៅកម្ពុជា | ២០០៦ |
| ឧស្សាហកម្ម និង ពាណិជ្ជកម្ម | |
| • កិច្ចអភិវឌ្ឍន៍វិស័យ SME | ២០០៤,២០០៥* |
| ហិរញ្ញវត្ថុ | |
| • កម្មវិធីវិស័យហិរញ្ញវត្ថុទី ១ (កម្មវិធីរងទី ៣) | ២០០៥ |
| • កម្មវិធីវិស័យហិរញ្ញវត្ថុទី ២ (កម្មវិធីរងទី ១) | ២០០៧ |
| វិស័យដទៃទៀត | |
| • កិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍ GMS ដែលទ្រទ្រង់ដល់ប្រជាជនក្រីក្រ | ២០០៦ |
| **គម្រោងជំនួយឥតសំណង** | |
| កសិកម្មនិងធនធានធម្មជាតិ | |
| • គំនិតផ្តួចផ្តើមអាជីវកម្មនៅក្នុងកិច្ចអភិវឌ្ឍន៍ជនបទ | ២០០៥ |
| • ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនិងធនធានទឹក (PPTA) | ២០០៦ |
| • កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្មទី ២ (PPTA) | ២០០៧ |
| ហិរញ្ញវត្ថុ | |
| • ការអនុវត្តន៍កម្មវិធីវិស័យហិរញ្ញវត្ថុ | ២០០៥ |
| • កម្មវិធីវិស័យហិរញ្ញវត្ថុទី ២ (PPTA) | ២០០៦ |
| • ការអនុវត្តន៍កម្មវិធីវិស័យហិរញ្ញវត្ថុ | ២០០៧ |

ឧស្សាហកម្ម និង ពាណិជ្ជកម្ម

- កែលំអសេវាកម្មអភិវឌ្ឍន៍អាជីវកម្មសម្រាប់ SME ២០០៦
- SME ទី ២ (PPTA) ២០០៧

វិស័យដឹកជញ្ជូន និង គមនាគមន៍

- កិច្ចអភិវឌ្ឍន៍និងការថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (PPTA) ២០០៥
- GMS: ការស្តារនីតិសម្បទាផ្លូវរថភ្លើងឡើងវិញនៅកម្ពុជា (PPTA) ២០០៥
- GMS: កំណែទម្រង់វិស័យទូរគមនាគមន៍ ២០០៥

វិស័យដទៃទៀត

- GMS: កិច្ចអភិវឌ្ឍន៍វិស័យទេសចរណ៍ដែលទ្រទ្រង់ប្រជាជនក្រីក្រ (PPTA) ២០០៥

[ក] ចុះហត្ថលេខាឥណទាន ខែ វិច្ឆិកា ឆ្នាំ ២០០៤

* ការយល់ព្រមលើឥណទាន ខែ ធ្នូ ឆ្នាំ ២០០៤

## ២. ការកែលំអជីវភាព និងការកាត់បន្ថយភាពងាយរងគ្រោះ

### ក. ការងារអប់រំ និង ការបណ្តុះបណ្តាល

៨០. ការបង្កើនឱកាសទទួលបានការអប់រំ គឺមានសារៈសំខាន់ក្រៃលែងចំពោះការកាត់បន្ថយភាពងាយរងគ្រោះ និង ការកាត់បន្ថយភាពក្រីក្រ។ ថ្វីបើគេឃើញមានវឌ្ឍនភាពជាច្រើននៅក្នុងការកែលំអលទ្ធភាពទទួលបានការអប់រំនៅបឋមសិក្សាក្នុងទស្សវត្សរ៍កន្លងមក ហើយវិភាជន៍ថវិកាសម្រាប់វិស័យអប់រំ បានកើនឡើងក្តី ក៏ប្រទេសកម្ពុជាទំនងជានឹងមិន សម្រេចបាននូវចំណុចដៅ MDG របស់ខ្លួនឡើយចំពោះលទ្ធភាពទទួលបានការអប់រំនៅមធ្យមសិក្សាបឋមភូមិ។ គេឃើញ មានការរីកចំរើនខ្លះក្នុងការធ្វើឱ្យលទ្ធភាពទទួលបានការអប់រំកាន់តែមានលក្ខណៈសមធម៌ ប៉ុន្តែ គម្លាតយេនឌ័រនៅក្នុងវិស័យអប់រំនៅតែមាន ហើយគុណភាពអប់រំចាំបាច់ត្រូវកែលំអនៅគ្រប់កម្រិតទាំងអស់។ ADB គឺជាអ្នកផ្តល់ ជំនួយនាំមុខគេក្នុងការគាំទ្រយុទ្ធសាស្ត្រទូទាំងវិស័យ (SWAp) និង ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០០១-២០០៥ (ESP 2001-2005) របស់រាជរដ្ឋាភិបាល ដែលមានបំណងលើកស្ទួយសមធម៌នៃលទ្ធភាពទទួលសេវាកម្មអប់រំ កែលំអគុណភាព និង ប្រសិទ្ធិភាពអប់រំ គ្រៀងគរធនធានដើម្បីបង្កើនការគាំទ្រថវិកា ពង្រឹងនិងអភិវឌ្ឍសមត្ថភាពស្ថាប័នដើម្បីការងារវិមជ្ឈការ និង ពង្រឹងភាពជាដៃគូជាមួយទីភ្នាក់ងារអ្នកផ្តល់ជំនួយទាំងឡាយ និង ប្រទេសនានា ហើយនិងស្ថាប័នជាតិនិងអន្តរជាតិ។ កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំដែលកំពុងដំណើរការ កំពុងគាំទ្រកំណែទម្រង់គោលនយោបាយ ការកសាងសមត្ថភាពស្ថាប័ន កិច្ចអភិវឌ្ឍន៍បរិក្ខាអប់រំនៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា ហើយនិងការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ។ ADB នឹងបន្តការគាំទ្ររបស់ខ្លួនចំពោះ ESP និង កម្មវិធីគាំទ្រវិស័យអប់រំ (ESSP) ឆ្នាំ ២០០៤-២០០៨ តាមរយៈ (១) ការគាំទ្រការអនុវត្តន៍កំណែទម្រង់គោលនយោបាយ

ដែលនឹងបង្កើនឱកាសសម្រាប់ប្រជាជនក្រីក្រនៅកម្រិតបឋមសិក្សា មធ្យមសិក្សា និង ក្រោយមធ្យមសិក្សា (២) លើកកំពស់លទ្ធភាពទទួលបានការអប់រំនៅមធ្យមសិក្សា តាមមធ្យោបាយកម្មវិធីវិនិយោគមានគោលដៅច្បាស់លាស់សម្រាប់កិច្ចអភិវឌ្ឍន៍បរិក្ខា (៣) ពង្រឹងកិច្ចប្រឹងប្រែងលើការបណ្ដុះបណ្ដាលវិជ្ជាជីវៈក្នុងលក្ខណៈវិមជ្ឈការតាមរយៈ ទស្សនាទានមណ្ឌលសិក្សាអស់មួយជីវិតតាមសហគមន៍ និង លើកទឹកចិត្តដល់ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជន (៤) យកចិត្តទុកដាក់និងពង្រីកកម្មវិធីលើកទឹកចិត្តវិស័យអប់រំសម្រាប់ប្រជាពលរដ្ឋក្រីក្រ ដោយសង្កត់ធ្ងន់លើក្មេងស្រី និងកុមារជនជាតិភាគតិច និង (៥) ផ្ដល់ការគាំទ្រដល់ការកសាងសមត្ថភាពសម្រាប់ការងារអប់រំ ដែលមានលក្ខណៈវិមជ្ឈការ ជាពិសេស នៅកម្រិតក្រោយការអប់រំមូលដ្ឋាន និង នៅក្នុងការងារអប់រំក្រៅប្រព័ន្ធ។ ADB ក៏នឹងបន្តគាំទ្រផងដែរដល់ផែនការក្រុងភ្នំពេញដែលផ្ដល់ការបណ្ដុះ បណ្ដាលជូនដល់មន្ត្រីជាន់ខ្ពស់នៃមហាអនុតំបន់ទន្លេមេគង្គ (GMS)។

### ខ. ជីវភាពជនបទ និងការកាត់បន្ថយភាពងាយរងគ្រោះ

៨១. ក្រោម SWAp របស់ ADB ចំពោះអាងទន្លេសាប ការយកចិត្តទុកដាក់នឹងបន្តផ្ដោតលើការជម្រុញការគ្រប់គ្រង និង ការការពារធនធានធម្មជាតិ ដោយការលើកកំពស់ជីវភាពប្រកបដោយចេរភាពនៅក្នុងតំបន់អាងទន្លេសាប។ ជាក់ស្តែង អន្តរាគមន៍នឹងផ្តោតលើការការពារនិងការបំពេញបន្ថែមលើទ្រព្យរបស់ប្រជាជនក្រីក្រ (ទ្រព្យរូបវ័ន្ត សង្គម និងធម្មជាតិ) តាមរយៈការគ្រប់គ្រងធនធានធម្មជាតិដែលផ្អែកលើសហគមន៍ ការផ្តល់ហេដ្ឋារចនាសម្ព័ន្ធ សហគមន៍ធុនតូច (ឧទាហរណ៍ ផ្លូវជនបទ ស្ពានថ្មើរជើង ម៉ាស៊ីនបូមទឹក ធារាសាស្ត្រតូចតាច អណ្តូងទឹកសហគមន៍ សម្រាប់ទឹកស្អាត ជាដើម) ការបណ្ដុះបណ្ដាលអភិវឌ្ឍន៍ជំនាញ និង កិច្ចអភិវឌ្ឍន៍ស្ថាប័ន និងការកសាងសមត្ថភាព ដើម្បីលើកកំពស់ជីវភាពរស់នៅតាមរយៈសកម្មភាពជំរើសផ្សេងៗទៀត។

៨២. ដូចបានឯកភាពជាមួយធនាគារពិភពលោក ចំពោះមុខការលំបាកខាងធនធាន ADB នឹងដាកចេញពីវិស័យសុខាភិបាលជាបណ្តើៗ ខណៈដែលធនាគារពិភពលោក ធ្វើវិភាជន៍ធនធានបន្ថែមទៀតឱ្យដល់វិស័យសុខាភិបាល។ ជាជំនួសវិញ ADB នឹងដាក់បញ្ចូលការផ្គត់ផ្គង់ទឹកនិងអនាម័យនៅជនបទជាវិស័យថ្មីនៃការយក-ចិត្តទុកដាក់ ដោយសារការខ្វះខាតការគាំទ្ររបស់អ្នកផ្តល់ជំនួយនៅក្នុងវិស័យនេះ និង សារៈសំខាន់របស់វានៅក្នុងការសម្រេចបាននូវ MDGs ដែលទាក់ទិននឹងសុខភាព។ អន្តរាគមន៍ដើម្បីកែលំអការផ្គត់ផ្គង់ទឹក និងអនាម័យនៅជនបទ គឺជាកត្តាធ្វើឱ្យមានការប្រែប្រួល ហើយការចូលរួមនាពេលអនាគតរបស់ ADB ក្នុងវិស័យនេះ នឹងផ្តោតលើអាងទន្លេសាប។ ប៉ុន្តែ ADB នឹងបន្តចូលរួមក្នុងវិស័យសុខាភិបាល តាមរយៈកិច្ចប្រឹងប្រែងដើម្បីទប់ស្កាត់ជម្ងឺឆ្លងដែលអាចត្រូវបានដោះស្រាយយ៉ាងកាន់តែមានប្រសិទ្ធិភាពក្នុងក្របខ័ណ្ឌតំបន់ (GMS)។

# តារាង ២: សំណើគម្រោងដើម្បីកែលំអជីវភាព និង កាត់បន្ថយភាពងាយរងគ្រោះ

| គម្រោងដែលបានស្នើឡើង | ឆ្នាំកម្មវិធី |
|---|---|
| **គម្រោងផ្តល់ឥណទាន** | |
| **កសិកម្ម និង ធនធានធម្មជាតិ** | |
| • ជីវភាពប្រកបដោយចីរភាពនៅតំបន់ទន្លេសាប | ២០០៥ |
| • ការកែលំអបរិស្ថានចុងក្នាស (បម្រុង) | ២០០៥ |
| • ការធ្វើឱ្យមានស្ថេរភាពទំនាបបឹងទន្លេសាប | ២០០៧ |
| • GMS: ការគ្រប់គ្រងទឹកជំនន់ | ២០០៧ |
| **អប់រំ** | |
| • កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំទី ៣ (បម្រុង) | ២០០៧ |
| **សុខាភិបាល អាហារូបត្ថម្ភ និង ការការពារសង្គម** | |
| • GMS: ការទប់ស្កាត់ជម្ងឺឆ្លងនៅតាមតំបន់ព្រំដែន | ២០០៥ |
| **ការផ្គត់ផ្គង់ទឹក អនាម័យ និង ការគ្រប់គ្រងសម្រាម** | |
| • ការផ្គត់ផ្គង់ទឹកនិងអនាម័យនៅជនបទ | ២០០៥ |
| **គម្រោងជំនួយឥតសំណង** | |
| **កសិកម្ម និង ធនធានធម្មជាតិ** | |
| • ការធ្វើឱ្យមានស្ថេរភាពទំនាបបឹងទន្លេសាប (PPTA) | ២០០៥ |
| • ការសិក្សាលើឥទ្ធិពលនៃរចនាសម្ព័ន្ធលើការនេសាទនៃទន្លេសាប | ២០០៥ |
| • ការកសាងសមត្ថភាពនៃវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍នេសាទទឹកសាបទី ២ | ២០០៥ |
| • ការគ្រប់គ្រងទីជម្រាលទន្លេសាប (PPTA) | ២០០៦ |
| • GMS: ការគ្រប់គ្រងទឹកជំនន់ (PPTA) | ២០០៦ |
| • លើកកំពស់សកម្មភាពដើម្បីអនុវត្តអនុសញ្ញាក្រុងស្តុកខុមស្តីពីសារធាតុបំពុលសរីរាង្គមិនរលាយ | ២០០៧ |
| • លើកស្ទួយតួនាទីរបស់ស្ត្រីក្នុងនេសាទទឹកសាប | ២០០៧ |
| • ការសិក្សាលើគំរូពាណិជ្ជកម្មធនធានទឹកសាប | ២០០៧ |
| **អប់រំ** | |
| • អន្តេវាសិកដ្ឋានសម្រាប់សិស្សនារីកម្រិតមធ្យមសិក្សា | ២០០៥ |
| • កិច្ចអភិវឌ្ឍន៍វិស័យអប់រំ (PPTA) | ២០០៦ |
| **ឧស្សាហកម្ម និង ពាណិជ្ជកម្ម** | |
| • មជ្ឈមណ្ឌលដើម្បីគាំទ្រលើកតំកើងស្ត្រី | ២០០៥ |
| **ការផ្គត់ផ្គង់ទឹក អនាម័យ និង ការគ្រប់គ្រងសម្រាម** | |
| • ការផ្គត់ផ្គង់ទឹកប្រកបដោយចេរភាពនិងអនាម័យនៅជនបទ (PPTA) | ២០០៥ |
| • គម្រោងផ្គត់ផ្គង់ទឹកនិងអនាម័យនៅតំបន់ទន្លេសាប (PPTA) | ២០០៧ |

## ៣. ការពង្រឹងអភិបាលកិច្ចដើម្បីកិច្ចអភិវឌ្ឍន៍

៨៣. ដូចបានលើកឡើងនៅក្នុងកថាខ័ណ្ឌ ១៦-២៣ កម្ពុជាប្រឈមមុខនឹងចំណោទអភិបាលកិច្ចដ៏ធ្ងន់ធ្ងរ។ ចំពោះមុខទំហំនៃរបៀបវារៈនេះ វាគឺជាប្រការសំខាន់ដែលដៃគូអភិវឌ្ឍន៍ត្រូវសម្របសម្រួលកិច្ចប្រឹងប្រែងរបស់ខ្លួន។ ហេតុនេះ ADB នឹងគាំទ្រគំនិតផ្តួចផ្តើមរបស់រដ្ឋាភិបាលដើម្បី (១) កែលំអគណនេយ្យភាព និង ការផ្តល់សេវាកម្មជូនដល់ប្រជាពលរដ្ឋរបស់ខ្លួនតាមរយៈ PFM វិមជ្ឈការ និង ការបង្កើនការចូលរួមក្នុងការគ្រប់គ្រងធនធាននៅមូលដ្ឋាន (២) បង្កើនកិច្ចប្រឹងប្រែងដើម្បីសម្រេចឱ្យបាននូវកំណែទម្រង់ខាងច្បាប់ បទប្បញ្ញត្តិ និង គោលនយោបាយនៅក្នុងវិស័យទាំងឡាយដែលមានសារៈសំខាន់ចំពោះកំណើន ដូចជាវិស័យហិរញ្ញវត្ថុ SMEs កសិកម្ម អប់រំ ទូរគមនាគមន៍ និង ផ្លូវរថភ្លើង (៣) បន្តគាំទ្រការកសាងសមត្ថភាពស្ថាប័នដើម្បីកែលំអរអភិបាលកិច្ច និងប្រសិទ្ធិភាពសាជីវកម្មនៅក្នុងវិស័យទាំងឡាយដែលនៅក្នុងនោះ ADB មានប្រតិបត្តិការ និង (៤) កែលំអរ ការរៀបចំ និងការអនុវត្តន៍គម្រោង ដូចជាការរៀបចំនិយាមនីតិវិធីប្រតិបត្តិការ ដើម្បីលើកកំពស់ប្រសិទ្ធិភាព និងប្រសិទ្ធិផល។ ដោយសារក៏រិតធនធាន និងការចូលរួមរបស់ដៃគូដទៃទៀត ADB នឹងមិនចូលរួមដោយផ្ទាល់ទេនៅក្នុងវិស័យ កំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ (សូមមើលផងដែរនូវឧបសម្ព័ន្ធ ១ តារាង ក១.៥)។

៨៤. អំពើពុករលួយគឺជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរមួយ។ នៅកម្ពុជា អំពើពុករលួយ ត្រូវបានគេទទួលស្គាល់ថាបានរារាំងយ៉ាងធ្ងន់ធ្ងរដល់កំណើនសេដ្ឋកិច្ច កិច្ចអភិវឌ្ឍន៍វិស័យឯកជន និង ការកាត់បន្ថយភាពក្រីក្រ និង ធ្វើឱ្យខូចខាតដល់វិធានច្បាប់។ ADB នឹងធ្វើការរួមគ្នាជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀតរបស់កម្ពុជា និង រាជរដ្ឋាភិបាល ដើម្បីបង្កើនគណនេយ្យភាព និង ប្រយុទ្ធប្រឆាំងអំពើពុករលួយ។ យុទ្ធវិធីរបស់ ADB ចំពោះការប្រយុទ្ធប្រឆាំងអំពើពុករលួយ គឺផ្អែកលើដំណោះស្រាយទិដ្ឋភាពជាប្រព័ន្ធ និងទិដ្ឋភាពស្ថាប័ននៃអំពើពុករលួយ ដោយ (១) កាត់បន្ថយឱកាសសម្រាប់អំពើពុករលួយ ដោយរៀបចំ និង ជម្រុញច្បាប់និងនីតិវិធីដែលមានលក្ខណៈសាមញ្ញ (២) បង្កើន "សម្លេង" ប្រឆាំងអំពើពុករលួយដោយលើកទឹកចិត្តដល់ការចូលរួមក្នុងកិច្ចអភិវឌ្ឍន៍ (៣) បង្កើន តម្លាភាពនិងប្រសិទ្ធិភាពនៅក្នុងការគ្រប់គ្រងសាធារណៈ ជាពិសេស PFM និង វិស័យហិរញ្ញវត្ថុ និង (៤) ធ្វើការ ត្រួតពិនិត្យយ៉ាងមធ្យ័តលើគម្រោងទាំងឡាយរបស់ ADB ។

### តារាង ៣: សំណើគម្រោងដើម្បីពង្រឹងអភិបាលកិច្ចដើម្បីកិច្ចអភិវឌ្ឍន៍

| គម្រោងដែលបានស្នើឡើង | ឆ្នាំកម្មវិធី |
|---|---|
| **គម្រោងផ្តល់ឥណទាន** | |
| កែលំអរគណនេយ្យភាព និង ការផ្តល់សេវាកម្ម | |

- បរិក្ខារសម្រាប់ក្រុមប្រឹក្សាឃុំ-សង្កាត់ តំណាក់កាលទី ២ | ២០០៦

កំណែរទម្រង់ច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ និង ការកសាងសមត្ថភាពស្ថាប័ន

- កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម | ២០០៤,២០០៥[ក]
- កិច្ចអភិវឌ្ឍន៍វិស័យ SME | ២០០៤,២០០៥*
- កម្មវិធីវិស័យហិរញ្ញវត្ថុទី ១ (កម្មវិធីរងទី ៣) | ២០០៥
- កិច្ចអភិវឌ្ឍន៍និងការថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន | ២០០៦
- កិច្ចអភិវឌ្ឍន៍វិស័យគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនិងធនធានទឹក | ២០០៧
- កម្មវិធីវិស័យហិរញ្ញវត្ថុទី ២ (កម្មវិធីរងទី ១) | ២០០៧
- កម្មវិធីអភិវឌ្ឍន៍វិស័យអប់រំទី ៣ (បម្រុង) | ២០០៧

**គម្រោងជំនួយឥតសំណង**

កែលំអរគណនេយ្យភាព និង ការផ្តល់សេវាកម្ម

- បរិក្ខារសម្រាប់ក្រុមប្រឹក្សាឃុំ-សង្កាត់ តំណាក់កាលទី ២ (PPTA) | ២០០៥
- កម្មវិធីគាំទ្រវិមជ្ឈការ (PPTA) | ២០០៦
- ការគាំទ្រចំពោះការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទី ២ | ២០០៧

កំណែទម្រង់ច្បាប់ បទប្បញ្ញត្តិ គោលនយោបាយ និង ការកសាងសមត្ថភាពស្ថាប័ន

- ការបង្កើតអង្គការគ្រប់គ្រងអាងទន្លេសាប ទី ៣ | ២០០៥
- ការអនុវត្តន៍កម្មវិធីវិស័យហិរញ្ញវត្ថុ | ២០០៥
- កិច្ចអភិវឌ្ឍន៍និងការថែទាំហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (PPTA) | ២០០៥
- GMS: ការស្តារនិតិសម្បទាផ្លូវថភ្លើងឡើងវិញនៅកម្ពុជា (PPTA) | ២០០៥
- GMS: កំណែទម្រង់វិស័យទូរគមនាគមន៍ | ២០០៥
- ការកសាងសមត្ថភាពសម្រាប់គំនិតផ្តួចផ្តើមកាត់បន្ថយភាពក្រីក្រនៅតំបន់ទន្លេសាប ទី ២ | ២០០៦
- ការបង្កើតអង្គការគ្រប់គ្រងអាងទន្លេសាប ទី ៤ | ២០០៦
- ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រនិងធនធានទឹក (PPTA) | ២០០៦
- កម្មវិធីវិស័យហិរញ្ញវត្ថុ ទី ២ (PPTA) | ២០០៦
- ការអនុវត្តន៍កម្មវិធីវិស័យហិរញ្ញវត្ថុ | ២០០៧
- SME ទី ២ (PPTA) | ២០០៧
- កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម ទី ២ (PPTA) | ២០០៧
- ការបង្កើតអង្គការគ្រប់គ្រងអាងទន្លេសាប ទី ៥ | ២០០៧

[ក] ចុះហត្ថលេខាឥណទាន ខែ វិច្ឆិកា ឆ្នាំ ២០០៤

* ការយល់ព្រមលើឥណទាន ខែ ធ្នូ ឆ្នាំ ២០០៤

## ក. ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៨៥. ADB នឹងសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀតដើម្បីគាំទ្រការអនុវត្តកម្មវិធីកំណែទម្រង់ PFM ដ៏ពេញលេញនិងដែលមានលំដាប់លំដោយសមស្របរបស់រាជរដ្ឋាភិបាល ។ ជំនួយ ADB ដែលនៅក្នុងដំណាក់កាលទីមួយគឺសំដៅធ្វើឱ្យថវិកាមានលក្ខណៈអាចទុកចិត្តបាន នឹងស្ថិតនៅក្នុងបរិបទនៃ SWAp ដែល

ឯកភាពគ្នា និង ដោយផ្អែកលើលទ្ធផលដែលបានសម្រេចក្នុងអន្តរាគមន៍មុនៗរបស់ ADB (ពោលគឺ អង្កេតតាមដានចំណាយសាធារណៈ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និង សវនកម្មសាធារណៈ)។

### ខ. វិមជ្ឈការ

៨៦. ការគាំទ្ររបស់ ADB ចំពោះវិមជ្ឈការ គឺបានផ្តោតលើការពង្រឹងសមត្ថភាពស្ថាប័ននៃក្រុមប្រឹក្សាឃុំ-សង្កាត់ ដោយគាំទ្រការបង្កើតបរិក្ខារឃុំ-សង្កាត់ និង ការផលិតផែនទីដើម្បីសម្រួលការអនុវត្តន៏ច្បាប់ភូមិបាលក្នុងកម្រិតឃុំ-សង្កាត់។ វិនិយោគទាំងនេះ ត្រូវបានបំពេញបន្ថែមដោយសកម្មភាពកសាងសមត្ថភាពជូនដល់សមាជិកក្រុមប្រឹក្សា បុគ្គលិក និង ការគាំទ្រដល់ស្ថាប័នរដ្ឋបាលមូលដ្ឋាននានា។ ADB នឹង បន្តគាំទ្រការផ្តល់បរិក្ខារឃុំ-សង្កាត់ និង ការកសាងសមត្ថភាពរដ្ឋាភិបាលមូលដ្ឋាន ទន្ទឹមគ្នានឹងកិច្ចសហការជាមួយរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ដទៃទៀត ដើម្បីរៀបចំប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានដ៏ពេញលេញមួយ ជាមួយនឹងរចនាសម្ព័ន្ធដែលមានលក្ខណៈសុខុដុមនីយកម្មសម្រាប់ការផ្តល់សេវាកម្ម។ អន្តរាគមន៍ ADB ដទៃទៀតនៅក្នុងផ្នែកជីវភាពជនបទ ជាពិសេស ការគ្រប់គ្រងធនធានធម្មជាតិ នឹងគាំទ្រដោយផ្ទាល់ចំពោះកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីលើកស្ទួយតួនាទី និង សមត្ថកិច្ចនៃរដ្ឋាភិបាលមូលដ្ឋាន។

### គ. ការសម្របសម្រួលការផ្តល់មូលនិធិបរទេស និង កិច្ចព្រមព្រៀងភាពជាដៃគូ

៨៧. កម្ពុជាគឺជាប្រទេសមួយក្នុងចំណោមប្រទេសអាស៊ី-ប៉ាស៊ីហ្វិកដែលនាំមុខគេក្នុងការរៀបចំអនុវត្តសេចក្តី-ថ្លែងការក្រុងរ៉ូមស្តីពីសុខុដុមនីយកម្ម។ រាជរដ្ឋាភិបាល ក្នុងកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍សំខាន់ៗ រួមមាន ADB បានជម្រុញយ៉ាងសកម្មនូវសុខុដុមនីយកម្មកាន់តែច្រើនរវាងដៃគូ និង តំរង់ទិសដៅនៃកម្មវិធីជំនួយរបស់ខ្លួន ជាមួយយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្នូលរបស់រាជរដ្ឋាភិបាល។ ផែនការសកម្មភាព ស្តីពីសុខុដុមនីយកម្ម និង សង្គតភាព ត្រូវបានព្រាងជាមួយនឹងជំនួយរបស់ដៃគូទាំងឡាយ។ ពង្រាងនេះ នឹងមានតួនាទីតំរែតំរង់សម្រាប់កែលំអការសម្របសម្រួល។ សេចក្តីថ្លែងការណ៍ ស្តីពីភាពជាដៃគូ ដែលត្រូវបានចុះហត្ថលេខាដោយរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍សំខាន់ៗ គឺផ្អែកលើការអនុវត្តន៏កម្រិតប្រទេស នូវសេចក្តីថ្លែងការណ៍ក្រុងរ៉ូម ស្តីពីសុខុដុមនីយកម្ម និង កំណត់គោលដៅចំបងទាំងឡាយនៃសុខុដុមនីយកម្ម និង សង្គតភាពកាន់តែច្រើនឡើងនៃជំនួយ បរទេស។ យន្តការគោល សម្រាប់ការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ គឺតាមរយៈ TWGs មួយចំនួន។ តាមសំណើរបស់រាជរដ្ឋាភិបាល TWGs ត្រូវបានរៀបចំឡើងវិញដើម្បីលើកកំពស់ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល និង ផ្តល់នូវមូលដ្ឋានសម្រាប់ការគ្រប់គ្រង ODA ឱ្យបានកាន់តែមានប្រសិទ្ធិភាពនៅក្នុងវិស័យជាអាទិភាព និង ផ្នែកប្រធានបទចំនួន ១៧ សម្រួលការពិភាក្សារបស់រាជរដ្ឋាភិបាល និង អ្នកផ្តល់ជំនួយជាមួយសង្គមស៊ីវិល វិស័យឯកជន និង ភាគីពាក់ព័ន្ធដទៃទៀត។ បេសកកម្ម

ប្រចាំប្រទេសកម្ពុជារបស់ ADB នឹងបន្តដើរតួនាទីនាំមុខនៅក្នុងការធ្វើសុខុដុមនីយកម្មអ្នកផ្តល់ជំនួយ និង នៅក្នុង TWGs ។

៨៨. កម្មវិធីជំនួយរបស់ ADB ត្រូវបានរៀបចំឡើងក្នុងកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍សំខាន់ៗដទៃទៀត ។ ជាពិសេស ADB ធនាគារពិភពលោក និង DFID បានរៀបចំយុទ្ធសាស្រ្តប្រចាំប្រទេសកម្ពុជាក្នុងកិច្ចសហប្រតិបត្តិការនិងការសម្របសម្រួលគ្នាដ៏ជិតស្និទ្ធដែលមិនដែលមានពីមុនមក ។ យុទ្ធសាស្រ្តទាំងនេះត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់ដ៏ជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល អ្នកផ្តល់ជំនួយ សង្គមស៊ីវិល និង វិស័យឯកជន ។ ដោយធ្វើការរួមគ្នា ដៃគូទាំងឡាយសង្ឃឹមថានឹងបានកែលំអការយល់ដឹងរួមរបស់ខ្លួនអំពីចំណោទអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា និង ដើម្បីអនុវត្តការឆ្លើយតបប្រកបដោយលក្ខណៈសម្របសម្រួលមួយកាត់បន្ថយចំណាយប្រតិបត្តិការរបស់រាជរដ្ឋាភិបាលក្នុងការធ្វើការងារជាមួយដៃគូអភិវឌ្ឍន៍របស់ខ្លួន (សូមមើលកថាខ័ណ្ឌ ៦៤ ផង) ។ ភាពជាដៃគូពុំមែនមានលក្ខណៈដាច់ដោយឡែកឡើយ ពោលគឺជាផ្នែកមួយនៃកិច្ចប្រឹង-ប្រែងដើម្បីបង្កើនកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀត ទាំងនៅក្នុងកម្រិតយុទ្ធសាស្រ្ត និង ទាំងនៅក្នុងកម្រិតប្រតិបត្តិការ (ឧទាហរណ៍ ថ្មីៗនេះ UN បានចូលរួមក្នុងដំណើរការរៀបចំយុទ្ធសាស្រ្តនៃស្ថាប័នទាំងបី) ។[២២] ADB ក៏នឹងពង្រឹងផងដែរនូវការចូលរួមរបស់សង្គមស៊ីវិលនៅក្នុងប្រតិបត្តិការរបស់ខ្លួននៅកម្ពុជា និង ខិតខំ ពង្រឹងទំនាក់ទំនងជាមួយ NGOs ក្រុមសហគមន៍ វិស័យឯកជន និង ក្រសួងពាក់ព័ន្ធ ដើម្បីជម្រុញអភិបាលកិច្ច ការចូលរួមរបស់សហគមន៍ និង ការផ្តល់សេវាកម្ម ឱ្យបានកាន់តែប្រសើរឡើង ។

៨៩. ADB នឹងបន្តសហការយ៉ាងជិតស្និទ្ធ និង អភិវឌ្ឍបន្ថែមទៀតនូវទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀតនៅក្នុងកម្រិតយុទ្ធសាស្រ្តនិងគម្រោង ។ គំនិតផ្តួចផ្តើមដើម្បីគាំទ្រ GMS នឹងមានសារៈសំខាន់ជាពិសេស ។ ADB បានសហការយ៉ាងជិតស្និទ្ធជាមួយ UN គណៈកម្មការទន្លេមេគង្គ និង ធនាគារពិភពលោក និង ជាមួយដៃគូឧភតោភាគីមួយចំនួនទៀត រួមទាំងរដ្ឋាភិបាលជប៉ុនផងដែរ លើយុទ្ធសាស្រ្តប្រចាំប្រទេស និងយុទ្ធសាស្រ្តតាមវិស័យនៅក្នុងតំបន់ទន្លេមេគង្គ ។ រដ្ឋាភិបាលជប៉ុន គឺជាអ្នកគាំទ្រដ៏ធំមួយតាមរយៈការគាំទ្រខាង TA ចេញពី JSF សម្រាប់ការកសាងសមត្ថភាព និង ចេញពី JFPR សម្រាប់ការកាត់បន្ថយភាពក្រីក្រ ។ ADB ក៏បានចុះកិច្ចព្រមព្រៀងសហប្រតិបត្តិការក្នុងភាពជាដៃគូជាមួយ NGOs ដូចជា មូលនិធិពិភពលោកសម្រាប់ធម្មជាតិជាដើម ។ រដ្ឋាភិបាលហ្វាំងឡង់ គឺជា អ្នកគាំទ្រដ៏សកម្មចំពោះគំនិតផ្តួចផ្តើមទន្លេសាប ។ ADB កំពុងសហការយ៉ាងជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍ ភាគច្រើន តាមរយៈ SWAp វិស័យអប់រំ ។ នៅក្នុងវិស័យសុខាភិបាល ADB

[២២] អង្គការសហប្រជាជាតិ (UN) ក៏បានប្រើផងដែរនូវការវិភាគរួមលើនិន្នាការនិងបញ្ហាអភិវឌ្ឍន៍បច្ចុប្បន្ននៅក្នុង CSP នេះ (ជំពូក ១) សម្រាប់ដំណើរការរៀបចំក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍អង្គការសហប្រជាជាតិ (UNDAF) របស់ខ្លួន ។

កំពុងធ្វើការជាមួយ DFID និង ធនាគារពិភពលោកដើម្បីគាំទ្រយុទ្ធសាស្ត្រវិស័យសុខាភិបាល។ ADB នឹងសហការជាមួយអង្គការ Deutsche Gesellschaft für Technische Zusammenarbeit (GTZ) និង ធនាគារពិភពលោក ដើម្បីជួយរាជរដ្ឋាភិបាល ក្នុងការរៀបចំក្របខ័ណ្ឌច្បាប់សម្រាប់ធនធានដីធ្លី។ រដ្ឋាភិបាលបារាំងបានធ្វើការជាមួយ ADB នៅក្នុង វិស័យអភិវឌ្ឍន៍ជនបទ និង វិស័យថាមពល។

៩០. SWAps ឬ PBAs នឹងត្រូវបានជំរុញកាន់តែច្រើនថែមទៀត ដើម្បីធ្វើសុខដុមនីយកម្មនៃជំនួយអភិវឌ្ឍន៍។ ADB គឺជាអ្នកត្រួសត្រាយ SWAps មួយនៅក្នុងប្រទេសកម្ពុជា នឹងប្រើបទពិសោធន៍របស់ខ្លួននៅក្នុងការអនុវត្តន៍ជាជម្រើសនូវ SWAps ឬ PBAs ចំពោះកម្មវិធីជំនួយ ដើម្បីកែលំអមុខព្រួញនៃជំនួយពីក្រៅ កាត់បន្ថយ ចំណាយប្រតិបត្តិការ និង ធានាឱ្យបាននូវភាពរលូននៃការប្រឹក្សាជូនរដ្ឋាភិបាល។ នៅទីណាដែល SWAps ឬ PBAs មិនអាចអនុវត្តបាន (ឧទាហរណ៍ដោយសារប្រភេទនៃអន្តរាគមន៍ ឬ កង្វះដៃគូអភិវឌ្ឍន៍ដ៏សកម្មដទៃទៀត) ADB នឹងអនុវត្តយ៉ាងសកម្មនូវការប្រមូលហិរញ្ញប្បទានពីប្រភពផ្សេងៗតាមតែអាចធ្វើទៅបាន។ ADB នឹងរក្សាការពិភាក្សាជាមួយរាជរដ្ឋាភិបាល ដើម្បីកំណត់ហិរញ្ញប្បទានសមស្របលើគម្រោងដែល ADB នឹងគាំទ្រក្នុងរយៈពេល ឆ្នាំ ២០០៥-២០០៩ ជាក់ស្តែង គឺប្រើប្រាស់ឥណទានរបស់ខ្លួន។

### ឃ. តម្រូវការធនធានផ្ទៃក្នុងក្នុងលក្ខណៈចង្អុលបង្ហាញ

៩១. ផ្អែកលើមេគុណពេលវេលាបុគ្គលិកក្នុងទូទាំង ADB សម្រាប់ឆ្នាំ ២០០៤ និង សំណើកម្មវិធីការងារឆ្នាំ ២០០៥ សម្រាប់កម្ពុជា តម្រូវការធនធានបុគ្គលិកបច្ចុប្បន្នដើម្បីអនុវត្តប្រតិបត្តិការស្នូលរបស់ ADB នៅកម្ពុជា គឺត្រូវបានប៉ាន់ស្មានជាបណ្តោះអាសន្នថាមានចំនួន ៥០៣ សប្តាហ៍បុគ្គលិក។[២៣] ប៉ុន្តែ ចំនួននេះមិនរាប់បញ្ចូលការងារលើឥណទាន GMS និង កម្មវិធី TA និង គំនិតផ្តួចផ្តើមដទៃទៀតមួយចំនួន ដូចជាការគ្រប់គ្រងដើម្បីទទួលបានលទ្ធផលល្អ សុខុដុមនីយកម្មអ្នកផ្តល់ជំនួយ និង បណ្តាសកម្មភាពទាក់ទិននឹង TWGs ទាំង ១៧ ដែលតម្រូវឱ្យមានធនធានបន្ថែមទៀត និង កំណើនដ៏ច្រើននៃពេលវេលាបុគ្គលិក។

## ៦. ការត្រួតពិនិត្យនិងការវាយតម្លៃស្នាដៃនិងហានិភ័យ

### ក. ហានិភ័យ

៩២. យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល និង CSP ប្រឈមមុខនឹងហានិភ័យមួយចំនួន។ ប្រទេសកម្ពុជាគឺស្ថិតនៅក្នុងដំណាក់កាលមួយដ៏សំខាន់ ខណៈដែលប្រទេសងាកចេញពីស្ថានភាពក្រោយវិវាទ ឆ្ពោះទៅ

[២៣] ចំនួននេះមិនរាប់បញ្ចូលចំនួនសប្តាហ៍នៃបុគ្គលិកជាតិឡើយ។

កាន់តំរូអភិវឌ្ឍន៍កាន់តែប្រក្រតី។ ការចូលរួមដ៏ពេញលេញរបស់កម្ពុជានៅក្នុងទំនាក់ទំនងក្នុងតំបន់និងពិភពលោក បានកាត់បន្ថយភាពមិនប្រាកប្រជាខាងនយោបាយ និង បានរួមចំណែកដល់កំណើននៃភាពអាចព្យាករណ៍គោល-នយោបាយ។ លើសពីនេះទៅទៀត កម្ពុជាត្រូវតែគោរពតាមគោលការណ៍ថ្មីៗអន្តរជាតិផងដែរ។ យុទ្ធសាស្ត្ររួមរបស់ ADB DFID និង ធនាគារពិភពលោក ត្រូវបានគ្រោងដើម្បីសម្រាល ឬ គ្រប់គ្រងហានិភ័យទាំងនេះ។

៩៣. **សមត្ថភាពទន់ខ្សោយនៅក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង គ្រឿងលើកទឹកចិត្តមិនគ្រប់គ្រាន់សម្រាប់អង្គការរដ្ឋបាលស៊ីវិលនាំឱ្យមានអំពើពុករលួយ រាំងដល់ការផ្តល់សេវាកម្មសាធារណៈ និង បន្ថយល្បឿនការអនុវត្តនីកំណែទម្រង់សំខាន់ៗទាំងឡាយ។** សមត្ថភាពមិនគ្រប់គ្រាន់ដើម្បីលើកស្ទួយនិងគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាឧបសគ្គចំបងចំពោះលទ្ធភាពរបស់រាជរដ្ឋាភិបាលក្នុងការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍របស់ខ្លួន។ ការលំបាកនេះត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរដោយប្រាក់បៀវត្សរ៍ដ៏ទាបនៃវិស័យសាធារណៈ ដែលបង្ខំឱ្យមន្ត្រីរាជការត្រូវពឹងផ្អែកលេកំរៃក្រៅផ្លូវការ ឬ ឱកាសរកចំណូលផ្សេងទៀត ដើម្បីធានាឱ្យបាននូវប្រាក់ខែដែលអាចរស់បាន។ កត្តាទាំងនេះបានរាំងដល់ការផ្តល់សេវាកម្មសាធារណៈ និង បានធ្វើឱ្យអំពើពុករលួយក្លាយទៅជាបញ្ហាដ៏ធំមួយ។ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍របស់ខ្លួនលើកម្មវិធីកំណែទម្រង់ PFM ដ៏ពេញលេញ ដែលដាក់បញ្ចូលគ្នានូវបណ្តាអភិក្រមជាប្រព័ន្ធចំពោះការទប់ស្កាត់អំពើពុករលួយ និង ចំពោះសកម្មភាពលើគ្រឿងលើកទឹកចិត្តសម្រាប់អង្គការរដ្ឋបាលស៊ីវិល ADB DFID និង ធនាគារពិភពលោកនឹងសំដៅសម្រាល និង គ្រប់គ្រងហានិភ័យនេះ។ ការគាំទ្រចំពោះអភិបាលកិច្ចមូលដ្ឋានត្រូវបានគ្រោងដើម្បីពង្រឹងការចូលរួមរបស់មូលដ្ឋាននៅក្នុងកិច្ចការរដ្ឋាភិបាល កែលំអរការផ្តល់សេវាកម្មសាធារណៈ និង កាត់បន្ថយឱកាសសម្រាប់អំពើពុករលួយ។

៩៤. **ភាពប្រកួតប្រជែងពិភពលោករបស់កម្ពុជាគឺមានលក្ខណៈផុយស្រួយ។** សេដ្ឋកិច្ចកម្ពុជាគ មានទំហំតូច និងងាយរងគ្រោះចំពោះវិបត្តិ។ កំណើនថ្មីៗនេះគឺពឹងផ្អែកយ៉ាងច្រើនលើវិស័យមួយចំនួនតូច ដូចជាសំលៀកបំពាក់ និងទេសចរណ៍ដែលងាយរងគ្រោះចំពោះការប្រែប្រួលអវិជ្ជមាននៅក្នុងទីផ្សារប៉ុណ្ណោះ និងស្ថានភាពនយោបាយពិភពលោក។ ប្រសិនបើកម្ពុជាមិនអាចធ្វើពិពិធកម្មនិងពង្រីកសេដ្ឋកិច្ចរបស់ខ្លួន លទ្ធភាពកំណើននិងការកាត់បន្ថយភាពក្រីក្រ អាចរងការខូចខាតធ្ងន់ធ្ងរ។ យុទ្ធសាស្ត្ររួមទាំងនេះ គឺត្រូវបានគ្រោងដើម្បីសម្រាលភាពប្រឈមទាំងនេះ ដោយផ្តោតជំនួយលើផលិតភាព និងការតម្រង់ទិសទៅរកទីផ្សារនៃវិស័យកសិកម្ម ការផ្តល់សេវាកម្មខាងហេដ្ឋារចនាសម្ព័ន្ធ កិច្ចអភិវឌ្ឍន៍ វិស័យហិរញ្ញវត្ថុ និងបង្កើនបរិស្ថានអំណោយផលសម្រាប់កំណើនវិស័យឯកជនជាទូទៅ និងដោយឡែកចំពោះការរីកចំរើននៃ SMEs។

៩៥. **ការសម្របសម្រួលអ្នកផ្តល់ជំនួយមិនបានប្រសើរឡើង ហើយចំណាយប្រតិបត្តិការចំពោះរាជរដ្ឋាភិបាលកើនឡើង។** ការសម្របសម្រួលអ្នកផ្តល់ជំនួយកាន់តែប្រសើរឡើង ត្រូវតែឈានហួសការពិភាក្សាទៅដល់ការកែលំអផលប៉ះពាល់ជាក់ស្តែង។ គេក៏ឃើញមានហានិភ័យផងដែរដែលថា ADB DFID និង ធនាគារពិភពលោក អាចធ្វើការរួមគ្នាបានយ៉ាងល្អ ប៉ុន្តែអាចមិនមានការសហការការគ្នាបានល្អជាមួយអ្នកផ្តល់ជំនួយដទៃទៀត។ ដើម្បីសម្រាលហានិភ័យនេះ ស្ថាប័នទាំងបី បានសន្យាអនុវត្តអភិក្រមដែលមានការចូលរួមមួយ។ គំនិតផ្តួចផ្តើមថ្មីៗដើម្បីរៀបចំ TWGs ឡើងវិញ និងធ្វើសុខុដុមនីយកម្មនីតិវិធីអ្នកផ្តល់ជំនួយ ក៏គឺដើម្បីបន្ថយហានិភ័យទាំងនេះនិងកែលំអរផងដែរនូវប្រសិទ្ធិភាពនៃការផ្តល់ជំនួយ។

៩៦. **គំនិតផ្តួចផ្តើមអភិបាលកិច្ចផ្សេងៗមិនបានសម្រេចតាមការរំពឹងឡើយ។** គេឃើញមានការទទួលស្គាល់យ៉ាងច្បាស់នៅក្នុងចំណោមរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ថាការកែលំអអភិបាលកិច្ចគឺមានសារៈសំខាន់ក្រៃលែងចំពោះការកែលំអរប្រសិទ្ធិភាពអភិវឌ្ឍន៍។ ដៃគូអភិវឌ្ឍន៍ភាគច្រើន បានបង្កើនការយកចិត្តទុកដាក់របស់ខ្លួនលើអភិបាលកិច្ច និង បានចាប់ផ្តើមគម្រោងនិងកម្មវិធីទាំងឡាយដើម្បីជួយកសាងសមត្ថភាពរាជរដ្ឋាភិបាលក៏ដូចជាយន្តការដើម្បីបង្កើនគណនេយ្យភាពសាធារណៈផងដែរ។ ប៉ុន្តែ ការងារនេះ ជាដំណើរការមួយដ៏វែងនិងដ៏ស្មុគ្រស្មាញដែលតម្រូវឱ្យមានកំណែទម្រង់ជ្រាលជ្រៅនិងប្រកបដោយអត្ថន័យនៅតាមស្ថាប័ន ការស្រុះស្រួលគ្នា ការជឿជាក់ផ្ទៃក្នុងដ៏រឹងមាំ និងភាពជាម្ចាស់។ ប្រការនេះ មិនមែនជាការងាយស្រួលឡើយ ហើយពុំអាចសំរេចបានដំណើរការសម្រាប់កំណែទម្រង់បរិសុទ្ធទេ ប្រសិនបើការប្តេជ្ញាចិត្តចំពោះកំណែទម្រង់មានលក្ខណៈទន់ខ្សោយ។ ដើម្បីបន្ថយហានិភ័យនេះ បរិមាណនៃជំនួយពីស្ថាប័នទាំងបីនេះ នឹងត្រូវបានផ្សាភ្ជាប់យ៉ាង ច្បាស់លាស់ទៅនឹងវឌ្ឍនភាពនៃកំណែទម្រង់។

៩៧. **កំណើនភាពស្មុគ្រស្មាញនៃគម្រោងបណ្តាលឱ្យមានការថយចុះគុណភាព។** គុណភាពនៃផលប័ត្រលីយ៉ូនៃស្ថាប័នអភិវឌ្ឍន៍ទាំងបី អាចធ្លាក់ចុះនៅពេលដែលស្ថាប័នជំនួយអភិវឌ្ឍន៍ទាំងបីនេះ ដែលកាន់តែមានលក្ខណៈស្មុគ្រស្មាញឡើង។ យុទ្ធសាស្ត្ររួមគ្នានេះ នឹងជួយសម្រាលហានិភ័យនេះដោយបន្តផ្តល់ TA គ្រប់គ្រាន់ដើម្បីគាំទ្រការរៀបចំគម្រោង និងការកសាងធនធានមនុស្សនិងសមត្ថភាពស្ថាប័ន។ គេនឹងឃើញមានការយកចិត្តទុកដាក់កាន់តែច្រើនឡើងផងដែរលើការចូលរួមរបស់ភាគីពាក់ព័ន្ធនៅក្នុងការលើកគម្រោង ការអនុវត្តន៍ និងការត្រួតពិនិត្យគម្រោង។

## ខ. ការត្រួតពិនិត្យដំណើរការនិងផែនការ

៩៨. រាជរដ្ឋាភិបាលទទួលស្គាល់ភាពចាំបាច់ក្នុងការកសាងសមត្ថភាពស្ថាប័នរបស់ខ្លួនលើការគ្រប់គ្រង ការត្រួតពិនិត្យ និង ការវាយតម្លៃកិច្ចអភិវឌ្ឍន៍។ ដើម្បីសម្រេចគោលដៅនេះ TWGs រាជរដ្ឋាភិបាល-អ្នកផ្តល់ជំនួយ ដែលត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញ នឹងគាំទ្រការអនុវត្តន៍យុទ្ធសាស្ត្រចតុកោណ តាមរយៈផែនការសកម្មភាព និងសូចនាករនៅក្នុងកម្រិតវិស័យនិងប្រធានបទ ដែលនឹងត្រូវបានត្រួតពិនិត្យរួមគ្នា។

៩៩. ADB នឹងគាំទ្រយ៉ាងសកម្មដល់ TWGs ទាំងឡាយណាដែលខ្លួនចូលរួម។ ADB DFID និង ធនាគារពិភពលោក នឹងត្រួតពិនិត្យនិងវាយតម្លៃរួមគ្នាលើបណ្តាវិស័យដែលពួកគេចូលរួម និងដែលគេមានតួនាទីគាំទ្រ។ ADB DFID និង ធនាគារពិភពលោក នឹងជួបប្រជុំគ្នាពីរដងក្នុងមួយឆ្នាំ ដើម្បីពិភាក្សាវឌ្ឍនភាពក្នុងការអនុវត្តន៍យុទ្ធសាស្ត្ររបស់ពួកគេ រួមទាំងវឌ្ឍនភាពប្រៀបធៀបនឹងលទ្ធផល និងវឌ្ឍនភាពនៅក្នុងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍ដទៃទៀត។ ក្នុងមួយឆ្នាំម្តង ស្ថាប័នទាំងបី នឹងសុំការផ្តល់យោបល់របស់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធដទៃទៀតលើស្នាដៃរបស់ស្ថាប័នទាំងបីនេះ។ ADB ក៏នឹងបន្តជួយផងដែរដល់ការពង្រឹងការវិភាគគោលនយោបាយ និងការគ្រប់គ្រងកិច្ចអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ដោយផ្អែកលើការងារកំពុងដំណើរការរបស់ខ្លួននៅក្នុងការធ្វើកំណែទម្រង់ PFM។ ADB នឹងជួយកសាងសមត្ថភាពក្នុងការវិភាគគោលនយោបាយ និងយុទ្ធសាស្ត្រសេដ្ឋកិច្ចនៅក្នុងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ។ ការគាំទ្រចំពោះវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការក្នុងពេលអនាគត នឹងត្រូវបានពិនិត្យឡើងវិញលើមូលដ្ឋាននៃតម្រូវការ និងការចូលរួមរបស់អ្នកផ្តល់ជំនួយដទៃទៀត។

១០០. បច្ចុប្បន្ននេះ ADB កំពុងធ្វើពិសោធន៍ CSPs ផ្អែកលើលទ្ធផលនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិករបស់ខ្លួនមួយចំនួន។ CSPs បែបនេះរួមមានក្របខ័ណ្ឌលទ្ធផលមួយ ដែលជាឧបករណ៍ធ្វើផែនការនិង គ្រប់គ្រងដែលកំណត់ទំនាក់ទំនងរវាងគោលដៅអភិវឌ្ឍន៍ជាយុទ្ធសាស្ត្រ លទ្ធផល សូចនាករ និង បទអន្តរាគមន៍។ ទោះបីជា CSP កម្ពុជា មិនស្ថិតនៅក្នុងចំណោម CSPs ពិសោធន៍ផ្អែកលើលទ្ធផលក្តី ក៏វារួមមានការកែប្រែថ្មីមួយនៃក្របខ័ណ្ឌលទ្ធផល ដើម្បីជួយឆ្លើយតបទៅនឹងសំណួរដូចខាងក្រោមនេះ។ (១) តើជំនួយ ADB នឹងរួមចំណែកដល់ MDGs និង គោលដៅជាតិអ្វីខ្លះ? (២) តើអ្វីទៅគឺជាលទ្ធផលគន្លឹះដែលគេរំពឹងថានឹងបានមកពីជំនួយ ADB គួបផ្សំជាមួយនឹងកិច្ចប្រឹងប្រែងរបស់ភាគីអភិវឌ្ឍន៍ពាក់ព័ន្ធដទៃទៀត? (៣) តើគេនឹងប្រើសូចនាករអ្វីខ្លះដើម្បីវាយតម្លៃវឌ្ឍនភាពរយៈពេលមធ្យមឆ្ពោះទៅកាន់លទ្ធផលទាំងនេះ? (៤) តើ ADB នឹងគាំទ្រដល់អន្តរាគមន៍អភិវឌ្ឍន៍អ្វីខ្លះ ដើម្បីរួមចំណែកដល់ការសម្រេចបាននូវលទ្ធផលអភិវឌ្ឍន៍?

១០១. ក្របខ័ណ្ឌលទ្ធផលនេះមិនទាន់បានទទួលអត្ថប្រយោជន៍ពីដំណើរការដែល CSP ដែលផ្អែកលើលទ្ធផលដ៏ពេញលេញមួយ ចាំបាច់ត្រូវឆ្លងកាត់ឡើយ។ គោលបំណងចំបងនៅក្នុងដំណាក់កាលនេះ គឺដើម្បីចង្អុលបង្ហាញទិសដៅនៃកិច្ចប្រឹងប្រែងបច្ចុប្បន្នទាំងឡាយដែលមានលក្ខណៈចង្អុលបង្ហាញមួយនៃលទ្ធផល និងសូចនាករសំខាន់ៗទាំងឡាយដើម្បីវាយតម្លៃ និងធ្វើការកែតម្រូវលើកម្មវិធីដែលកំពុងដំណើរការរបស់ ADB។ ដោយសារគោលបំណង គឺចង់ឱ្យលទ្ធផល និងសូចនាករទាំងនេះក្លាយជាស្នូលនៃការរាយការណ៍ដ៏ទៀងទាត់អំពីវឌ្ឍនភាពនៃការអនុវត្តន៍ លទ្ធផលនិងសូចនាករទាំងនេះ ចាំបាច់ត្រូវបានកែលំអឡើងវិញ និងត្រូវបានកំណត់សំរាប់កម្មវិធីវិវឌ្ឍទៅមុខ (សូមមើលតារាង ក១.១២)។ ការធ្វើអោយមានភាពបច្ចុប្បន្នភាពជាប្រចាំរៀងរាល់ឆ្នាំនូវ CSP នឹងដើម្បីធ្វើការវាយតម្លៃលើ (១) វឌ្ឍនភាពដែលបានទទួលក្នុងការសម្រេចបានលទ្ធផលគន្លឹះទាំងឡាយ (២) ការកែលំអរបន្ថែមនូវសូចនាកររយៈពេលមធ្យម ដោយផ្អែកលើស្នាដៃគម្រោងនិងស្នាដៃ TA និងការកែសម្រួលយុទ្ធសាស្រ្តឡើងវិញ (៣) ស្នាដៃផលប័ត្រលីយ៉ូវិស័យ (៤) ភាពសមស្របនៃគម្រោងផ្តល់ឥណទាននិងមិនផ្តល់ឥណទាន និង (៥) វិភាជន៍ធនធាន ADF ដែលផ្អែកលើស្នាដៃ។